ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King

Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

---

អង្គជំនុំជម្រះសាលាដំបូង

Trial Chamber
Chambre de Premiere instance

ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 01-Apr-2016, 14:50
CMS/CFO: Sann Rada

# កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី

# ជំនុំជម្រះក្តីនៅដំណាក់កាលពីរ

## សាធារណៈ

សំណុំរឿងលេខ ០០២/១៩-០៩-២០០៧/អវតក/អជសដ

**ថ្ងៃទី២១ ខែមីនា ឆ្នាំ២០១៦**

**ម៉ោង ០៩:០៥នាទី**

**សវនាការលើកទី៣៨៦**

**ចៅក្រមសាលាដំបូង៖**

ចៅក្រម និល ណុន ជាប្រធាន

ចៅក្រម ក្លូឌា ហ្វេនស៍
*(Judge Claudia FENZ)*

ចៅក្រម យ៉ា សុខន

ចៅក្រម ហ្សង់ម៉ាក ឡាវ៉ែន
*(Judge Jean-Marc LAVERGNE)*

ចៅក្រម យូរ ឧត្តរា

ចៅក្រម ធូ មណី (បម្រុង)

ចៅក្រម ម៉ាទីន ខារ៉ុបគីន (បម្រុង)
*(Judge Martin KAROPKIN)*

**ក្រឡាបញ្ជីសាលាដំបូង៖**

លោក ម៉ាធូវ ម៉ាកាធី *(Mr.Matthew Mccarthy)*

លោក ឯម ហ៊័យ

**ការិយាល័យសហព្រះរាជអាជ្ញា៖**

លោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល
*(Mr. Vincent de wilde d'ESTMAEL)*

លោក ស្រ៊ា រតនៈ

លោក ឌេល លីសាក់ *(Mr. Dale Lysak)*

**ជនជាប់ចោទ៖**

លោក នួន ជា

លោក ខៀវ សំផន

**មេធាវីការពារជនជាប់ចោទ នួន ជា៖**

លោក សុន អរុណ

លោក វ៉ិចទ័រ កូប៉េ*(Mr.Victor KOPPE)*

លោក លីវ សុវណ្ណា

**មេធាវីការពារជនជាប់ចោទ ខៀវ សំផន៖**

លោក គង់ សំអុន

កញ្ញា អង់តា ហ្គីសសេ *(Ms. Anta GUISSE)*

**មេធាវីប្រចាំការលោក ខៀវ សំផន៖**

លោកស្រី ទូច វរល័ក្ស

លោក ខលវីន សោនដឺស៍
*(Mr. Calvin SAUNDERS)*

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

លោក ពេជ អង្គ

លោកស្រី ម៉ារី ហ្គីរ៉ូដ៍*(Ms.Marie GUIRAUD)*

លោក វ៉ែន ពៅ

លោកស្រី ជេត វណ្ណលី

លោកស្រី ស៊ីន សុវ៉ន

លោក ឡោ ជុនធី

លោកស្រី ទី ស្រ៊ីនណា

**ផ្នែកគ្រប់គ្រងតុលាការ៖**

លោក អ៊ុច អរុណ

លោកស្រី សួ សុទ្ធាវី

**បញ្ជីឈ្មោះអ្នកនិយាយ៖**

ភាសាដែលបានប្រើ លើកលែងតែមានការបញ្ជាក់ផ្សេងទៀតនៅក្នុងប្រតិចារឹក

| **អ្នកនិយាយ** | **ភាសា** |
|---|---|
| ចៅក្រម និល ណុន (ប្រធានអង្គជំនុំ) | ខ្មែរ |
| ចៅក្រម ហ្សង់ម៉ាក ឡាវែន៍ | បារាំង |
| ចៅក្រម ក្លូឌា ហ្វេនស៍ | អង់គ្លេស |
| លោក ខេល លីសាក់ | អង់គ្លេស |
| លោក វាំងសង់ វ៉ាយដ៍ ដេស្សាឯល | បារាំង |
| លោក ពេជ អង្គ | ខ្មែរ |
| លោក វ៉ិចទ័រ កូប៉េ | អង់គ្លេស |
| កញ្ញា អង់តា ហ្គីសសេ | បារាំង |
| សាក្សី 2-TCW-900 | ខ្មែរ |

# ឧបសម្ព័ន្ធ

**ការសួរសំណួរទៅសាក្សី៖** 2-TCW-900

សួរដោយប្រធានអង្គជំនុំ ផ្ដើមពី ........................................................................ ទំព័រ ១៦
សួរដោយលោក វ៉ាំងសង់ វ៉ាយដ៍ ដេស្មាឯល ផ្ដើមពី..................................................... ទំព័រ ១៩

# កិច្ចដំណើរការនីតិវិធី

*(ចៅក្រមចូលក្នុងបន្ទប់សវនាការ)*

[០៩:០៤:៥៩]

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ សវនាការនៅថ្ងៃនេះ អង្គជំនុំជម្រះនឹងធ្វើសវនាការស្តាប់សក្ខីកម្មសាក្សីដែលមានរហស្សនាម 2-TCW-900 ពាក់ព័ន្ធជាមួយនឹងអង្គហេតុចោទប្រកាន់មន្ទីរសន្តិសុខអូរកន្សែង ដោយធ្វើតាមប្រព័ន្ធសោតទស្សន៍។

មានបញ្ហាបកប្រែភាសា!

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

យើងមិនទាន់មានការបកប្រែនៅឡើយទេ ពីដំបូង។

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ ហើយសវនាការនៅថ្ងៃនេះអង្គជំនុំជម្រះធ្វើសវនាការស្តាប់សក្ខីកម្មសាក្សីដែលមានរហស្សនាម 2-TCW-900 ពាក់ព័ន្ធនឹងអង្គហេតុចោទប្រកាន់មន្ទីរសន្តិសុខអូរកន្សែង តាមរយៈប្រព័ន្ធសោតទស្សន៍ ដែលធ្វើទំនាក់ទំនងរវាងអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ជាមួយនឹងសាក្សីដែលមានទីតាំងនៅខេត្តឧត្តរមានជ័យ។

ក្រឡាបញ្ជីសវនាការ លោក ឯម ហ៊ុយ ឡើងរាយការណ៍អំពីស្ថានភាពវត្តមាន អវត្តមានភាគីនិងបុគ្គលដែលអង្គជំនុំជម្រះកោះអញ្ជើញឱ្យចូលរួមនៅក្នុងកិច្ចដំណើរការសវនាការថ្ងៃនេះ។

[០៩:០៧:០៤]

**ក្រឡាបញ្ជី៖**

សូមគោរពលោកប្រធាន សម្រាប់សវនាការថ្ងៃនេះ ក្រឡាបញ្ជីកត់សម្គាល់ឃើញថា គ្រប់ភាគីទាំងអស់នៃរឿងក្តីនេះមានវត្តមាន។ លើកលែងតែមេធាវីប្រចាំការរបស់លោក ខៀវ សំផន គឺលោកស្រី ទូច វរល័ក្ស ជូនដំណឹងមកថា នឹងមកដល់យឺតបន្តិច ដោយសារមូលហេតុស្ទះចរាចរណ៍។ ដោយឡែក

លោក នួន ជា មានវត្តមាននៅបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការនេះ ដោយលោកស្នើសុំលះបង់សិទ្ធិមានវត្តមានដោយផ្ទាល់ពីបន្ទប់សវនាការនៅថ្ងៃនេះ។ លិខិតលះបង់សិទ្ធិរបស់លោក នួន ជា បានប្រគល់ដល់ក្រឡាបញ្ជីរួចហើយ។

សាក្សីដែលនឹងត្រូវមកផ្តល់សក្ខីកម្មនៅថ្ងៃនេះ មានរហស្សនាម 2-TCW-900។ សាក្សីរូបនេះនឹងផ្តល់សក្ខីកម្មតាមរយៈប្រព័ន្ធសោតទស្សន៍ពីស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ។ សាក្សីបានបញ្ជាក់ថា តាមសមត្ថភាពដែលអាចគាត់ដឹង គឺគាត់មិនមានទំនាក់ទំនងញាតិលោហិត ឬញាតិពន្ធជាមួយនឹងជនជាប់ចោទទាំងពីររូប គឺលោក នួន ជា និងលោក ខៀវ សំផន ឬភាគីដើមបណ្តឹងរដ្ឋប្បវេណីណាមួយដែលត្រូវបានទទួលស្គាល់នៅក្នុងរឿងនេះទេ។ សាក្សីបានធ្វើសម្បថរួចហើយមុននឹងមកផ្តល់សក្ខីកម្ម។ សាក្សីមានមេធាវីប្រឹក្សាគឺលោក ម៉ម រិទ្ធា។

តាមការបញ្ជាក់ពីផ្នែកបច្ចេកទេសសោតទស្សន៍បានជូនដំណឹងថា ការរៀបចំផ្នែកបច្ចេកទេសសម្រាប់ការស្តាប់សក្ខីកម្មនៅពេលនេះ បានរៀបចំរួចរាល់ហើយ។ រីឯសាក្សីក៏បានត្រៀមខ្លួនជាស្រេចសម្រាប់ការផ្តល់សក្ខីកម្មនេះដែរ។ សូមអរគុណលោកប្រធាន។

[០៩:០៨:៣៩]

**ប្រធានអង្គជំនុំ៖**

អរគុណលោក ឯម ហ៊ាយ។ ជាដំបូងនេះអង្គជំនុំជម្រះសម្រេចលើសំណើសុំរបស់ជនជាប់ចោទ នួន ជា ជាមុនសិន។ អង្គជំនុំជម្រះបានទទួលលិខិតសុំលះបង់សិទ្ធិចូលរួមក្នុងសវនាការដោយផ្ទាល់ ក្នុងបន្ទប់សវនាការនេះ របស់ជនជាប់ចោទ នួន ជា។ ចុះថ្ងៃទី២១ ខែមីនា ឆ្នាំ២០១៦ ដែលបានបញ្ជាក់ថា ដោយគាត់មានបញ្ហាសុខភាព ឈឺក្បាល ឈឺចង្កេះ មិនអាចអង្គុយយូរ មិនអាចផ្តង់អារម្មណ៍បានយូរ និងដើម្បីមានលទ្ធភាពចូលរួមសវនាការនាថ្ងៃខាងមុខឲ្យមានប្រសិទ្ធភាព ខ្លួនសុំលះបង់សិទ្ធិចូលរួម និងមានវត្តមានដោយផ្ទាល់នៅក្នុងបន្ទប់សវនាការនេះ នៅថ្ងៃទី២១ ខែមីនា ឆ្នាំ២០១៦។ មេធាវីការពារក្តីរបស់ខ្លួនបានប្រាប់អំពីផលប៉ះពាល់នៃការលះបង់សិទ្ធិនេះថា ការលះបង់សិទ្ធិនេះមិនអាចបកស្រាយថាជាការលះបង់សិទ្ធិរបស់ខ្លួនក្នុងកាត់សេចក្តីដោយយុត្តិធម៌ ឬក៏សិទ្ធិក្នុងការជំទាស់នឹងភស្តុតាងក្នុងការដាក់បង្ហាញ ឬដាក់ជូនតុលាការនេះគ្រប់ពេលវេលានៃសវនាការលើរូបខ្លួនឡើយ។

បានឃើញកំណត់ហេតុពិនិត្យខុសភាពជនជាប់ចោទ នួន ជា ដែលធ្វើឡើងដោយគ្រូពេទ្យប្រចាំការ ពិនិត្យព្យាបាលថែទាំសុខភាពជនជាប់ចោទនៅ អ.វ.ត.ក ចុះថ្ងៃទី២១ ខែមីនា ឆ្នាំ២០១៦ បានកត់

សម្គាល់ពីស្ថានភាពសុខភាពរបស់លោក នួន ជា នៅថ្ងៃនេះថា មានអាការៈឈឺចង្កេះជាប្រចាំ វិលមុខ មិនអាចអង្គុយយូរបាន និងបានផ្តល់អនុសាសន៍ថា សូមឲ្យអង្គជំនុំជម្រះអនុញ្ញាតឲ្យលោក នួន ជា ចូលរួមតាមដានកិច្ចដំណើរការសវនាការពីបន្ទប់មួយស្ថិតនៅក្រោមសាលសវនាការនេះ។

[០៩:០៩:៥៩]

ផ្អែកលើមូលដ្ឋាននេះ និងយោងតាមបទប្បញ្ញត្តិនៃវិធាន៨១(៥)នៃវិធានផ្ទៃក្នុង អ.វ.ត.ក អង្គជំនុំជម្រះអនុញ្ញាតឲ្យជនជាប់ចោទ នួន ជា ចូលរួម និងតាមដានកិច្ចដំណើរការសវនាការពីចម្ងាយពីបន្ទប់ឃុំខ្លួនមួយស្ថិតនៅក្រោមសាលសវនាការនេះ តាមរយៈឧបករណ៍សោតទស្សន៍សម្រាប់រយៈពេលសវ-នាការពេញមួយថ្ងៃនេះ។

បង្គាប់ឲ្យបុគ្គលិកផ្នែកសោតទស្សន៍ភ្ជាប់ប្រព័ន្ធសោតទស្សន៍សម្រាប់ជនជាប់ចោទ នួន ជា អាចចូលរួមតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ នៅក្នុងអំឡុងពេលនៃកិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះ។

ហើយមុននឹងធ្វើការស្តាប់សក្ខីកម្មសាក្សីដែលមានរហស្សនាម 2-TCW-900 តាមរយៈប្រព័ន្ធសោតទស្សន៍ អង្គជំនុំជម្រះសម្រេច ទី១ គឺចេញសេចក្តីសម្រេចផ្ទាល់មាត់លើសំណើសុំរបស់សហព្រះរាជអាជ្ញាក្នុងការដាក់ឯកសារពិភាក្សាដេញដោលពាក់ព័ន្ធទៅសាក្សីរូបនេះ។ ហើយនិងទី២ អង្គជំនុំជម្រះនឹងធ្វើសវនាការស្តាប់សារណាផ្ទាល់មាត់ភាគីលើសំណើសុំរបស់សហព្រះរាជអាជ្ញា សុំបន្ថែមសាក្សីចំនួនពីររូបពាក់ព័ន្ធជាមួយអង្គហេតុភ្នំក្រោល។

ទី១ អង្គជំនុំជម្រះចេញសេចក្តីសម្រេចផ្ទាល់មាត់លើសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិដែលឯកសារ E319/36។ អង្គជំនុំជម្រះសាលាដំបូងបានទទួលសំណើរបស់សហព្រះរាជអាជ្ញាអន្តរ-ជាតិឯកសារ E319/36 ដែលបានស្នើសុំឲ្យអង្គជំនុំជម្រះទទួលយកកំណត់ហេតុស្តាប់ចម្លើយបន្ថែមចំនួន៩៥។ សំណើនេះរួមមានទាំងកំណត់ហេតុស្តាប់ចម្លើយសាក្សីដែលមានរហស្សនាម 2-TC-900 ដែលជាសាក្សីត្រូវផ្តល់សក្ខីកម្មនៅថ្ងៃនេះ (ហើយសូមមើលឯកសារ E319/36.2 ទំព័រ៤៨)។

[០៩:១១:៤៨]

បានពិចារណាឃើញថា ឯកសារនេះមានផលប្រយោជន៍ខ្លាំងនៅក្នុងកិច្ចដំណើរការនីតិវិធីសវនាការនៅថ្ងៃនេះ អង្គជំនុំជម្រះសម្រេចដោយផ្អែកទៅលើសំណើនោះ ហើយទទួលយកឯកសារ E319/23.3.5 ដែលជាកំណត់ហេតុចម្លើយរបស់សាក្សី 2-TCW-900 ជាឯកសារភស្តុតាង និង

កំណត់លេខឯកសារនេះជាឯកសារ E3/9734។ សំអាងហេតុជាលាយលក្ខណ៍អក្សរនៃសេចក្ដីសម្រេចនេះ និងដំណើរដែលនៅសេសសល់នៅក្នុងឯកសារ E319/36 នឹងចេញក្នុងរយៈពេលសមស្របខាងមុខនេះ។

ជាបន្ដទៅនេះអង្គជំនុំជម្រះធ្វើសារណាស្ដាប់សំណើសុំ ពាក់ព័ន្ធនឹងសំណើសុំរបស់សហព្រះរាជអាជ្ញាដែលបានស្នើសុំឱ្យកោះហៅសាក្សីបន្ថែម ឬជំនួសពាក់ព័ន្ធនឹងមន្ទីរសន្តិសុខភ្នំក្រោល (ឯកសារ E390)។ ហើយកាលពីថ្ងៃទី១៦ ខែមីនា ឆ្នាំ២០១៦ សហព្រះរាជអាជ្ញាបានដាក់សំណើសុំឱ្យអង្គជំនុំជម្រះកោះហៅសាក្សីបន្ថែមចំនួនពីររូបទៀតដែលមានរហស្សនាម 2-TC -- មួយគឺមាន 2-TCCP-1036 គឺដើមបណ្ដឹងរដ្ឋប្បវេណី និង 2-TCW-1017 ដើម្បីជំនួសសាក្សីមួយចំនួនដែលបានទទួលមរណភាព ហើយពាក់ព័ន្ធជាមួយនឹងមន្ទីរសន្តិសុខភ្នំក្រោល។ អាស្រ័យហេតុនេះ អង្គជំនុំជម្រះមានបំណងស្ដាប់សារណាភាគីផ្ទាល់មាត់នៅលើបញ្ហានេះ ដើម្បីមានមូលដ្ឋានក្នុងការយកទៅពិចារណាសម្រេចលើបញ្ហានេះឱ្យបានឆាប់ៗ។ ថាតើសម្រេចទទួលយក កោះហៅសាក្សីនេះបន្ថែម ឬយ៉ាងណា។

ហើយជាដំបូងនេះ អង្គជំនុំជម្រះផ្ដល់វេទិកាជូនទៅតំណាងសហព្រះរាជអាជ្ញា ដើម្បីឡើងបញ្ជាក់បន្ថែមលើសំណើសុំរបស់ខ្លួនដែលបានដាក់កាលពីថ្ងៃទី១៦ ខែមីនា ឆ្នាំ២០១៦ កន្លងមកនេះ។

[០៩:១៤:២៧]

**លោក ឌែល លីសាក់៖**

សូមអរគុណលោកប្រធាន។ ជម្រាបសួរលោក លោកស្រីចៅក្រម។ ខ្ញុំនឹងលើកឡើងដោយសង្ខេបពាក់ព័ន្ធទៅនឹងសំណើដែលពាក់ព័ន្ធទៅនឹងហេតុផល<ជាក់ស្ដែង>មួយ។ <>កាលពីខែមុន <នៅពេលដែលសាក្សី ត្រូវបានកំណត់បែងចែកពេលវេលា អង្គភាពគាំពារសាក្សី និងអ្នកជំនាញបានជូនដំណឹងដល់អង្គជំនុំជម្រះ និងភាគី ថាសាក្សីចំនួនបីរូបបានស្លាប់ ក្នុងចំណោមទាំងប្រាំមួយរូបដែលបានស្នើដោយ>តំណាងសហព្រះរាជអាជ្ញា<> ហើយយើងក៏ត្រួតពិនិត្យទៅលើបញ្ជីឈ្មោះសាក្សីទាំងអស់ ហើយនិងពិនិត្យមើលសាក្សីដែលអាចធ្វើការផ្ដល់សក្ខីកម្មនោះ ហើយយើងពិនិត្យទៅលើសាក្សីដែលអាចជំនួស<បាន> ហើយដោយសារតែសាក្សី<សក្ដានុពលដែលត្រូវមកជំនួស>មួយចំនួនបានស្លាប់<ផងដែរ>។

ដូច្នេះ ចំណុចនេះវាមានសារៈសំខាន់ណាស់ ពាក់ព័ន្ធទៅនឹងទីតាំង<ឧក្រិដ្ឋកម្ម>មួយចំនួនដែលមានការឃុំឃាំងទៅដល់សាក្សីទាំងអស់នោះ។ ហើយសាក្សី<ចំនួនពីរូបត្រូវបានស្ដាប់សក្ខីកម្មរួចមក

ហើយ ដែលពួកគាត់>ត្រូវបានគេឃុំឃាំងនៅក្នុងមន្ទីរ<><តំបន់> <ដែល>ជា<ផ្នែកមួយនៃក្រុមមនុស្ស>៨០នាក់ ដែលគេបានចាប់នៅក្នុង<អំឡុងពេលបោសសម្អាត>។ ហើយពាក់ព័ន្ធទៅនឹងការចោទប្រកាន់ទៅនឹងទីតាំង<នោះ> ហើយជាពិសេសគឺពាក់ព័ន្ធទៅនឹង<គុកដ៏ធំមួយ>ដែលគេប្រើប្រាស់ជាមន្ទីរឃុំឃាំង។ <>សាក្សី<ម្នាក់ ដែលយើងបានស្នើនោះ គាត់>បានស្លាប់ហើយ<។ គាត់ជាអតីតអ្នកទោសនៅមន្ទីរសន្តិសុខនោះ>។ ហើយមានសាក្សីមួយ<ទៀតក៏បានស្លាប់ដែរ គឺគាត់ត្រូវបានកំណត់អត្តសញ្ញាណ និង>សម្ភាសដោយការិយាល័យសហចៅក្រមស៊ើបអង្កេត <ដែលគាត់ជាប់ឃុំនៅក្នុងមន្ទីរសន្តិសុខធំជាងនោះ។> ហើយជាសំណាងល្អ ដែលយើងបានព្យាយាមរកនូវ<ដើមបណ្ដឹងរដ្ឋប្បវេណី ហើយពួកគេ>មួយចំនួន<បានស្លាប់។> ហើយ<មេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណីបានប្រាប់យើងថាមានតែ>ដើមបណ្ដឹងរដ្ឋប្បវេណី<ម្នាក់គត់នៅរស់ ក្នុងចំណោម៥នាក់ ហើយគាត់គឺជាមនុស្សដែល>យើងបានស្នើ<នៅពេលនេះ> <ហើយត្រូវបានលោកប្រធានកំណត់រហស្សនាម> គឺ <2-TCCP-1016> ។ <> គាត់ជាអតីតទាហាន<នៃកងពល៩២០។> ហើយ<មានការផ្ដល់>សក្ខីកម្ម<ថាមន្ទីរសន្តិសុខនេះ> គេបានប្រើប្រាស់<ជាញឹកញាប់ធ្វើជាកន្លែងឃុំខ្លួន>ពាក់ព័ន្ធទៅនឹងការបោសសម្អាតទាហាន<កងពល៩២០>។ ហើយក៏មានសាក្សី<ជំនួស ដែលយើងបានស្នើសុំ គឺគាត់>ជាបង <>ស្រី<របស់>សាក្សី<ម្នាក់>ដែលអង្គជំនុំជម្រះសាលាដំបូងបានសម្រេចធ្វើការអញ្ជើញ<ម្ដងទៀត>។ ហើយយើងក៏បានស្នើ<ឲ្យដំណើរការលើគ្រប់សាក្សីទាំងអស់><>ដែលមាន<>នៅទីតាំង<>នោះ។ ហើយគាត់ជាបង<>ស្រី ដែលគាត់អាចផ្ដល់ព័ត៌មានបានច្រើនជាង<ប្អូន>ប្រុសគាត់ ដែលធ្វើការងារនៅក្នុងមន្ទីរទូរលេខ<តំបន់>។ <មានមូលហេតុប្អូននៅក្នុងញត្តិរបស់យើង> គាត់មានវ័យចំណាស់ជាងប្អូន<ប្រុស>គាត់ប្រហែលជា <៥ ឬ>៨ឆ្នាំ ហើយគាត់ក៏ <មានតួនាទីមួយ>នៅក្នុង<យោធា>តំបន់នេះ នៅក្នុងឆ្នាំ៧៧។ <យោធាតំបន់នេះ មើលការខុសត្រូវលើ>មន្ទីរសន្តិសុខភ្នំក្រោលហ្នឹង។ <ដូច្នេះ សម្រាប់មូលហេតុទាំងអស់នេះ ដោយសារតែស្ថានភាពកម្រ ព្រោះ><សាក្សី>ចំនួន<ពាក់កណ្ដាលដែលបានស្នើសុំ គឺ>បានស្លាប់ ដូច្នេះយើងសូមធ្វើការ<ស្នើសុំ>សាក្សីចំនួនពីររូប<នេះជំនួសវិញ>។ សូមអរគុណ។

[០៩:១៨:១៥]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ សូមអញ្ជើញលោកចៅក្រម ហ្សង់ម៉ាក ឡាវែន៍!

---

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

សូមអរគុណលោកប្រធាន។ ខ្ញុំ<គ្រាន់តែបញ្ជាក់ដើម្បីឲ្យ>ច្បាស់<ថាតើខ្ញុំយល់ត្រឹមត្រូវឬទេ>។ <មនុស្សម្នាក់ ក្នុងចំណោម>អ្នកដែលលោកចង់សុំឲ្យកោះហៅនោះ ជាដើមបណ្ដឹងរដ្ឋប្បវេណីមែនទេ ដូច្នេះ<>រហស្សនាម<របស់គាត់អាចនឹងតម្រូវឲ្យផ្លាស់ប្ដូរ ព្រោះខ្ញុំជឿថា> រហស្សនាម<បច្ចុប្បន្នរបស់គាត់គឺ>TCW <ហើយមិនមែនជា TCCP ទេ>។

**លោក ឌេល លីសាក់៖**

ម្នាក់<ក្នុងចំណោមនោះ គឺ>ជាដើមបណ្ដឹងរដ្ឋប្បវេណី ដែលរស់រានមានជីវិត<ពីការ>ឃុំខ្លួន<នៅក្នុងគុក> ហើយ<ម្នាក់ទៀត> គាត់ជាសាក្សី ដែលជាកូនស្រីរបស់<លេខាតំបន់ ហើយគាត់ធ្វើការនៅក្នុង>មន្ទីរ<តំបន់>។

**ប្រធានអង្គជំនុំ៖**

បាទ បន្តទៅនេះផ្តល់វេទិកាជូនទៅក្រុមសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ដើម្បីអាចធ្វើសេចក្តីសន្និដ្ឋានផ្ទាល់មាត់ ឬក៏ធ្វើការកត់សម្គាល់លើបញ្ហាសំណើសុំរបស់សហព្រះរាជអាជ្ញាលើបញ្ហាអម្បាញ់មិញនេះ។ សូមអញ្ជើញ!

**លោក ពេជ អង្គ៖**

បាទ សូមគោរពលោកប្រធាន សូមគោរពលោក លោកស្រីចៅក្រម ភាគីដើមបណ្តឹងរដ្ឋប្បវេណី និងសាធារណជន។ ខាងមេធាវីនាំមុខ មិនមានអ្វីជាជំទាស់ទៅនឹងសំណើរបស់សហព្រះរាជអាជ្ញាទេ ដោយសារទាំងសាក្សី ទាំងដើមបណ្តឹងរដ្ឋប្បវេណីទាំងពីររូបនេះ គឺមានព័ត៌មានពាក់ព័ន្ធទៅនឹងមន្ទីរសន្តិសុខដែលស្ថិតនៅកោះញែក ហើយជាពិសេសពាក់ព័ន្ធទៅនឹងដើមបណ្តឹងរដ្ឋប្បវេណី យើងបានជួបជាមួយដើមបណ្តឹងរដ្ឋប្បវេណីពីសប្តាហ៍មុន ហើយលោកបានបញ្ជាក់ថា លោកអាចមកចូលរួមផ្តល់សក្ខីកម្មនៅទីបាន។ សូមអរគុណលោកប្រធាន។

[០៩:២០:២០]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ហើយជាបន្តទៅនេះ អង្គជំនុំជម្រះផ្តល់វេទិកាជូនក្រុមសហមេធាវី ដំបូងគេនេះផ្តល់វេទិកាទៅសហមេធាវីការពារក្តីលោក នួន ជា ដើម្បីឡើងធ្វើសារណាតបទៅនឹងសំណើសុំរបស់សហព្រះរាជអាជ្ញា។

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណលោកប្រធាន។ សូមជម្រាបសួរលោក លោកស្រីចៅក្រម ក៏ដូចជាមេធាវីភាគីទាំងអស់។ យើងនឹងឆ្លើយតបដោយសង្ខេប ហើយជាគោលការណ៍នោះ គឺយើងមិនមានការជំទាស់ទៅនឹងសំណើដែលលើកឡើងដោយតំណាងសហព្រះរាជអាជ្ញានោះទេ។ ក៏ប៉ុន្តែខ្ញុំកត់សម្គាល់ផងដែរថា នៅក្នុងសំណើជាលាយលក្ខណ៍អក្សរ នៅក្នុងកថាខណ្ឌទី៤ គឺថាព្រះរាជអាជ្ញាបានស្នើសុំឲ្យមាន 2-TCW-1017 <> គឺសូមឲ្យមាន<គាត់ជាសាក្សីជំនួស ឬក៏បន្ថែមជាមួយប្អូន>ប្រុស<គាត់>។ ហើយក៏ខ្ញុំឮពាក្យថា មានសាក្សីដែលជំនួស។ ហើយយើងជឿជាក់ថា ដើម្បីជាផលប្រយោជន៍ខាងសហមេធាវីការពារក្តីនោះ គឺ<សុំឲ្យប្អូនប្រុសគាត់>នេះ <នៅតែមកក្នុងនាម>ជាសាក្សី។ ហើយ<កាលពីលើកមុន> គាត់ក៏បានធ្វើសក្ខីកម្មរួចមកហើយ យើងបានជួបរួចហើយ <ប៉ុន្តែ>យើងមានសំណួរបន្ថែមចង់សួរគាត់។ ប៉ុន្តែខ្ញុំមិនច្បាស់ហេតុអីបានជា<មានការផ្លាស់ប្តូរនៅក្នុងកថាខណ្ឌទី៤ ឥឡូវនេះថាឲ្យជំនួសវិញនោះទេ។ ពីមុនគឺបានស្នើសុំឲ្យ>មានការ<>ជំនួស <ឬក៏បន្ថែម>។ ហើយយើងជឿជាក់ថា វាពិតជាសំខាន់ណាស់ដែល<>មាន<>បង<>ប្អូនប្រុស<ស្រីពីរនាក់>ហ្នឹង មកធ្វើសក្ខីកម្ម។

ហើយចំណុចទី២ នៃការកត់សម្គាល់របស់ខ្ញុំហ្នឹង <គឺ>ការអង្កេត<មួយ ដែលឯករាជ្យពីការស្នើសុំពិសេសនេះ។> ខ្ញុំសូមជម្រាបជូនអង្គជំនុំជម្រះសាលាដំបូងថា <យើងខ្ញុំកំពុងរៀបចំស្នើសុំតាម> វិធានផ្ទៃក្នុង៨៧ <ដើម្បី>ស្នើសុំឲ្យមានសាក្សី<បន្ថែមម្នាក់ទៀត> ពាក់ព័ន្ធទៅនឹងមន្ទីរសន្តិសុខភ្នំក្រោលហ្នឹង គឺវាជិតរួចរាល់ហើយ។ ហើយយើងរីករាយនឹងបញ្ជូន<ឯកសារមួយ នៅពេលណាមួយក្នុងប៉ុន្មាន>ថ្ងៃនេះ។ <វាអាចជាអ្វីមួយ ដែលអង្គជំនុំជម្រះចង់ធ្វើការសម្រេចចិត្តនៅពេលជាមួយគ្នានោះដែរ។ បើសិនជាមិនអនុញ្ញាតទេ យើងនឹងគ្រាន់តែដាក់ពាក្យស្នើសុំតែប៉ុណ្ណោះ> ហើយយើងនឹងរៀបចំ <ដោះស្រាយ>នៅពេលក្រោយ។ សូមអរគុណ។

[០៩:២៣:១៦]

**កញ្ញា អង់តា ហ្គីសសេ៖**

សូមអរគុណលោកប្រធាន។ សូមគោរពលោកប្រធាន លោក លោកស្រីចៅក្រម និង ភាគីទាំងអស់។ មេធាវីការពារក្តីលោក ខៀវ សំផន យើងជំទាស់។ ជំទាស់ទៅនឹងសំណើនេះ ដោយផ្អែកលើវិធាន៨៧(៤) ពាក់ព័ន្ធនឹងការកោះហៅសាក្សីថ្មី<ពីរនាក់ ដោយ>មានហេតុផលជាច្រើន។ ជាដំបូងខ្ញុំធ្វើការកត់សម្គាល់ជាទូទៅ ទៅលើភាពយឺតយ៉ាវនៃសំណើនេះ។ ខ្ញុំស្តាប់ឮការពន្យល់ពីសហព្រះរាជ

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

អាជ្ញាអន្តរជាតិនៅថ្ងៃនេះថា ក្រោយពីមានការសម្រេចរបស់អង្គជំនុំជម្រះទៅលើបញ្ជីកាលពីថ្ងៃទី០៥ ខែកុម្ភៈ ឆ្នាំ២០១៦ ខ្លួន<បាន>ពិនិត្យមើលឡើងវិញ ទៅលើអង្គហេតុពាក់ព័ន្ធទៅនឹងភ្នំក្រោល។ ក៏ប៉ុន្តែរបៀបវារៈនិងដំណើរការប្រព្រឹត្តទៅនៃសំណើរបស់សហព្រះរាជអាជ្ញានេះ គឺវាមិន<មែនមិន>សមស្របទេ។ កាលពីថ្ងៃទី០៥ ខែកុម្ភៈ ឆ្នាំ២០១៦ យើងមានបញ្ជីថ្មី <ហើយការ>ដាក់សំណើ<ទើបតែធ្វើនៅថ្ងៃទី១៦ ខែមីនា ឆ្នាំ២០១៦ តែប៉ុណ្ណោះ>។ អ៊ីចឹងការដាក់សំណើហ្នឹងវាយឺតពេលបន្តិច ដោយវគ្គស្ដីពីភ្នំក្រោលហ្នឹងបានចាប់ផ្ដើមរួចទៅហើយ ព្រោះថាថ្ងៃទី០២ ថ្ងៃទី០៣ <និងថ្ងៃទី៧> មីនា <ដែល> អង្គជំនុំជម្រះបានស្ដាប់សាក្សី<ពីនាក់ដំបូង>រួចទៅហើយ<>។

ដូច្នេះនេះមិនមែនជាលើកទី១ទេ ដែលសហព្រះរាជអាជ្ញាគាត់តែងតែ<ដាក់សំណើសុំនៅពាក់កណ្ដាលវគ្គសវនាការបែប>នេះនោះ គឺ<អាចនិយាយបាន>ថា នៅពេលដែល<សាក្សីនានាបានបង្ហាញខ្លួន>រួចទៅហើយ។ <យើងខ្ញុំដែលជាក្រុមមេធាវីការពារក្ដីលោក ខៀវ សំផន យល់ឃើញថានេះជាការប៉ុនប៉ងរបស់សហព្រះរាជអាជ្ញា ដើម្បីកែតម្រូវនូវអ្វីដែលបាននិយាយក្នុងអំឡុងពេលនីតិវិធីសវនាការ>។ <បើជាការពិតដែលថា>សាក្សីស្ដាប់នុ៎ង <គឺជា>ចំណុច<កណ្ដាលក្នុងការស្នើសុំសាក្សីទាំងពីរនាក់>ហ្នឹង <នោះការស្នើសុំនេះគួរតែត្រូវបានធ្វើឡើង តាំងពីមុនពេលចាប់ផ្ដើមវគ្គនេះម៉្លេះ ហើយពួកគេមិនបានធ្វើដូច្នោះទេ>។ <ខ្ញុំសូមរំឭកអង្គជំនុំជម្រះថា បញ្ហានេះក៏បានកើតឡើងផងដែរពាក់ព័ន្ធទៅនឹងការប្រព្រឹត្តិចំពោះជនជាតិចាម>។ <ការស្នើសុំថ្មីមួយ ដើម្បីបង្ហាញសាក្សី E366 ត្រូវបានធ្វើឡើង។> ចំពោះជនជាតិវៀតណាម <>មានសំណើពីរ<ត្រូវបានដាក់សុំ>គឺ E381 និង E382 ។ ហេតុអីបានជាខ្ញុំលើកឡើងអ៊ីចឹង ពីព្រោះថាយើងបានបញ្ជាក់ជូនអង្គជំនុំជម្រះរួចមកហើយ ថាគោលការណ៍យោងតាមវិធាន៨៧(៤) ហ្នឹងជាការគោលការណ៍លើកលែង។ <គេស្នើសុំ>យើង<ឱ្យ>កោះហៅសាក្សី<ដែល>យើងមិនអាចកំណត់<>បានពីមុន ឬក៏សាក្សីទាំងអស់នុ៎ង<ដែលមានព័ត៌មាន>សំខាន់<ពាក់ព័ន្ធត្រូវផ្ដល់ឱ្យ> ហើយដែលយើងមិនអាចកំណត់បានជាមុន។ ហើយក្នុងករណីយើងនេះមិនមែនអ៊ីចឹងទេ។

[០៩:២៦:២១]

តាំងពីថ្ងៃទី០៥ ខែកុម្ភៈ ឆ្នាំ២០១៦មកម៉្លេះ សហព្រះរាជអាជ្ញាបានដឹងហើយថា មានសាក្សីណាខ្លះដែលអង្គជំនុំជម្រះគ្រោងនឹងកោះហៅ<>។ អ៊ីចឹងយើង<មិនចូលចិត្តការធ្វើ>របៀប<នេះ គឺ>ការស្នើសុំ<សាក្សីនៅពាក់កណ្ដាលវគ្គ ក្លាយទៅ>ជាទម្លាប់<ទេ ព្រោះការធ្វើបែបនេះ គឺជាបញ្ហាអនុវត្ត

ជាក់ស្ដែងសម្រាប់យើង ដែលជាមេធាវីការពារក្ដី ក្នុងការរៀបចំទុកជាមុនរបស់យើង>។ យើង<មានឧទាហរណ៍នៅចំពោះមុខយើង>នៅថ្ងៃហ្នឹង។ <យើងមាន>សហព្រះរាជអាជ្ញា<ដែលនឹងឆ្លើយបំភ្លឺចំពោះការដាក់ពាក្យសុំ ហើយមានសហព្រះរាជអាជ្ញាផ្សេងទៀត ដែលនឹង>សួរសាក្សី <ចំណែកយើងដែលជាមេធាវីការពារក្ដី គឺជាមនុស្សតែមួយ ដែលជាអ្នកដាក់ពាក្យស្នើសុំផង ឆ្លើយតបចំពោះការដាក់ពាក្យស្នើសុំផង ហើយនិងសួរដេញដោលរាល់សាក្សីទាំងអស់ក្នុងសវនាការផង>។ <>អ៊ីចឹង<ការស្នើសុំសាក្សីនៅនាទីចុងក្រោយ ក្នុងអំឡុងពេលវគ្គមួយកំពុងដំណើរការ គួរតែ>បញ្ឈប់<ទៅ>។ <វាបង្កើតបញ្ហាចំពោះការរៀបចំឯកសារ> វាធ្វើឱ្យ<>មិនមានសមភាពនៃមធ្យោបាយតទល់ក្ដីទេ។ <យើងមិនអាចត្រៀមខ្លួន ដើម្បីកោះហៅសាក្សីទាំងអស់នេះនៅពាក់កណ្ដាលវគ្គបានទេ។ យើងមានរយៈពេលបួនសប្ដាហ៍ ក្រោយពីពេលដែលគេប្រាប់យើងថា សាក្សីមួយណានឹងចូលផ្ដល់សក្ខីកម្មពាក់ព័ន្ធនឹងវគ្គមួយនោះ នរណាដែលគេនឹងហៅឱ្យមានវត្តមានផងដែរ នៅក្នុងសវនាការផ្សេងទៀត ពាក់ព័ន្ធនឹងវគ្គផ្សេងទៀត>។

[០៩:២៨:០៥]

អ៊ីចឹងយើងឃើញហើយថា <មានការរំខានក្នុងការធ្វើផែនការ និង>កាលវិភាគ<ឯករាជ្យរបស់អង្គជំនុំជម្រះ ពាក់ព័ន្ធទៅនឹងលទ្ធភាពរបស់សាក្សី>។ <ដូច្នេះ>ហើយការដាក់សំណើ<>តាមវិធាន៨៧(៤)ហ្នឹង<> វាធ្វើឱ្យយើងពិបាកក្នុងការរៀបចំខ្លួនណាស់។ <ហើយយើងអាចយកឧទាហរណ៍ករណីរបស់សាក្សី អ៊ីន យឿង។ គេប្រាប់យើងថា>សាក្សី<>សំខាន់ណាស់<នឹងចូលបំភ្លឺ ហើយបន្ទាប់មក ក្រោយមកទៀត យើងពិតជាមិនយល់ទាល់តែសោះ>ថា ម៉េចបានជាអង្គជំនុំជម្រះសម្រេចកោះហៅ<សាក្សី>នោះ<>។ <ដូច្នេះហើយ ខ្ញុំចង់សំដៅលើចំណុចនេះ រាល់អ្វីៗទាំងអស់ដែលយើងសង្កេតគឺថា ថ្មីៗនេះ ការស្នើសុំតាម>វិធាន៨៧(៤)<ដែល>សហព្រះរាជអាជ្ញា<ស្នើឡើង> គឺដូចជាលក្ខណៈជាប្រព័ន្ធអ៊ីចឹង ត្រូវបានអង្គជំនុំជម្រះទទួលយករហូត។ <កាន់តែច្បាស់នោះ>ភ័ស្តុតាងហ្នឹង គឺហៅមកសុទ្ធតែដាក់បន្ទុកទៀត<>។

<យើងបានដាក់ពាក្យសុំឱ្យកោះហៅសាក្សី៧នាក់ ប៉ុន្តែ>អង្គជំនុំជម្រះ<នៅមិនទាន់សម្រេចលើពាក្យស្នើសុំនោះទេ ដើម្បីឱ្យយើងមានសាក្សី ដែលអាច>ផ្ដល់សក្ខីកម្មទៅលើវគ្គជាច្រើនទៀត។ <ហើយពួកគេអាចមានព័ត៌មានច្រើនត្រូវនិយាយ ពាក់ព័ន្ធទៅនឹងវគ្គកន្លងមក>ទាក់ទងនឹង<ជនជាតិ>វៀតណាម <ក៏ដូចជា>ជនជាតិចាម<>។ ក៏ប៉ុន្តែ<ជាសំណាងអាក្រក់ យើងសង្កេតឃើញថា>ករណី

ដូចអ្នកជំនាញចុងក្រោយអ៊ីចឹងដែរ គឺអង្គជំនុំជម្រះហាក់ដូចជាទទួលយកតែសាក្សី<>ដាក់បន្ទុក<>។

[០៩:២៩:៤៨]

ហើយចំពោះសាក្សី ហើយនិងដើមបណ្ដឹងរដ្ឋប្បវេណីថ្មីពីររូប ដែលសហព្រះរាជអាជ្ញាចង់កោះហៅនៅចំពោះមុខអង្គជំនុំជម្រះនេះ ទាក់ទងទៅនឹងសាក្សីទី១ ខ្ញុំមិនបានកត់លេខរហស្សនាមថ្មី<ឲ្យបានត្រឹមត្រូវនោះទេ> ខ្ញុំគិតថា ប្រហែលជា 2-TCW-2017 ខ្ញុំហៅ<គាត់>ថាបងស្រី<របស់សាក្សីម្នាក់ទៀត>ទៅចុះ។ <> តាមរយៈការអានកំណត់ហេតុទាំងអស់របស់គាត់ហ្នឹង ខ្ញុំមើលទៅដូចជាសាក្សីហ្នឹង ដូចជាមិនមានព័ត៌មានអីសំខាន់ពាក់ព័ន្ធនឹងមន្ទីរសន្តិសុខភ្នំក្រោលសោះ។ ហើយសាក្សីហ្នឹងមិនបានធ្វើការនៅ<ទីនោះ>ទេ នៅពេលដែល<ទីនោះ>ជាមន្ទីរសន្តិសុខនោះ។ ហើយបើខ្ញុំអានកំណត់ហេតុ<របស់គាត់ម្ដងទៀត> គឺថាគាត់ធ្វើ<ការនៅទីនោះ នៅពេលដែលវាជា>មន្ទីរតំបន់<ក្នុងឆ្នាំ១៩៧៤> មិនមែនជាមន្ទីរសន្តិសុខនៅឡើយទេ។ ដូច្នេះ គាត់នៅក្នុងកងវរសេនាតូចស្ត្រីនុ៎ង <> មិនអាចឲ្យគាត់មកនិយាយអ្វីពាក់ព័ន្ធនឹងមន្ទីរសន្តិសុខភ្នំក្រោលហ្នឹងបានទេ។ <វាមិនសមហេតុផលសោះដែលឲ្យគាត់ផ្ដល់សក្ខីកម្មលើចំណុចនេះ។> ហើយស្ត្រីរូបនេះ គាត់បាននិយាយនៅក្នុងកំណត់ហេតុនោះ គាត់អត់មានបាននិយាយអំពីការបោសសម្អាត មិនបាននិយាយសន្តិសុខ អត់បាននិយាយពាក់ព័ន្ធនឹងជនជាតិចាម ជនជាតិវៀតណាមអីនោះទេ។ អ៊ីចឹងខ្ញុំមើលទៅដូចជាមិនមានហេតុផលអ្វីដែលត្រូវកោះហៅគាត់ ហើយសក្ខីកម្មរបស់គាត់ ដូចជាមិនអាចបញ្ជាក់អ្វីបានអំពីដំណើរការនៃមន្ទីរសន្តិសុខភ្នំក្រោលនុ៎ងទេ។ គាត់មិនបានធ្វើការក្នុងនៅមន្ទីរសន្តិសុខហ្នឹងទេ ខ្ញុំសូមសង្កត់ធ្ងន់ត្រង់ចំណុចនេះ។ ដូច្នេះយើងបង្ហិនពេលអត់ប្រយោជន៍នៅពេលដែលកោះហៅសាក្សីហ្នឹងមក។

ហើយ<ខ្ញុំចង់ទទូចថា មិនមែនដោយសារ>សហព្រះរាជអាជ្ញា គាត់មិនពេញចិត្តនូវក្នុងសក្ខីកម្មរបស់សាក្សីផ្សេង <ហើយយើងចេះតែពន្យារនីតិវិធីដោយគ្មានកំណត់ ដោយសង្ឃឹមថានឹងទទួលបានភ័ស្តុតាង>ដាក់បន្ទុក<បន្ថែម>នោះ<ទេ។ ក្នុងការធ្វើដូច្នេះ គឺជាការកោះហៅសាក្សីថ្មីនៅពាក់កណ្ដាលវគ្គ ដោយគ្មានដំណោះស្រាយពិសេស>។ <> ដូច្នេះខ្ញុំមើលទៅឃើញថា តាមរយៈកំណត់ហេតុរបស់ស្ត្រីរូបនេះ ខ្ញុំគិតថាដូចជាមិនមានសារៈសំខាន់អ្វីក្នុងការស្វែងរកការពិតទេ <ពាក់ព័ន្ធទៅនឹងភ្នំក្រោល> នោះ។

[០៩:៣២:១៤]

ហើយចំពោះ<ការព្រួយបារម្ភរបស់>ដើមបណ្ដឹងរដ្ឋប្បវេណីវិញ យើង<មាន>អតីតទាហាន

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

កងពលដែលបានមកផ្តល់សក្ខីកម្មរួចមកហើយ។ ហើយនៅក្នុងឯកសាររបស់គាត់ដែលជាពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី <គឺមិនបាននិយាយយោងទៅដល់មន្ទីរសន្តិសុខភ្នំក្រោលនោះទេ>។ ដូច្នេះខ្ញុំមើលទៅឃើញថា ដូចជាសក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណីរូបនេះមិនមានប្រយោជន៍អីក្នុងការស្វែងរកការពិតទេ យោងតាមវិធាន៨៧(៤)។ ហើយវិធាន៨៧(៤) នោះ គឺថាទាល់តែមានហេតុការណ៍លើកលែង ហេតុការណ៍ពិសេសណាមួយទើបឲ្យយើងកោះហៅសាក្សី ដើម្បីមកផ្តល់ភ័ស្តុតាងបន្ថែម។ ហើយប្រសិនបើមិនមានភាពជាប់ពាក់ព័ន្ធអ្វីទៅនឹងសាក្សីថ្មី <ឬក៏ដើមបណ្តឹងរដ្ឋប្បវេណីថ្មី>ដែលលើកឡើងដោយសហព្រះរាជអាជ្ញាទេ <ហើយចម្លើយរបស់សាក្សីដែលបានស្លាប់ ដែលគេគិតថានឹងមកបង្ហាញខ្លួនក្នុងសវនាការនោះ ខ្ញុំ>ដូចជាមិន<ឃើញថាជាការ>ជំនួសទេ <ប៉ុន្តែគឺជាការបន្ថែមទៅវិញ>។ <ពួកគេកំពុងតែស្នើសុំភ័ស្តុតាងបន្ថែម មិនមែនការជំនួសទេ ដូចដែលអង្គជំនុំជម្រះបានពិនិត្យមើលឃើញហើយ។ នេះគឺជាការបន្ថែមភ័ស្តុតាង ដែលអាចធ្វើឲ្យព្រះរាជអាជ្ញាពន្យារនីតិវិធីគ្មានទីបញ្ចប់។> អ៊ីចឹងខ្ញុំសូមឲ្យអង្គជំនុំជម្រះបដិសេធចោលនូវសំណើរបស់សហព្រះរាជអាជ្ញា ពីព្រោះថាវគ្គចុងក្រោយនេះបានចាប់ផ្តើមរួចមកហើយ ហើយការដាក់សំណើនេះវាយឺតពេលទៅទៀត។

[០៩:៣៣:៤៦]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ហើយជាចុងក្រោយនេះ អង្គជំនុំជម្រះផ្តល់វេទិកាជូនទៅតំណាងសហព្រះរាជអាជ្ញាអន្តរជាតិ ដើម្បីមានឱកាសឡើងធ្វើសេចក្តីតបទៅនឹងសេចក្តីជំទាស់របស់ខាងភាគីម្ខាងទៀត គឺខាងសហមេធាវីការពារក្តី។ សូមអញ្ជើញសហព្រះរាជអាជ្ញារងអន្តរជាតិ!

**លោក ឌេល លីសាក់៖**

សូមអរគុណលោកប្រធាន។ ដំបូងសូមឆ្លើយតបទៅនឹងមេធាវីការពារក្តីក្រុម នួន ជា នៅពេលដែលខ្ញុំនិយាយថា យើងខ្ញុំសូមស្នើឲ្យកោះហៅសាក្សី<ទាំងនោះ មកធ្វើជាសាក្សីជំនួស> គឺយើងចង់សំដៅទៅលើថាឲ្យកោះហៅ<សាក្សីជំនួស>ទៅលើអ្នកដែលបានស្លាប់ ជំនួសអ្នកដែលស្លាប់<។> ក្នុងករណី<បងស្រីគាត់>គឺថា គាត់អាច<ត្រូវបាន>កោះហៅ<មកជំនួស ឬក៏បន្ថែម ហើយយើងមិនជំទាស់ទៅនឹងការកោះហៅប្អូនប្រុសរបស់គាត់មកនោះទេ> បើសិនណា<មានភាគីណាមួយ ឬក៏> អង្គជំនុំជម្រះមានបំណងចង់ស្តាប់សក្ខីកម្មរបស់សាក្សីរូបនេះ។ ដូច្នេះជំហររបស់ខាងសហព្រះរាជអាជ្ញា<គឺនៅដដែល។ យើង>ស្នើសុំ<មនុស្សទាំងអស់នេះ ដើម្បី>ជំនួសសាក្សីដែលបានស្លាប់ទៅ

ហើយនោះ។ យើងខ្ញុំមិនជំទាស់ទេ បើសិនណាជាអង្គជំនុំជម្រះចង់ស្ដាប់ទាំងបងប្អូនប្រុសស្រី អ្នកទាំងពីរនេះ។

ទាក់ទងទៅនឹងក្រុមការពារក្ដីរបស់ ខៀវ សំផន វិញម្ដង។ ខ្ញុំគិតឃើញថា <--> <ញត្តិ>ស្នើ<>សុំនេះ<យឺតពេល ពីព្រោះយើងចំណាយ>រយៈពេលមួយខែ <ដើម្បីត្រឡប់ទៅមើលឯកសារ>។ តំបន់នេះជាតំបន់មួយដែលមានលក្ខណៈស្មុគស្មាញ បើសិនណាជា<អ្នកអានកំណត់ហេតុស្ដាបចម្លើយ>សាក្សី<ទាំងនេះ ដើម្បីកំណត់ថា តើអ្នកជាប់ឃុំមួយណា មកពីមន្ទីរសន្តិសុខមួយណា។><>។ <>។ យើងខ្ញុំក៏បានចង្អុលបង្ហាញរួចមកហើយថា <ចំណុចនេះបានចាប់ផ្ដើមរួចហើយ។> ហេតុផល<តែមួយគត់ ដែលចំណុចនេះបានចាប់ផ្ដើមរួចហើយនោះ> គឺដោយសារថាសាក្សីពីរនាក់ដំបូង គាត់<ត្រូវបានពន្យារ ហើយ>នេះដោយសារតែ<><សំណើរបស់មេធាវីការពារក្ដី ខៀវ សំផន សុំពន្យារពេលដើម្បីមកស្ដាប់សក្ខីកម្មបញ្ចប់របស់អ្នក>ជំនាញ អ៊ីសា ឧស្មាន <ហើយក៏ដោយសារតែបញ្ហាសុខភាពរបស់សាក្សីមួយចំនួនទៀតដែរ>។ ហើយយើងខ្ញុំក៏កំពុងតែ<បន្ត>បញ្ចប់<ការស្ដាប់សក្ខីកម្ម>ពីសាក្សីជំនាញ អ៊ីសា ឧស្មាន <ហើយយើងក៏កំពុងតែបន្តបញ្ចប់ស្ដាប់សក្ខីកម្មសាក្សី>ពាក់ព័ន្ធទៅនឹងអ្នកខ្សែង<>។

[០៩:៣៦:២៣]

<មូលហេតុតែមួយគត់ ដែលយើងបានស្ដាប់សក្ខីកម្មសាក្សីពាក់ព័ន្ធមន្ទីរសន្តិសុខភ្នំក្រោលហើយនោះ គឺដោយសារតែវាជាប្រភេទស្ថានភាពដ៏កម្រមួយ ក្នុងការលៃលកកាលវិភាគសវនាការ។ ខ្ញុំមិនគិតថា វាមិនត្រឹមត្រូវនោះទេក្នុងការនិយាយថា សំណើសុំនេះវាយឺតយ៉ាវ>។ នេះមិនមែនជា<គោលបំណងក្នុងការកែប្រែនោះទេ>។ <នេះជាការឆ្លើយតបទៅនឹង>បញ្ហា<ជាក់ស្ដែង>ដែល គឺដោយសារតែសាក្សី<>ចំនួន<ពាក់កណ្ដាល នៃសាក្សីទាំងអស់ដែលយើងបានស្នើសុំ>នោះ បានស្ដាប់ទៅហើយ។ <ឆ្លើយតបទៅនឹងក្រុមការពារក្ដី ដែលថា> ក្នុងករណីនេះ គឺមាន<តែ>សហព្រះរាជអាជ្ញាដែលស្នើសុំទៅដោយអនុលោមទៅតាមវិធាន៨៧(៤) <នោះ គឺវាខុសទាំងស្រុង។ ក្រុមមេធាវីការពារក្ដី នួន ជា ធ្លាប់បានដាក់សំណើមួយចំនួននៅក្នុងអំឡុងពេលវគ្គសវនាការ ហើយវាក៏ត្រូវបានសម្រេចផ្ដល់ឱ្យផងដែរ>។

យើងខ្ញុំតែងតែបានទទួល<ការ>ស្នើសុំទាំងពីរក្រុម ខៀវ សំផន ក៏ដូចជាក្រុម នួន ជា ដែរ គឺថាមួយថ្ងៃ មុនពេលសាក្សី <និងអ្នកជំនាញ>ចូលមកផ្ដល់សក្ខីកម្ម ជាសំណើ<សុំបន្ថែម> ដែលអនុវត្ត

ទៅតាមវិធាន៨៧(៤)។ <ហើយយើងត្រូវបានឲ្យឆ្លើយតបទៅនឹងសំណើទាំងអស់នោះ ក្នុងសវនាការនៅថ្ងៃបន្ទាប់ គឺយើងរីករាយនឹងធ្វើដូច្នេះ។> ហើយយើងចង់ឲ្យដំណើរការនេះវាមានដំណើរការជឿនលឿនទៅមុខ។ អ៊ីចឹង<ខ្ញុំគិតថា វាមិនត្រឹមត្រូវទេ ដែលថា> មានតែសហព្រះរាជអាជ្ញាទេ បានដាក់សំណើសុំ<>បន្ថែម<ភស្តុតាង ហើយថា អង្គជំនុំជម្រះសាលដំបូងគ្រាន់តែពិចារណាសំណើសុំរបស់យើងប៉ុណ្ណោះ>។

ជាចុងក្រោយឆ្លើយ<តប>ទៅនឹងចំណុចជាក់លាក់ដែលលើកឡើងអំពីសាក្សីទាំងពីររូបនេះដោយក្រុមមេធាវីការពារក្តី ខៀវ សំផន។ គុក <ដែលដើមបណ្តឹងរដ្ឋប្បវេណី> 2-TCCP-1016 <ច្បាស់ថាជា>មន្ទីរសន្តិសុខនៅភ្នំក្រោល ដែលគាត់បានរៀបរាប់នៅក្នុងពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់គាត់ ថាជាមន្ទីរសន្តិសុខមួយមានទីតាំងនៅជិត<ភ្នំមួយ ក្នុង>ស្រុកកោះញែក <ហើយនោះជាមន្ទីរសន្តិសុខភ្នំក្រោលតែមួយគត់ ដែលនៅជិតភ្នំ។ វាជាកន្លែងតែមួយគត់>ដែលនៅទីនោះ គឺកងទ័ពមកពីកងពល៩២០ ត្រូវបានគេឃុំខ្លួននៅទីនោះ។ <ដូច្នេះមិនបាច់សំណួរ ដែលថាគាត់ពាក់ព័ន្ធនឹងវគ្គនេះទេ។

ជាថ្មីម្តងទៀត ពាក់ព័ន្ធទៅនឹងបងស្រី<នេះ> សាក្សីរូបនេះគឺថាមានព័ត៌មានពាក់ព័ន្ធ ហើយអង្គជំនុំជម្រះបានសម្រេចជ្រើសរើសយកប្អូន<ប្រុស>របស់គាត់ ដោយសារគាត់មានព័ត៌មានពាក់ព័ន្ធទៅនឹងមន្ទីរសន្តិសុខមួយនេះ។ សាក្សីរូបនេះ លោកស្រីរូបនេះគឺថាគាត់មិនធ្វើការនៅក្នុងពន្ធនាគារនោះមែនមន្ទីរសន្តិសុខនោះមែន ក៏ប៉ុន្តែគាត់ធ្វើការតែចម្ងាយ១គីឡូម៉ែត្រពីកន្លែងនោះ។ ដូច្នេះអ្នកដែលនៅក្នុង<មន្ទីរ>តំបន់នេះគឺដឹងអំពីរចនាសម្ព័ន្ធក្បាលម៉ាស៊ីនចាត់តាំងរបស់មន្ទីរសន្តិសុខនេះ។ ដូច្នេះគាត់អាចផ្តល់ព័ត៌មានពាក់ព័ន្ធទៅនឹងមន្ទីរសន្តិសុខ ទាក់ទងទៅនឹងទិដ្ឋភាពទូទៅនៃមន្ទីរតំបន់នេះតែម្តង <រួមទាំងការណែនាំពីមជ្ឈិម ពីព្រោះនាងធ្វើការនៅក្នុងមន្ទីរទូរលេខ មួយរយៈដែរ>។ នេះជាហេតុផលដែលសហព្រះរាជអាជ្ញានៅប្រកាន់ជំហរបែបនេះឯង។ សូមអរគុណលោកប្រធាន។

[០៩:៣៩:៤៣]

**កញ្ញា អង់តា ហ្គីសសេះ**

សូមអរគុណលោកប្រធាន។ <មានចំណុចពីរដែលត្រូវ>ឆ្លើយតប<>។ ពិតណាស់ខាងមេធាវីការពារក្តីលោក ខៀវ សំផន ហើយនិង នួន ជា គឺយើងមានសំណើតាមវិធាន៨៧(៤) ក៏ប៉ុន្តែនៅពេលដែលឆ្លើយតបទៅនឹងសំណើរបស់សហព្រះរាជអាជ្ញា<តាមវិធាន៨៧(៤)>នោះ គាត់មិនអាចបន្ទោស

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងខ្សែបកប្រែ និងខ្សែបកប្រែបន្ត។*

យើងទេ <ក្នុងការមើលទៅលើធាតុផ្សំថ្មី> នៅពេលដែលមានសាក្សីថ្មីមកនោះ។ យើង<>អត់មានមធ្យោបាយអីដើម្បីឲ្យដឹងមុនថាតើសាក្សីថ្មីណានឹងមកនោះទេ។ អ៊ីចឹងហើយបានជាវាពិបាកសម្រាប់យើង។ ហើយចំពោះដើមបណ្ដឹងរដ្ឋប្បវេណីនេះ ខ្ញុំមើលក្នុងពាក្យសុំតាំងខ្លួនរបស់គាត់នោះ ដូចជាមិនមាននិយាយអំពីមន្ទីរសន្តិសុខភ្នំក្រោលទេ។ <ឈ្មោះត្រឹមត្រូវតែមួយគាត់ ដែលបានបញ្ជាក់>នៅក្នុងនុំងគឺ អ៊ុល <ពឿ> ហើយដែលភ្នំក្រោលនេះ អត់មានឃើញទេ នៅក្នុងឯកសាររបស់គាត់។

ហើយចំពោះអ្វីផ្សេងទៀតនោះ ខ្ញុំសូមផ្អែកទៅលើការឆ្លើយតបរបស់ខ្ញុំអម្បាញ់មិញនេះ <ប៉ុន្តែសូមកុំរិះគន់ខ្ញុំចំពោះការធ្វើប្រតិកម្មនឹងវិធាន ៨៧(៤)នេះ>។ អ៊ីចឹងនៅពេលដែលមានការដាក់ភ័ស្តុតាងថ្មីនោះ <ជាការពិត គឺជាឱកាសសម្រាប់>មេធាវីការពារក្តីត្រូវតែរកភ័ស្តុតាងថ្មី<ដែរ> ដើម្បីមកឆ្លើយតប<>។ <>

**ប្រធានអង្គជំនុំះ**

យ៉ាងម៉េចទៅ មានអីត្រូវចង់និយាយចុងក្រោយទេ តំណាងសហព្រះរាជអាជ្ញាអន្តរជាតិ?

បាទ មិនមានអីទេ គឺកិច្ចពិភាក្សាស្តាប់សារណាភាគីលើសំណើសុំរបស់សហព្រះរាជអាជ្ញាសុំឲ្យអង្គជំនុំជម្រះសាលាដំបូងកោះហៅដើមបណ្តឹងរដ្ឋប្បវេណី សាក្សីបន្ថែមចំនួនពីររូប ដែលមានរហស្សនាម 2-TCCP-1016 និង 2-TCW-1017 បន្ថែមលើ ឬជំនួសសាក្សីមួយចំនួនដែលបានទទួលមរណភាពពាក់ព័ន្ធនឹងអង្គហេតុមន្ទីរសន្តិសុខភ្នំក្រោលបានចប់ហើយ។

[០៩:៤១:៤៦]

ហើយអង្គជំនុំជម្រះ ក៏សូមថ្លែងអំណរគុណដល់មតិយោបល់របស់ភាគីដែលបានលើកឡើងនូវសារណាផ្ទាល់មាត់លើសំណើនេះ ហើយដើម្បីជាមូលដ្ឋានអង្គជំនុំជម្រះយកទៅពិភាក្សាពិចារណាសម្រេចលើសំណើនេះ ដើម្បីចេញសេចក្តីសម្រេចបានឆាប់ៗក្នុងរយៈពេលខ្លីខាងមុខនេះ ដើម្បីធ្វើឲ្យទាន់នៅក្នុងអំឡុងពេលនៃដំណើរការសវនាការស្តាប់សក្ខីកម្មសាក្សី ដើមបណ្តឹងរដ្ឋប្បវេណីពាក់ព័ន្ធអង្គហេតុនេះ។

ជាបន្តទៅនេះ អង្គជំនុំជម្រះចាប់ផ្តើមធ្វើសវនាការស្តាប់សក្ខីកម្មសាក្សីដែលមានរហស្សនាម 2-TCW-900 តាមរយៈប្រព័ន្ធសោតទស្សន៍ពីខេត្តឧត្តរមានជ័យ។ ហើយមុននឹងចាប់ផ្តើមស្តាប់សក្ខីកម្មសាក្សីរូបនេះ អង្គជំនុំជម្រះកត់សម្គាល់ថា សាក្សីរូបនេះ ត្រូវបានស្តាប់ចម្លើយនៅក្នុងកិច្ចស៊ើបអង្កេតដែលកំពុងដំណើរការនៅក្នុងសំណុំរឿងផ្សេង។ ដូច្នេះអង្គជំនុំជម្រះបាន ដូចអង្គជំនុំជម្រះបានជូនដំណឹង

ដល់ភាគីហើយនៅក្នុងអនុស្សរណៈរបស់ខ្លួនលេខឯកសារ E29/478/2 កថាខណ្ឌ៩ ថាសហចៅក្រមស៊ើបអង្កេតអន្តរជាតិបានកំណត់សាក្សីរូបនេះ ស្ថិតនៅក្នុងក្រុម “ក” នៃក្រុមទាំងបីប្រភេទ នៅក្នុងអនុស្សរណៈរបស់ខ្លួន (សូមមើលឯកសារ E19/35 -- E319/35)។ ហើយបានស្នើថា សាក្សីរូបនេះគួរប្រើរហស្សនាមក្នុងគោលបំណងការពារនូវភាពសម្ងាត់នៃកិច្ចដំណើរការស៊ើបអង្កេត និង ការពារសុវត្ថិភាពដល់សាក្សីផងដែរ។ អង្គជំនុំជម្រះយល់ឃើញថា វិធានការដែលមានកម្រិតបែបនេះ គឺត្រឹមត្រូវ សមស្រប តាមច្បាប់នៅក្នុងករណីបែបនេះ។ ហើយការបង្គាប់នេះ គឺត្រូវធ្វើឲ្យមានតុល្យភាពគ្នារវាងតម្រូវការនៃសាធារណភាពនៃសវនាការ ជាមួយនឹងការការពារសុចរិតភាពនៃការងារស៊ើបអង្កេត។ ហើយអង្គជំនុំជម្រះក៏សូមរំឭកដល់ភាគីដែរថា ឲ្យគោរពឲ្យបានខ្ជាប់ខ្ជួននូវសេចក្តីណែនាំនៅក្នុងឯកសារ E319/7 ក្នុងការប្រើប្រាស់ឯកសារដាក់បង្ហាញពីសំណុំរឿង ០០៣ និង ០០៤។

តទៅនេះ សូមជម្រាបសួរលោក ញ៉ែម សំណាង បុគ្គលិកអង្គភាពគាំពារសាក្សី និងអ្នកជំនាញ តើលោកបានសម្របសម្រួលតាមតាមរយៈប្រព័ន្ធសោតទស្សន៍ ពីកន្លែងសាក្សីត្រូវផ្តល់សក្ខីកម្មជាមួយអង្គជំនុំជម្រះបានរៀបរយហើយឬនៅ? ហើយសាក្សីបានត្រៀមខ្លួនហើយនៅលោក សំណាង?

[០៩:៤៤:២២]

**លោក ញ៉ែម សំណាង៖**

បាទ លោកប្រធាន បានរៀបរួចអស់ហើយ។ សាក្សីបានត្រៀមខ្លួនរួចជាស្រេចហើយជាមួយនឹងមេធាវីផ្តល់ប្រឹក្សា លោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណលោក សំណាង។ លោកសាក្សីនៅក្នុងកិច្ចដំណើរការសវនាការនៅចំពោះមុខអង្គជំនុំជម្រះ តាមសំណើរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ គឺយើងបានប្រើប្រាស់តែរហស្សនាមរបស់លោកទេ។ ហើយលោកសាក្សីមានរហស្សនាម 2-TCW-900 ហើយជាទូទៅភាគី និងតែងតែប្រើប្រាស់ហៅលោកក្នុងនាមជាសាក្សីប៉ុណ្ណោះ។ អ៊ីចឹងគឺសូមលោកយល់ថា អង្គជំនុំជម្រះនឹងមិនអនុញ្ញាតភាគីពាក់ព័ន្ធរួមទាំងអង្គជំនុំជម្រះខ្លួនឯងប្រើនាមត្រកូល និងនាមខ្លួនរបស់លោកជាសាធារណៈនៅក្នុងសវនាការនេះទេ។

**ការតាំងសំណួរដោយចៅក្រម**

**សួរដោយប្រធានអង្គជំនុំ៖**

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**ស៖** ហើយលោកសាក្សី តទៅនេះអង្គជំនុំជម្រះសូមបញ្ជាក់លើអត្តសញ្ញាណមួយចំនួន ដែលមាននៅក្នុងឯកសារ E3/5605 ដែលមានលេខ ERN ភាសាខ្មែរ 00484143 ហើយនិង ERN ជាភាសាអង់គ្លេស 00488704 និង ERN ជាភាសាបារាំង 00488704<*(ស៊ីក)*>។ ហើយលោកមេធាវី ម៉ម រិទ្ធា មេធាវីប្រឹក្សាសាក្សីសូមផ្តល់ឯកសារ ទំព័រនៃឯកសារ E3/5605 ដែលក្រឡាបញ្ជីបានរៀបចំជូនប្រគល់ជូនសាក្សីពិនិត្យ។ ហើយសូមឱ្យសាក្សីពិនិត្យលើចំណុចដែលមាន*ហាយឡាយ* ពាក់ព័ន្ធជាមួយនឹង ឈ្មោះ ថ្ងៃខែឆ្នាំកំណើត ទីកន្លែងកំណើត ហើយមុខរបរ ទីលំនៅបច្ចុប្បន្ន ហើយនិងឪពុកម្តាយ ប្រពន្ធ ហើយនិងកូនតែប៉ុណ្ណោះ អង្គជំនុំជម្រះចង់បញ្ជាក់បញ្ហាហ្នឹង តើត្រឹមត្រូវដែរឬទេ? សូមពិនិត្យមើល។

**2-TCW-900៖**

**ឆ៖** បាទ ត្រឹមត្រូវហើយ។

[០៩:៤៦:៤៨]

**ស៖** យ៉ាងម៉េចទៅលោកសាក្សី បានពិនិត្យហើយឬនៅ តើចំណុចមួយចំនួនដែលយើងបានរៀបរាប់អម្បាញ់មិញនេះ ជាចំណុចដែលបញ្ជាក់អំពីអត្តសញ្ញាណរបស់លោក មាននាមត្រកូល នាមខ្លួន ថ្ងៃខែឆ្នាំកំណើត ភូមិកំណើត សញ្ជាតិ មុខរបរ ឈ្មោះឪពុកម្តាយ ទីលំនៅបច្ចុប្បន្ន ឈ្មោះប្រពន្ធហើយ និងកូន។ តើលោកពិនិត្យមើល តើត្រឹមត្រូវដែរឬទេ ឬក៏មានចំណុចណាខុសពីការពិតនៃប្រវត្តិរូបរបស់លោក?

**ឆ៖** សូមគោរពលោកប្រធាន ខ្ញុំបានពិនិត្យខ្លឹមសារនៅក្នុងឯកសារ គឺត្រឹមត្រូវតាមឈ្មោះខ្ញុំ ឪពុកម្តាយខ្ញុំ និងប្រពន្ធ ត្រឹមត្រូវ។

**ស៖** បាទ អរគុណ។ ហើយលោកសាក្សីតាមរបាយការណ៍របស់ក្រឡាបញ្ជីសវនាការអំមិញនេះ ថាតាមសមត្ថភាពដែលលោកអាចដឹង គឺលោកមិនមានជាប់ចំណងញាតិលោហិត ឬក៏ញាតិពន្ធជាមួយនឹងជនជាប់ចោទទាំងពីររូប លោកនួន ជា និងលោកខៀវ សំផន និងបុគ្គលទាំងឡាយដែលត្រូវបានទទួលយកជាភាគីដើមបណ្តឹងរដ្ឋប្បវេណី នៅក្នុងរឿងក្តីនេះទេ តើត្រឹមត្រូវដែរឬទេ របាយការណ៍នេះ?

[០៩:៤៨:០៩]

**ឆ៖** បាទ ត្រឹមត្រូវ។

**ស៖** បាទ អរគុណ។ ហើយក្រឡាបញ្ជីក៏បានធ្វើរបាយការណ៍ថា លោកបានធ្វើសម្បថតាម

ជំនឿសាសនា មុននឹងមកកាន់កន្លែងផ្តល់សក្ខីកម្មតាមប្រព័ន្ធសោតទស្សន៍ទីនោះ តើលោក -- តើរបាយការណ៍នេះ ត្រឹមត្រូវដែរឬទេ? តើលោកបានធ្វើសម្បថហើយឬនៅ?

**ឆ៖** បាទ ខ្ញុំបានធ្វើសម្បថហើយៗ ត្រឹមត្រូវតាមការ របាយការណ៍។

**ស៖** អរគុណលោកសាក្សី។ ជាបន្តទៅនេះយើងប្រាប់អំពីសិទ្ធិនិងករណីយកិច្ច ក្នុងឋានៈលោកជាសាក្សី នៅក្នុងកិច្ចដំណើរការសវនាការចំពោះមុខអង្គជំនុំជម្រះ។ អំពីសិទ្ធិលោកសាក្សី ក្នុងឋានៈជាសាក្សីនៅក្នុងកិច្ចដំណើរការសវនាការចំពោះមុខអង្គជំនុំជម្រះនេះ លោកអាចបដិសេធក្នុងការឆ្លើយតបទៅនឹងសំណួរ ឬការសុំឱ្យលោកធ្វើអត្ថាធិប្បាយរៀបរាប់ណាមួយ ដែលនាំឱ្យដាក់ពិរុទ្ធភាពលើខ្លួនឯង សិទ្ធិមិនធ្វើសក្ខីកម្មប្រឆាំងនឹងខ្លួនឯង។

អំពីករណីយកិច្ចលោកសាក្សី ក្នុងឋានៈជាសាក្សី លោកត្រូវតែឆ្លើយតបរាល់សំណួរទាំងឡាយដែលភាគី ឬចៅក្រមនៃអង្គជំនុំជម្រះសួរចំពោះលោក លើកលែងតែសំណួរណា ដែលនាំឱ្យចម្លើយតប ឬការធ្វើអត្ថាធិប្បាយរៀបរាប់របស់លោក នាំឱ្យដាក់ពិរុទ្ធភាពលើខ្លួនឯង ដូចយើងប្រាប់អំពីសិទ្ធិរួចហើយអម្បាញ់មិញនេះ។

[០៩:៤៩:៣០]

ហើយក្នុងឋានៈជាសាក្សី លោកត្រូវតែឆ្លើយតែការណ៍ណាដែលពិត ដែលលោកបានដឹង បានឮ បានឃើញ បានចងចាំ ឬក៏ធ្លាប់មានបទពិសោធន៍ជួបប្រទះ ឬក៏បានធ្វើការសង្កេតដោយផ្ទាល់នូវព្រឹត្តិហេតុ នូវហេតុការណ៍ទាំងឡាយដែលពាក់ព័ន្ធនឹងសំណួរ ដែលភាគី ឬចៅក្រមនៃអង្គជំនុំជម្រះសួរចំពោះលោក។ តើលោកយល់អំពីសិទ្ធិ និងករណីយកិច្ចក្នុងឋានៈជាសាក្សីដែលត្រូវផ្តល់សក្ខីកម្មជាមួយនឹងអង្គជំនុំជម្រះដែរឬទេ?

**ឆ៖** ខ្ញុំបានអានខ្លឹមសារឯកសារនេះហើយ ក៏យល់ស្រប ហើយនិងទទួលយក។

**ស៖** បាទ អរគុណ។ ហើយលោកសាក្សី តើលោកធ្លាប់ផ្តល់សក្ខីកម្ម ឬក៏ផ្តល់កិច្ចសម្ភាសន៍ជាមួយនឹងអ្នកស៊ើបអង្កេតនៃការិយាល័យសហចៅក្រមស៊ើបអង្កេតដែរឬទេ កន្លងមក? ហើយបើសិនបើធ្វើ ៗប៉ុន្មានដង ធ្វើនៅទីកន្លែងណាខ្លះ?

**ឆ៖** ខ្ញុំធ្លាប់បានធ្វើ តាមខ្ញុំចាំដូចបីដង។ ធ្វើនៅ ភាគច្រើនធ្វើនៅសាលាស្រុកត្រពាំងប្រាសាទ ក្នុងខេត្តឧត្តរមានជ័យ។

**ស៖** បាទ អរគុណ។ ហើយមុននឹងចូលមកផ្តល់សក្ខីកម្មនៅទីនោះ តើលោកបានពិនិត្យមើល

ឬក៏បានអាននូវកំណត់ហេតុ ដែលលោកបានផ្ដល់សក្ខីកម្មកាលពីលើកមុនជាមួយនឹងអ្នកស៊ើបអង្កេត ដើម្បីរំឭកការចងចាំដែរឬទេ?

**ឆ៖** ខ្ញុំបានអានគ្រប់ឯកសារដែលខ្ញុំបានធ្វើការសម្ភាសជាមួយអស់លោកពីមុនៗមក។

[០៩:៥១:០១]

**ស៖** បាទ អរគុណណាស់។ ហើយតាមសមត្ថភាពដែលលោកអាចដឹង និងចងចាំ តើលោកបាន អាចបញ្ជាក់បានដែរទេថា កំណត់ស្ដាប់ចម្លើយដែលលោកបានផ្ដល់សក្ខីកម្មពីមុន ហើយលោកបានអានដើម្បីរំឭកការចងចាំនោះ ពិតជាត្រឹមត្រូវ សមស្រប ស៊ីសង្វាក់គ្នាទៅនឹងកិច្ចសម្ភាសន៍ដែលលោកបានផ្ដល់ជាមួយនឹងអ្នកស៊ើបអង្កេតកាលពីចំនួនបីដង ដែលលោកបានលើកឡើងអម្បាញ់មិញហ្នឹងដែរឬទេ?

**ឆ៖** ខ្ញុំបានអាននូវខ្លឹមសារក្នុងកំណត់ហេតុទាំងអស់ ខ្ញុំឯកភាព ប៉ុន្តែចំណុចដែលខ្ញុំចាប់អារម្មណ៍ គឺអាចមានកន្លែងខ្លះក៏លើស ហើយកន្លែងខ្លះក៏ខ្វះ ពីព្រោះអីការចងចាំរបស់ខ្ញុំវាវែង មានរយៈកាលវែង ដូច្នេះមិនគ្រប់គ្រាន់ពេញលេញ ប៉ុន្តែខ្លឹមសារដែលខ្ញុំបានអាន គឺខ្ញុំយល់ស្របទៅតាមខ្លឹមសារដែលខ្ញុំបានឃើញ ហើយនិងខ្ញុំបានផ្ដល់ជាកំណត់ហេតុ។

**ប្រធានអង្គជំនុំ៖**

បាទអរគុណណាស់។ ហើយក្នុងការស្ដាប់សក្ខីកម្មសាក្សីរូបនេះ យើងបានប្រាប់រួចហើយអំមិញ គឺមានមេធាវីប្រឹក្សាគឺលោក ម៉ម រិទ្ធា ហើយបើឃើញវត្តមានលោក ម៉ម រិទ្ធា នៅជាមួយនឹងសាក្សី គឺមិនចំឡែកទេ ព្រោះមេធាវីប្រឹក្សាសាក្សីត្រូវតែអង្គុយនៅក្បែរសាក្សី ដើម្បីស្ដាប់នូវសំណួរណាដែលមានលក្ខណៈចរិតជាសំណួរ ឬក៏សុំឲ្យធ្វើអត្ថាធិប្បាយដាក់បន្ទុកលើសាក្សីនោះ គឺគាត់នឹងពិភាក្សាថា គាត់ត្រូវឆ្លើយតប ឬក៏មិនឆ្លើយតបទៅនឹងសំណួរ។

ហើយនៅក្នុងការសួរដេញដោលចំពោះសាក្សីរូបនេះ អនុវត្តតាមបទប្បញ្ញត្តិនៃវិធាន៩១ស្ទួននៃវិធានផ្ទៃក្នុង អង្គជំនុំជម្រះសាលាដំបូងផ្ដល់វេទិកាជូនទៅតំណាងសហព្រះរាជអាជ្ញាសួរដេញដោលសាក្សីរូបនេះមុនភាគីដទៃទៀតនៃរឿងក្ដី។ ហើយសហព្រះរាជអាជ្ញា រួមទាំងសហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណីមានរយៈពេលមួយថ្ងៃក្នុងការសួរដេញដោលសាក្សីរូបនេះ។

សូមអញ្ជើញតំណាងសហព្រះរាជអាជ្ញា!

[០៩:៥៣:០០]

**លោក វាំងសង់ វ៉ាយដ៍ ដេស្នាឯល៖**

បាទ សូមអរគុណលោកប្រធាន។ ជម្រាបសួរអស់លោក លោកស្រីចៅក្រម។ ជម្រាបសួរភាគីទាំងអស់ និងសាធារណជន ជម្រាបសួរលោកសាក្សី<2-TCW-900>។

**ការតាំងសំណួរដោយសហព្រះរាជអាជ្ញា**

**សួរដោយលោក វាំងសង់ វ៉ាយដ៍ ដេស្នាឯល៖**

**ស៖** ខ្ញុំនឹងចោទសំណួរ ហើយដោយសារតែយើងធ្វើតាមវីដេអូលីង អ៊ីចឹងខ្ញុំនឹងសួរយឺតៗ ដើម្បីឱ្យលោកយល់សំណួរខ្ញុំឱ្យបានច្បាស់។ ជាបឋមខ្ញុំសូមចោទសំណួរលោកពីរ<>សំណួរទាក់ទងនឹងរយៈពេលមុនឆ្នាំ១៩៧៥ ១៧ មេសា ៧៥។ អ៊ីចឹងខ្ញុំកំណត់រយៈពេលឱ្យលោក គឺពីឆ្នាំ១៩៧០ ដល់៧៥។ តើលោកអាចនិយាយដោយសង្ខេបបានដែរឬទេថា តើលោកចូលទៅក្នុងកងកម្លាំងបដិវត្តន៍នៅពេលណា? ហើយប្រធានផ្ទាល់របស់លោកជាអ្នកណាដែរ?

**2-TCW-900៖**

**ឆ៖** ពីឆ្នាំ៧០ ដល់៧៥ ខ្ញុំចូលបម្រើកងទ័ពឆ្នាំ១៩៧១។ ខ្ញុំចូលដំបូងនៅក្នុងកងវរសេនាធំលេខ៣៩។ មេបញ្ជាការដែលទទួលខុសត្រូវនៅក្នុងវរសេនាធំនេះ ភាគច្រើនមក ខ្មែរមកពីប្រទេសវៀតណាម មកពីហាណូយ ហៅខ្មែរកម្មាភិបាលមកពីហាណូយ។ ហើយតាមខ្ញុំចាំឈ្មោះគាត់មានឈ្មោះ តាចេង និង តាសាត។ រហូតដល់ឥឡូវនេះមិនដឹងថាគាត់ទៅណាទេ ខ្ញុំអត់ដឹងដែរ។ នេះខ្ញុំចូលតាំងពីឆ្នាំ៧០ ដល់៧៥។

[០៩:៥៥:១១]

**ស៖** បាទ សូមអរគុណ។ ពេលដែលលោករង់ចាំ និងឆ្លើយហ្នឹង លោកកុំឆ្ងល់អី កុំបារម្ភអី ពីព្រោះថាអ្វីដែលលោកនិយាយហ្នឹង គឺត្រូវបានបកប្រែទៅជាភាសាអង់គ្លេសហើយ បានបកបន្តមកភាសាបារាំងទៀត។ តើកងវរសេនាធំ៣៩ហ្នឹងមានបញ្ចូលទៅក្នុងកងពលណាដែរឬទេ? ហើយលេខកងពលហ្នឹងលេខអី លេខប៉ុន្មានដែរ? ហើយអ្នកណាជាអ្នកប្រធានកងពលហ្នឹងបាទ?

**ឆ៖** កងពលកងវរសេនាធំលេខ៣៩ហ្នឹង ពីដើមមិនមានចំណុះឱ្យអ្នកណាទេ គេហៅថារបស់មជ្ឈិម ហើយធ្វើការនៅខេត្តកំពង់ធំ នៅជុំវិញភ្នំសន្ទុក ពីព្រោះកាលហ្នឹងសមរភូមិបានចាប់ផ្តើមវ៉ៃប្រតិបត្តិការសឹកចេនឡាទី២ ហើយកងទ័ព លន់ នល់ ហ្នឹងមកផ្តុំគ្នានៅជុំវិញទីរួមខេត្តកំពង់ធំ។ ហើយអង្គភាពហ្នឹងធ្វើប្រតិបត្តិការនៅជុំវិញទីរួមខេត្តកំពង់ធំហ្នឹង ម្តុំភ្នំសន្ទុក ចុះមកក្រោម។

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឱ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**សះ** បាទ សូមអរគុណ។ តើបន្ទាប់ទៀតហ្នឹងលោកនៅក្នុងកងវរសេនាធំ៨២មែនដែរទេ? ហើយនៅក្នុងកងវរសេនាធំហ្នឹង លោកមានតួនាទីអ្វីដែរ?

**ផះ** ក្រោយពីអង្គភាពវរសេនាធំលេខ៣៩ ត្រូវមកនៅបំពេញភារកិច្ចនៅជុំវិញ ហៅពាយ័ព្យភ្នំពេញ មានទីតាំងបោះនៅដើមដំបូងនៅភូមិប៉ាលហាល នៅខាងលិចភ្នំប្រសិទ្ធិ៍។ ហើយដែលឈ្មោះវរសេនាធំលេខ៨២ហ្នឹង ជាវរសេនាធំមួយដែលចំណុះឲ្យកងពល៨០១ ប៉ុន្តែកងពល៨០១ ហ្នឹងមុននឹងដាក់ឈ្មោះ៨០១ហ្នឹង ក្រោយពេលរំដោះ៧៥ហើយទេ បានដាក់ឈ្មោះ៨០១ ពីមុនគេហៅកងពលលេខ១៤ទេ។ កង៣៩ហ្នឹងមកចូលនៅក្នុងវរសេនាធំលេខ៨១, ៨២ហ្នឹង ហើយក្នុងកងពលលេខ១៤ នៅសមរភូមិពាយ័ព្យភ្នំពេញ។

[០៩:៥៨:៣០]

**សះ** អ៊ីចឹងអ្នកណាជាប្រធានកងពលលេខ១៤ ហើយមុននឹងពេលដែលកងពល១៤នេះក្លាយជាកងពល៨០១ក្រោយមកនោះ?

**ផះ** នៅពេលដែលមកដល់សមរភូមិពាយ័ព្យភ្នំពេញមានឈ្មោះ សាន។ ឈ្មោះ សាន ហ្នឹងជាមេបញ្ជាការកងពល១៤ហ្នឹង។ នៅពេលដែលរៀបចំបើកយុទ្ធនាការសមរភូមិ គេហៅថាសមរភូមិ <៩៩០> មានឈ្មោះ ស្វ សារឿន គាត់មកពីផ្នែកខាងត្បូង មកត្នោតពងហ្នឹង មកបានចូលមកនៅជាមួយកងពល១៤ហ្នឹង។ ហើយធ្វើសកម្មភាពវ៉ៃនៅសមរភូមិ៩៩០ នៅខាងជើងអៀងខាងលិចពោធិ៍ចិនតុង។

**សះ** បាទ សូមអរគុណ។ ឥឡូវខ្ញុំចូលនិយាយរយៈពេលក្រោយឆ្នាំ១៩៧៥ ១៧ មេសា ៧៥ ខ្ញុំនឹងនិយាយលឿនជាងនេះបន្តិច។ តើកងពលលេខ១៤របស់លោកមានមុខងារអ្វីដែរ ក្រោយពីដណ្តើមបានទីក្រុងភ្នំពេញ? ហើយកងពលហ្នឹងឈរជើងនៅកន្លែងណាដែរ?

**ផះ** កងពល១៤ ក្រោយពេលរំដោះ ១៧ មេសា កងពលនេះបានមានទីតាំងពង្រាយធ្វើសកម្មភាពការពារភ្នំពេញចាប់ពីរទេះភ្លើង ចំណតរទេះភ្លើង ស្ថានីយរទេះភ្លើងមករហូតមកលិចមក មកម្តុំជិតពោធិ៍ចិនតុងត្រង់ឃ្លាញ បាយ៉ាប ហើយទីបញ្ជាការកងពលបោះនៅស្ពាតអូឡាំពិក។

**សះ** ខ្ញុំមានសំណួរពីរសួរបន្ត។ លោក<បាននិយាយ>អំពីស្ថានីយរថភ្លើង អ៊ីចឹងក្រោយពីរំដោះបានទីក្រុងភ្នំពេញ លោកមានបានចូលរួម ឬក៏ដឹងអំពីកិច្ចប្រជុំរបស់អ្នកដឹកនាំដែលបានប្រព្រឹត្តទៅនៅក្នុងស្ថានីយរថភ្លើងនេះដែរឬទេ?

[១០:០១:៤០]

**ឆ៖** ខ្ញុំមិនបានដឹងទេ កន្លែងដែលគេទៅប្រជុំ កន្លែងណាៗ ខ្ញុំអត់ដឹង។

**ស៖** ទីបញ្ជាការ<របស់លោក> គឺបោះទីតាំងនៅស្ពាតអូឡាំពិក។ អ៊ីចឹងតើកងពលរបស់លោក មានទទួលបន្ទុកក្នុងការរក្សាសន្តិសុខនៅពេលសន្និបាតមួយដែលបានប្រព្រឹត្តឡើង ឬមីទ្ទិងមួយដែលបាន ប្រព្រឹត្តឡើងនៅស្ពាតអូឡាំពិកនៅ<>ឆ្នាំ១៩៧៥ ដែរឬទេ?

**ឆ៖** មានមីទ្ទិងមួយនៅក្នុងស្ពាតអូឡាំពិក កាលនុ៎ងខ្ញុំអត់នៅទេ។ ខ្ញុំទៅស្នាក់នៅផ្លូវទៅឃ្លួញ បាយ៉ាប ពីព្រោះមេកងពលគាត់ឲ្យខ្ញុំនៅចាំហ្នឹង ដោយដំឡើងវិទ្យុទាក់ទងនៅកន្លែងហ្នឹងសម្រាប់ ទាក់ទងតាមអង្គភាពខាងក្រោមៗ។ មានតែពេលយប់ទេ ដែលខ្ញុំទៅ ដែលគេលេងសិល្បៈអីនៅនឹងស្ពាត ហ្នឹង។ ហើយខ្ញុំក៏អត់បានចូលមើលផង គេអត់ឲ្យចូល។

**ស៖** ខ្ញុំសូមអានអ្វីដែលលោកបាននិយាយ លោកបានឆ្លើយនៅក្នុងកំណត់ហេតុស្តាប់ចម្លើយ របស់លោក ឯកសារ <E3/9734> ចម្លើយទី២របស់លោក។ លោកឆ្លើយដូចតទៅនេះ៖ “ក្រោយពីឆ្នាំ ១៩៧៥ ខ្ញុំបានជួប ស៊ូ ម៉េត នៅក្នុងពេលមីទ្ទិងនៅស្ពាតអូឡាំពិក នៅពេលនោះខ្ញុំទទួលបន្ទុកខាង<វិទ្យុ ទាក់ទង>នៅកងពល១៤ ដែលមាន តាសារឿន ជាមេបញ្ជាការ។ ហើយក្រោយមកកងពលហ្នឹងដូរ ឈ្មោះទៅជាកងពល៨០១។ សុន សេន គាត់ប្រជុំជាញឹកញាប់នៅមន្ទីររបស់ តាសារឿន។” តើលោក មានបានចូលរួមក្នុងមីទ្ទិងណាមួយនៅស្ពាតអូឡាំពិកដែរឬទេ? ហើយបើសិនជាលោកបានចូលរួម សូម លោកពិពណ៌នាឲ្យបានលម្អិតបន្តិចអំពីកិច្ចមីទ្ទិងនេះ?

[១០:០៥:១១]

**ឆ៖** ខ្ញុំនៅធ្វើការនៅក្នុងមន្ទីរកងពល៨០១ ពីមុនគេហៅ១៤ ក្រោយមកផ្លាស់មកដាក់៨០១ ខ្ញុំ មិនដែលចូលរួម ៗធ្វើមីទ្ទិងណាមួយដែលគេប្រព្រឹត្តធ្វើឡើងនៅស្ពាតអូឡាំពិក ឬក៏ការប្រជុំណាមួយ ដែលនៅក្នុងរង្វង់ស្ពាតអូឡាំពិក ខ្ញុំមិនដែលធ្វើទេ។ ហើយខ្ញុំមិនដែលបានចូលរួមទេ ពីព្រោះពេលហ្នឹងខ្ញុំ ជាអ្នកកាន់វិទ្យុទាក់ទង ហើយតួនាទីខ្ញុំមានតួនាទីតែរៀបចំកន្លែងកៅអីតុ ទឹកតែប៉ុណ្ណឹងទេ។ ហើយរឿង ការងារប្រជុំអី ខ្ញុំអត់បានដឹង។ ខ្ញុំដឹងថាមានគេមកប្រជុំ អ្នកតាមកងពលមួយៗមកប្រជុំនៅកន្លែងហ្នឹង ហើយតួនាទីខ្ញុំដូចបានជម្រាបលោកពីខាងដើមថា ខ្ញុំមានតួនាទីតែរៀបចំកន្លែងប្រជុំជាមួយមិត្តភក្តិខ្ញុំនៅ ក្នុងមន្ទីរហ្នឹង។

**ស៖** តើលោកមានចាំពេលដែលកងពលលេខ១៤ បានដូរឈ្មោះទៅកងពល៨០១ ដែរឬទេ? តើ នៅពេលណាដែរ ខែណាដែរនៅក្នុងឆ្នាំ១៩៧៥ ហ្នឹងដែលកងពលហ្នឹងដូរទៅកងពល៨០១?

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**ឆ៖** តាមខ្ញុំចាំ ការដូរឈ្មោះកងពលពី១៤មកដាក់៨០១ គឺមុនពេលដែលកងពលនេះទៅបំពេញភារកិច្ចនៅខេត្តរតនគិរី។ ហើយក្នុងរវាង តាមខ្ញុំប៉ាន់ប្រមាណប្រហែលជាខែ១០, ១១ ឬក៏ខែ១០ ឬក៏ខែ ១១ ពីព្រោះពេលហ្នឹងធាតុអាកាសត្រជាក់បន្តិចហើយ។

**សៈ** ពេលលោកនិយាយពីខែតុលា, វិច្ឆិកា ឆ្នាំ១៩៧៥ ហ្នឹងគឺលោកចង់និយាយថានៅពេលហ្នឹងហើយឬ ដែលលោកត្រូវបានបញ្ជូនទៅរតនគិរីជាមួយនឹងកងពល៨០១ ឬក៏ពេលក្រោយ ពេលហ្នឹងទេ?

[១០:០៦:៥១]

**ឆ៖** នៅក្រោយពេលដឹង ខ្ញុំដឹងដំណឹងពីថាផ្លាស់ឈ្មោះពី១៤ មក៨០១ គឺពេលហ្នឹងកងពលហ្នឹង ទាំងមូលត្រូវរៀបចំធ្វើដំណើរទៅៗខេត្តរតនគិរីហើយ។ ហើយទៅដំបូងមានកងទ័ពមួយចំនួនមិនជាច្រើនទេទៅនាំមុខមុន។ ហើយទីបញ្ជាការកងពលទៅស្រាលទេ ស្រាលអីគឺយកវិទ្យុទាក់ទង ពីដើមប្រើវិទ្យុរបស់ជយភណ្ឌរបស់អាមេរិកាំងហ្នឹង ប្រើវិទ្យុប្រភេទកូឡាំង។ កូឡាំងហ្នឹងនិយាយបានពីក្រចេះមក ឬក៏ពីរតនគិរីទាក់ទងមកភ្នំពេញឮបាន។ ហើយក្រៅពីនេះទៀត មានវិទ្យុC46 និងវិទ្យុC25 សម្រាប់ទាក់ទងជាមួយអង្គភាពតាមកង។ ហើយខ្ញុំបានទៅមុនគេ ទៅជាមួយ តាសាន កងពលហ្នឹងទៅ។ ទៅដល់ខ្ញុំស្នាក់នៅភូមិឫស្សីចាកក្នុងខេត្តក្រចេះ។

**សៈ** ក្នុងចំណោមការងារនៃកងពល៨០១ នៅភូមិភាគ<>ព្លសាន<> តើមានមុខងារណាមួយដែលពាក់ព័ន្ធទៅនឹងការងារនៅតាមព្រំប្រទល់<ជាមួយវៀតណាម>ដែរឬទេ?

**ឆ៖** កងពលនេះមានតួនាទីទៅឈរជើងនៅជាប់ព្រំប្រទល់ហ្នឹងតែម្ដង តាំងពីមុំ មិនមែនមុំបីទេ គេហៅកន្ទុយនាគ ព្រំប្រទល់ឡាវ ហើយនិងវៀតណាម-កម្ពុជាហ្នឹង ហើយនិងព្រំប្រទល់ជាមួយវៀត-ណាម នៅម្ដុំផ្លូវលេខ១៩ អូរយ៉ាដាវ។

**សៈ** នៅចុងឆ្នាំ១៩៧៥ហ្នឹង រហូតដល់១៩៧៩ហ្នឹង លោកអាចជម្រាបជូនតុលាការបានដែរឬទេថា រចនាសម្ព័ន្ធ<រដ្ឋបាលរបស់ភូមិភាគព្លសាន>នុំងយ៉ាងណាដែរ? ហើយអ្នកណា<ខ្លះ>ជា<គណៈគ្រប់គ្រងភូមិភាគព្លសាន>? <តើមេដឹកនាំ>នៅភូមិភាគព្លសានហ្នឹង<មានការផ្លាស់ប្ដូរទេ នៅពេលបន្តបន្ទាប់មកទៀតនោះ>?

[១០:០៩:៥៦]

**ឆ៖** ខ្ញុំមិនដឹងទូលាយរហូតដល់មួយភូមិភាគព្លសានទេ។ នៅពេលនោះខ្ញុំដឹងតែក្នុងក្របខ័ណ្ឌកងពល៨០១។ រចនាសម្ព័ន្ធរបស់កងពល៨០១ មានកងវរសេនាធំបោះនៅតាមចំណុចនីមួយៗ ដូចនៅ

ខាងស្រុកសៀមប៉ាង មានវរសេនាធំមួយ ហើយនៅភ្នំ នៅកន្ទុយនាគហ្នឹងមានវរសេនាធំមួយរួមជាមួយកងពិសេសរបស់កងពល។ ហើយមានវរសេនាធំមួយទៀត បោះនៅបរកែវ ធ្វើសកម្មភាពការពារព្រំប្រទល់នៅម៉ុំអូរយ៉ាដាវ ហើយតាមទន្លេសេសានខាងលើ ម៉ុផ្លូវលំខូ គេហៅថាផ្លូវលំខូ ផ្លូវលំខូ និយាយរួមឥឡូវគេហៅផ្លូវហូជីមិញ។

**ស៖** ខ្ញុំត្រឡប់មកសំណួរមុន អម្បាញ់មិញនេះ ខ្ញុំសួរលោកថាតើប្រធានភូមិភាគព្ភ៌សានហ្នឹងជាអ្នកណា? អ្នកណាជាប្រធានភូមិភាគ ពេលដែលលោកទៅឈរជើងនៅទីនោះ? ហើយមន្ទីរភូមិភាគព្ភ៌សានហ្នឹង មានទីតាំងនៅកន្លែងណាដែរ?

**ឆ៖** ខ្ញុំអត់ដែលដឹងមន្ទីរភូមិភាគព្ភ៌សានបោះនៅទីណាទេ ប៉ុន្តែកន្លែងដែលខ្ញុំទៅបោះដំបូងនៅបានលុង ខ្ញុំទៅដល់ភ្លាមបោះទីតាំងនៅបានលុង នៅច្រមុះភ្នំមួយខាងត្បូងភ្នំស្វាយបន្ទិច។ ហើយកន្លែងហ្នឹងជាទីតាំងរបស់ទាហាន លន់ នល់។ នៅកន្លែងហ្នឹង នៅពេលដែលពួកខ្ញុំទៅដល់ហ្នឹង ឃើញតែសម្បកគ្រាប់ និងគ្រាប់ដែលមិនទាន់ផ្ទុះច្រើន។ ឯមន្ទីរមួយដែលនៅក្បែរអូរកន្ទ្បេង គេហៅថាមន្ទីរតំបន់មន្ទីរតំបន់ ខ្ញុំអត់ដែលទៅដល់ចូលទេ ឮតែតាមគេនិយាយថា មន្ទីរតំបន់ៗ នៅខាងកើតអូរកន្ទ្បេងហ្នឹង។ ហើយក្រៅពីហ្នឹង ខ្ញុំអត់ដឹងថាមន្ទីរភូមិភាគព្ភ៌សានហ្នឹងបោះនៅកន្លែងណា។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ អរគុណលោកសាក្សី។ ឥឡូវនេះដល់ពេលសម្រាកហើយ ហើយលោកសាក្សីរួមទាំងមេធាវីប្រឹក្សាសាក្សីសម្រាក២០នាទី ចាប់ពីពេលនេះតទៅរហូតដល់ម៉ោងដប់កន្លះ សូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការ។ ដូច្នេះលោកអាចសម្រាកបាន ហើយម៉ោង មុនម៉ោងដប់កន្លះ លោកចូលមកកាន់កន្លែងផ្ដល់សក្ខីកម្មនៅទីនោះវិញណ៎ា។

ឥឡូវនេះដល់ពេលសម្រាកហើយ អង្គជំនុំជម្រះប្រកាសសម្រាកចាប់ពីពេលនេះតទៅរហូតដល់ម៉ោងដប់កន្លះ សូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការ។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១០:១៣ នាទី ដល់ម៉ោង ១០:៣៣ នាទី)*

[១០:៣៣:០៣]

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ សួរស្តីលោកសាក្សី តើលោកបានត្រៀមខ្លួនរួចហើយឬនៅ?

**2-TCW-900៖**

បាទ ហើយៗលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ហើយបន្តទៅនេះអង្គជំនុំជម្រះផ្តល់វេទិកាជូនទៅតំណាងសហព្រះរាជអាជ្ញាអន្តរជាតិដើម្បីបន្តការតាំងសំណួរដេញដោលចំពោះសាក្សី។

**លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

សូមអរគុណលោកប្រធាន។

**សួរដោយលោក វ៉ាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

**ស៖** លោកសាក្សី ដោយសារតែលោកផ្តល់សក្ខីកម្មតាមរយៈវីដេអូលីង សូមឲ្យលោកស្តាប់សំណួរឲ្យច្បាស់ ហើយសូមឆ្លើយឲ្យច្បាស់ទៅនឹងសំណួររបស់ខ្ញុំ។ សូមលោកកុំងាកចេញពីអ្វីដែលខ្ញុំសួរ។ ពាក់ព័ន្ធទៅនឹងរចនាសម្ព័ន្ធកងពល៨០១ លោកបាននិយាយអំពី តាសារឿន ជាមេបញ្ជាការ ហើយលោកបាននិយាយអំពី តាសាន។ ដូច្នេះខ្ញុំចង់ដឹងថា តើអ្នកណាជាមេផ្ទាល់របស់ តាសារឿន?

[១០:៣៤:៥២]

**2-TCW-900៖**

**ឆ៖** នៅកងពលនោះ ខ្ញុំមិនដឹងថាអ្នកណាជាមេផ្ទាល់របស់គាត់ទៀតទេ។ ខ្ញុំដឹងតែត្រឹម តាសារឿន ហើយនិង តាសាន ហ្នឹង។ ហើយគាត់ទំនាក់ទំនងទៅខាងលើៗ ខ្ញុំអត់បានដឹងថា យ៉ាងម៉េចៗទេ។

**ស៖** ខ្ញុំមិនមែននិយាយអំពីមេនៅកងពល៨០១ទេ។ ខ្ញុំដឹងហើយថា គាត់ជាមេបញ្ជាការកងពល៨០១។ អ៊ីចឹងក្នុងកងពលហ្នឹង គាត់ធំជាងគេហើយ ក៏ប៉ុន្តែខ្ញុំចង់ដឹងថា មេដែលនៅកន្លែងផ្សេងនោះ ឧទាហរណ៍ដូចនៅសេនាធិការ នៅភ្នំពេញនោះ តើអ្នកណាជាមេរបស់ តាសារឿន ហ្នឹង?

**ឆ៖** ខ្ញុំបានដឹង គឺគាត់ធ្វើរបាយការណ៍តាមរយៈវិទ្យុទាក់ទងច្រើនតែទៅកន្លែងសេនាធិការភ្នំពេញ ហើយទៅភ្នំពេញសំដៅទៅលើកន្លែង សុន សេន ជាអ្នកទទួលព័ត៌មានពីវិទ្យុទាក់ទង។

**សៈ** ក្រៅពីការទាក់ទងគ្នាតាមវិទ្យុទាក់ទង តើ តាសារឿន ទៅប្រជុំញឹកញាប់ទេ នៅភ្នំពេញ?

**ឆ៖** កាលមកដល់រតនគិរីភ្លាម ប្រហែលជាមួយខែ គាត់ត្រូវឡើងទៅភ្នំពេញ ដោយសារពេលហ្នឹងផ្លូវលំបាកធ្វើដំណើរ ទៅម្តងៗប្រើពេលយូរដែរ បានជាមួយអាទិត្យ ឬក៏លើសហ្នឹង ពីព្រោះទៅពីរតនគិរីទៅដល់ក្រចេះ ឡានជូនកាលដេកផ្លូវមួយយប់ ជួនកាលដេកផ្លូវពីរយប់។ ហើយទម្រាំពីក្រចេះទៅភ្នំពេញ មិនប្រើឡានទេ ប្រើកាណូត។ អ៊ីចឹងពេលវេលាដែលគាត់ទៅយូរដែរ។

[១០:៣៧:៣២]

**សៈ** លោកទទួលបន្ទុកខាងវិទ្យុទាក់ទងនៅក្នុងកងពល៨០១ ដូច្នេះលោកដឹងទេ ឬក៏ តាសារឿន មានធ្លាប់ប្រាប់លោកទេថា គាត់ត្រូវសួរយោបល់ពីសេនាធិការ ឬក៏មជ្ឈិមបក្សសិនមុននឹងគាត់ធ្វើការសម្រេចសំខាន់ៗពាក់ព័ន្ធទៅនឹងបញ្ហាសន្តិសុខនៅក្នុងភូមិភាគរបស់គាត់នោះ? ឧទាហរណ៍ដូចជា បញ្ហាខ្មាំងផ្ទៃក្នុង ខ្មាំងខាងក្រៅអីនោះ តើលោកដឹងទេថា គាត់ត្រូវតែសួរយោបល់ពីសេនាធិការ ឬមជ្ឈិមបក្សសិនមុននឹងសម្រេចនោះ?

**ឆ៖** ជាធម្មតានៅរបាយការណ៍ ៗរបស់កងពលទៅកន្លែងសេនាធិការ គាត់សរសេរជាលិខិតអ៊ីចឹង ហើយខ្ញុំបានបកប្រែធ្វើសារលិខិតតាមអក្សរសម្ងាត់។ ហើយនៅក្នុងភាសាអក្សរដែលមិនទាន់បានទៅជាភាសាអក្សរសម្ងាត់ ខ្ញុំតែងតែជួបប្រទះឃើញគាត់សូមយោបល់។ ហើយរបាយការណ៍សមរភូមិនៅតាមព្រំដែន ហើយនិងរបាយការណ៍ផ្ទៃក្នុងនៅក្នុងកងពល ឬក៏អង្គភាពក្នុងកងពលទាំងមូល ភាគច្រើនខ្ញុំឃើញ ៗគាត់សរសេរ ហើយសូមយោបល់ ៗពីខាងថ្នាក់លើ។

**សៈ** លោកថា គាត់សូមយោបល់ពីថ្នាក់លើ ហើយក្រោយមកគាត់ចាំបញ្ហាពីថ្នាក់លើមក <អ៊ីចឹង>គាត់<ចង់បានអ្វី? ចង់បានការណែនាំ ឬក៏>គ្រាន់តែ<ចង់បានអនុសាសន៍ នៅពេលដែលគាត់ស្នើសុំ>ពិគ្រោះយោបល់<>ពីថ្នាក់លើនោះ?

**ឆ៖** ជាធម្មតាការសូមយោបល់ពីថ្នាក់លើក្នុងករណីដូចជា សមរភូមិជួបប្រទះបញ្ហាអីស្មុគស្មាញ ដូចជា ថ្នាំពេទ្យ អ្នកជំងឺ ឬក៏មានស្ថានការណ៍នៅតាមព្រំដែន។ ឯរឿងអីផ្សេងៗទៀត គាត់សុំយោបល់ពីខាងលើ។

[១០:៤០:២៤]

**ស៖** ចុះបញ្ហាក្នុង ខ្មាំងផ្ទៃក្នុង ខ្មាំងស៊ីរូងផ្ទៃក្នុង ក្នុងកងកងពល ឬក៏ខ្មាំងខាងក្រៅ ដូចជាខ្មាំងយួនអីជាដើមនេះ គាត់មានសុំសេចក្ដីណែនាំពីថ្នាក់លើទេ?

**ឆ៖** ខ្ញុំបានជួបប្រទះបញ្ហាមួយ ហើយខ្ញុំបានយកលិខិតរបស់ តាសារឿន ហ្នឹងដោយផ្ទាល់តែម្ដង ដាក់ក្នុងស្រោមសំបុត្រ ហើយឲ្យខ្ញុំយកទៅភ្នំពេញ មានគ្នាបី ទៅប្រគល់ឲ្យកន្លែងសេនាធិការផ្ទាល់។ ហើយខ្ញុំធ្វើដំណើរពីរតនគិរីទៅ ជិះម៉ូតូឌុបគ្នា។ គ្នាបីនាក់ ដេកកណ្ដាលព្រៃហ្នឹងមួយយប់ ហើយបានទៅដល់ក្រចេះ។ ស្អែកឡើងបានខ្ញុំឆ្លងពីក្រចេះទៅត្រើយម្ខាង ខាងជើងនេះជិះម៉ូតូរហូតមួយថ្ងៃពេញ ហើយយកសំបុត្រហ្នឹងទៅឲ្យកន្លែងសេនាធិការ។ ហើយខ្លឹមសារសំបុត្រ ខ្ញុំអត់បានឃើញទេ ពីព្រោះសំបុត្រហ្នឹងបិទស្រោមជិត។ ខ្ញុំមានតួនាទីតែនាំសំបុត្រទៅឲ្យសេនាធិការ ហើយនៅក្នុងសំបុត្រហ្នឹងដាក់ចារថា "គោរពជូន បងខៀវ"។

**ស៖** បាទ សូមអរគុណ។ នៅក្នុងកាលៈទេសៈបែបណា ដែលលោកត្រូវយកសំបុត្រទៅនោះ? ដោយហេតុអីបានជាមិនបញ្ជូនតាមទូរលេខ បានជាកាន់សំបុត្រទៅដោយផ្ទាល់ដៃនោះ? សំបុត្រហ្នឹងវាសម្ងាត់ខ្លាំង ឬក៏យ៉ាងម៉េច? ហើយ តាសារឿន ហ្នឹង<មាន>ប្រាប់លោក<ទេ>ថា សំបុត្រនេះសំខាន់ណាស់ត្រូវតែប្រគល់ផ្ទាល់ដៃ ឬក៏យ៉ាងម៉េច បានមិនផ្ញើតាមទូរលេខនោះ?

**ឆ៖** តាមខ្ញុំដឹងខ្លះៗអំពីកិច្ចការរបស់កម្ពុជាប្រជាធិបតេយ្យជំនាន់នុ៎ងគឺ កន្លែងខ្លះត្រូវការនិយាយជាសម្ងាត់ ហើយមិនអាចនិយាយចំហ តាមរយៈ សូម្បីតែខ្ញុំជាអ្នកបកប្រែធ្វើអក្សរសម្ងាត់ ឆ្លងឆ្លើយតាមរយៈផ្ញើសារទៅសេនាធិការ ក៏អត់ដឹងដែរ។ អ៊ីចឹងខ្ញុំគិតថា សំបុត្រដែលខ្ញុំយកទៅនេះ ជាសំបុត្រដែលសម្ងាត់តែម្ដង ពីព្រោះខ្ញុំក៏មិនហ៊ានបើកដែរ។ ហើយអ្នកដែលទៅជាមួយខ្ញុំហ្នឹងគឺ អ្នកដែលនៅផ្ទាល់ជាមួយ តាសារឿន ហ្នឹង ឈ្មោះ ម៉ាន ទៅជាមួយខ្ញុំហ្នឹង។

**ស៖** លោកមិនបានឆ្លើយទៅនឹងសំណួរមុខរបស់ខ្ញុំទេ។ ខ្ញុំនិយាយអំពីវិទ្យុទាក់ទង ក្នុងការផ្លាស់ប្ដូររបាយការណ៍ជាមួយនឹងសេនាធិការដែលលោកត្រូវបកប្រែនោះ តើគេមាននិយាយអំពីបញ្ហាខ្មាំងបង្កប់ស៊ីរូងផ្ទៃក្នុង ខ្មាំងខាងក្រៅ<ទេ>? តើ តាសារឿន មានបានស្នើទៅ បង៨៩ ឬ បងសុន សេន នោះ សុំសេចក្ដីណែនាំពីគាត់ទេ?

**ឆ៖** ខ្ញុំអត់ដែលឃើញសាររបស់គាត់ ទាក់ទងនឹងខ្មាំងស៊ីរូងផ្ទៃក្នុងនៅក្នុងអង្គភាពយ៉ាងណាៗ។ ខ្ញុំអត់ដែលបានឃើញសាររបស់គាត់ទេ។

[១០:៤៤:៥៥]

**ស៖** យើងនឹងពិភាក្សាអំពីបញ្ហានេះនៅពេលក្រោយ ដោយខ្ញុំនឹងអានឯកសារមួយចំនួន។ ក៏ប៉ុន្តែឥឡូវនេះ ខ្ញុំចង់សួរលោកថា តើទីបញ្ជាការកងពល៨០១ ដែលលោកធ្វើការពាក់ព័ន្ធនឹងផ្នែកវិទ្យុទាក់ទងនោះ ខ្ញុំចង់ដឹងថាដំបូងមានទីតាំងនៅបានលុង ក្រោយមកប្តូរទៅវ៉ឺនសៃមែនទេ?

**ឆ៖** បាទ ត្រឹមត្រូវហើយ។

**ស៖** ហើយលោកធ្វើការនៅក្នុងមន្ទីរកងពលហ្នឹង នៅវ៉ឺនសៃហ្នឹងរហូតទៅដល់ឆ្នាំណា?

**ឆ៖** ចាប់ពីខ្ញុំទៅដល់ខេត្តរតនគិរី ដំបូងបោះទីតាំងនៅបានលុង ដោយសារស្ថានភាពនៅកន្លែងនុ៎ងមានមីន មានគ្រាប់មិនទាន់ផ្ទុះច្រើន ហើយជាកន្លែងមួយមិនទូលាយ ហើយចង្អៀត វាតែច្រមុះភ្នំមួយតូច ហើយក៏កងពលបានរៀបចំរុះរើទីបញ្ជាការ។ ដំបូងប្រុងទៅនៅលំផាត់ ជាទីរួមខេត្តរតនគិរីជំនាន់សម្តេច។ ហើយខ្ញុំក៏បានទៅមើលទីតាំងជាមួយគាត់ ជូនដំណើរគាត់បើកឡាន ជូនដំណើរគាត់ទៅមើលទីតាំងនោះ។ ហើយទៅដល់សួរប្រជាពលរដ្ឋនៅក្នុងសហករណ៍ គាត់ថាពិបាកនៅណាស់តំបន់ហ្នឹងគឺទឹកលិចខែវស្សា ទឹកជំនន់លិចមួយពេលៗ។ ហើយក៏ត្រឡប់មកវិញ ហើយនិងសម្រេចថា ទៅមើលនៅវ៉ឺនសៃ។ ហើយវ៉ឺនសៃ ខ្ញុំអត់ដែលបានទៅៗមើលកន្លែងទេ តាំងពីខ្ញុំត្រឡប់មកពីជូនគាត់ទៅមើលនៅលំផាត់មក។ សកម្មភាពរបស់គាត់ហ្នឹងគឺចេះតែដើររកកន្លែង--

**ស៖** *(គ្មានការបកប្រែ)*

**ឆ៖** ហើយទៅនៅកន្លែងវ៉ឺនសៃ យកទីតាំងនៅវ៉ឺនសៃ។

[១០:៤៧:៤៦]

**ស៖** សូមអរគុណ។ លោកឆ្លើយវែងមែន<ទែន> ហើយខ្ញុំសួរលោកហ្នឹងគឺសាមញ្ញបំផុត។ អ៊ីចឹងខ្ញុំសូមឱ្យលោកឆ្លើយខ្លីៗទៅនឹងសំណួររបស់ខ្ញុំ ដោយសារតែយើងមានពេលវេលាមានកម្រិត។ សូមអរគុណលោក។ នៅក្នុងកំណត់ហេតុឯកសារលេខ E3/9734 ចម្លើយទី៧ លោកថា លោកធ្វើការនៅមន្ទីរកងពល៨០១ នោះរហូតដល់ពេលលោក<រៀប>ការ គឺនៅថ្ងៃទី២៧ ខែមីនា ឆ្នាំ១៩៧៧។ តើត្រឹមត្រូវទេ?

**ឆ៖** បាទ ត្រឹមត្រូវ។

**ស៖** ក្រោយមកគេចាត់លោកឱ្យទៅធ្វើការនៅមន្ទីរអប់រំកែប្រែអ្នកទោសនៅជិតស្រុកបានលុង គឺនៅក្នុងតំបន់១០២ មែនទេ?

**ឆ៖** បាទ។

សៈ អ្នកណាជាអ្នកចាត់តាំងឲ្យលោកទៅធ្វើការនៅទីនោះ? ហើយគេមានប្រាប់លោកទេថា ហេតុអ្វីបានជាគេចាត់តាំងលោកឲ្យទៅធ្វើការនៅក្នុងមន្ទីរអប់រំកែប្រែអូរកន្សែងនោះ?

ឆៈ ខ្ញុំអត់ដឹងពីមូលហេតុថា ហេតុអីបានជាឲ្យខ្ញុំទៅនៅកន្លែងហ្នឹង។ ហើយអ្នកដែលឲ្យខ្ញុំទៅហ្នឹងគឺនៅមន្ទីរកងពលហ្នឹងមានប្រធានមន្ទីរគេ។ ប្រធានមន្ទីរហ្នឹងប្រាប់ខ្ញុំ ឲ្យទៅនៅកន្លែងបានលុងហ្នឹង។

សៈ <តើគាត់>មានប្រាប់លោកថា លោកទៅកាន់មុខតំណែងអីទេនៅក្នុងមន្ទីរសន្តិសុខអូរកន្សែងហ្នឹង?

ឆៈ មុនៗខ្ញុំចេញដំណើរពីក្បាលល្វាច ឈ្មោះ ស៊ុង ហ្នឹងប្រធានមន្ទីរកងពលហ្នឹងប្រាប់ខ្ញុំថាស្អែករៀបចំអីវ៉ាន់ទៅបានលុង ទៅជួប តាឆេង។

[១០:៥០:២៥]

សៈ តាឆេង ហ្នឹងជាអ្នកណា? <តើលោកអាចប្រាប់យើងបានទេថា គឺគាត់នេះហើយដែលជាអ្នកចាត់តាំងលោកឲ្យកាន់តួនាទីច្បាស់លាស់នោះ?>

ឆៈ ប្រធានគ្រប់គ្រងភស្តុភារនៅកន្លែងហ្នឹង ហើយខ្ញុំទៅដល់ឃើញជួបគាត់នៅហ្នឹង។

សៈ គាត់ប្រធានភស្តុភារហ្នឹង គាត់ធ្វើការនៅក្នុងអង្គភាព៨០៦ <ឬវរសេនាតូច៨០៦ ដែលទទួលខុសត្រូវផ្នែកភស្តុភារនៅក្នុងកងពល៨០១> មែនទេ?

ឆៈ បាទ។

សៈ ពេលលោកទៅដល់អូរកន្សែង តើលោកមានមុខងារអ្វីខ្លះនៅទីនោះ? ហើយអ្នកណាជាប្រធានមន្ទីរសន្តិសុខនោះ?

ឆៈ ពេលខ្ញុំទៅដល់ដំបូងនៅជាមួយ តាឆេង ហ្នឹង អត់ទាន់មានរៀបចំចាត់តាំងមុខងារខ្ញុំជាស្អីៗទេ។ ខ្ញុំនៅតែជាមួយ តាឆេង ហ្នឹង។

សៈ ខ្ញុំសួរសំណួរម្តងទៀត។ តើអ្នកណាក្លាយជាប្រធានមន្ទីរសន្តិសុខអូរកន្សែង។

ឆៈ ខ្ញុំទៅដល់កន្លែង តាឆេង ប្រហែលជាកន្លះខែបានឃើញម្នាក់ឈ្មោះ សៃ មកកន្លែង តាឆេង ហ្នឹង។

សៈ សៃ ហ្នឹងគាត់មានមុខងារអ្វីដែរ?

ឆៈ ក្រោយពេលចេញពីអាកន្លែង ចេញពីបានលុងទៅនៅមាត់អូរ គេហៅអូរកន្សែងហ្នឹងបាន

មានឈ្មោះ តាស្មៀន ហ្នឹងមករៀបចំឲ្យ សែ ជាប្រធាន ហើយឈ្មោះ ទីម ៗហ្នឹងជាៗជាមនុស្សដែលនៅក្នុងអង្គភាព៨០៦ ហ្នឹង ជាអនុប្រធាន ហើយខ្ញុំជាសមាជិក។

[១០:៥៣:២៨]

**ស៖** ខ្ញុំនឹងត្រឡប់មកនិយាយអំពីចំណុចនេះវិញ ព្រោះខ្ញុំស្តាប់ដូចជាមិនសូវច្បាស់។ ខ្ញុំនឹងអាននូវចម្លើយរបស់លោក ដែលលោកបានឆ្លើយនៅក្នុងកំណត់ហេតុស្តាប់ចម្លើយរបស់លោកគឺ E3/9734។ នៅចម្លើយទី៦ លោកបានឆ្លើយដូចតទៅ ខ្ញុំសូមដកស្រង់៖ "មន្ទីរសន្តិសុខហ្នឹងស្ថិតនៅក្រោមកងវរសេនាតូច៨០៦ ហើយ តាឆេង ហ្នឹងជាអ្នកគ្រប់គ្រងនៅទីនោះមុនគេ។ ខ្ញុំមកធ្វើការបានប្រហែលមួយអាទិត្យទើប តាសែ គាត់មកធ្វើការនៅទីនោះដែរ។ ក្រោយមកខាងកងពល គេចាត់តាំងឲ្យ តាសែ ហ្នឹងធ្វើជាប្រធាន។ <ទីម> ជាអនុប្រធាន ហើយខ្ញុំជាសមាជិក។" សូមបញ្ចប់ការដកស្រង់។ ដូច្នេះខ្ញុំសូមដកស្រង់ចម្លើយមួយទៀតដែលលោកបានឆ្លើយថា លោកជាអនុប្រធានទទួលបន្ទុកខាងសួរចម្លើយ ហើយទីម ហ្នឹងជាសមាជិកទេ។ អ៊ីចឹងមានការផ្លាស់ប្តូរមុខងាររបស់លោកយ៉ាងម៉េច? លោកជាអនុប្រធាន ឬក៏ជាសមាជិក? ហើយចុះ <ទីម> នោះ <ទីម> គាត់ធ្វើអីឲ្យប្រាកដ ជាអនុប្រធាន ឬក៏ជាសមាជិក?

**ឆ៖** ទីម ហ្នឹងគាត់ជាអនុប្រធាន។ សែ គាត់ជាប្រធាន ហើយខ្ញុំជាសមាជិកទទួលបន្ទុកខាងការរៀបចំចម្លើយរបស់អ្នកជាប់ឃុំឃាំងហ្នឹង។

**ស៖** ចុះ ទីម ហ្នឹងគាត់មានមុខងារអ្វីដែរ ពិតឲ្យប្រាកដនោះនៅក្នុងមន្ទីរសន្តិសុខអូរកន្សែងនោះ?

**ឆ៖** គាត់អ្នកគ្រប់គ្រងកងសន្តិសុខនៅមន្ទីរអូរកន្សែងហ្នឹង។

[១០:៥៦:០០]

**ស៖** ដូច្នេះមានន័យថា គាត់ជាអ្នកទទួលបន្ទុករៀបចំការពារយាមកាមសន្តិសុខនៅមន្ទីរសន្តិសុខអូរកន្សែង គឺបានន័យថា យាមកាមអ្នកទោសអ៊ីចឹងមែនទេ ហើយនិងត្រួតពិនិត្យទៅលើការសម្លាប់អ្នកទោសផងដែរមែនទេ? គឺតួនាទីគាត់អ៊ីចឹងមែនទេ?

**ឆ៖** បាទៗ។

**ស៖** តើមានបុគ្គលិកប៉ុន្មាននាក់ធ្វើការជាប្រចាំនៅក្នុងមន្ទីរសន្តិសុខអូរកន្សែង? ក្រៅពី សែ, ទីម ហើយនិងលោកជាកម្មាភិបាលនេះ តើមានបុគ្គលិកប៉ុន្មាននាក់ដែលធ្វើការជាប្រចាំនៅទីនោះតែម្តង?

**ឆ៖** មិនលើសពី១០នាក់ទេ បុគ្គលិកដែលធ្វើការនៅមន្ទីរហ្នឹង។

**លោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

ខ្ញុំសូមអានចម្លើយរបស់សាក្សី 2-TCW-840។ ខ្ញុំសូមការអនុញ្ញាតពីលោកប្រធានដើម្បីបង្ហាញឈ្មោះសាក្សីរូបនេះ ពីព្រោះគាត់បានផ្តល់សក្ខីកម្មរួចមកហើយនៅក្នុងសំណុំរឿង០០២/០១ ពាក់ព័ន្ធទៅនឹងអូរកន្សែងនេះ។ លោកប្រធានតើអនុញ្ញាតឲ្យខ្ញុំបញ្ចេញឈ្មោះទេ?

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះអនុញ្ញាត!

**សួរដោយលោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

**ស៖** ខ្ញុំសូមបញ្ជាក់ថា ឆោម សែ នៅក្នុងកំណត់ហេតុរបស់គាត់នុ៎ង គឺ<E3/407> នៅចម្លើយទី២០។ ខ្ញុំសូមដកស្រង់៖ “បុគ្គលិកដែលធ្វើការនៅក្នុងមន្ទីរសន្តិសុខនុ៎ងមាន១២នាក់។” ឯកសារហ្នឹងគឺ E3/407 គឺមានន័យថា កម្មាភិបាលបីនាក់ ហើយនិងអ្នកយាមប្រាំបួននាក់។ តើលោកចាំទេថា អ្នកយាមនៅអូរកន្សែងនុ៎ងមានឈ្មោះអ្វីខ្លះ?

[១០:៥៨:៣០]

**2-TCW-900៖**

**ឆ៖** ខ្ញុំបានចាំមានឈ្មោះ ឡាយ, ឈ្មោះ ជួប ហើយឈ្មោះ ញ៉ុក, ហើយមានឈ្មោះ តាអ៊ួយ ហើយមានឈ្មោះ ចាត, ហើយមានឈ្មោះ សេត ហើយក្រៅពីហ្នឹងទៀត ខ្ញុំភ្លេចឈ្មោះ។

**ស៖** បាទ សូមអរគុណ។ តើលោកអាចរៀបរាប់អំពីភារកិច្ចជាក់លាក់របស់ តាសែ បានទេ? គាត់ក្តាប់រួមនៅក្នុងមន្ទីរសន្តិសុខនុ៎ងតែម្តង ឬក៏យ៉ាងម៉េច? ហើយគាត់ទទួលខុសត្រូវក្នុងការទំនាក់ទំនងជាមួយថ្នាក់លើមែនទេ?

**ឆ៖** សែ គាត់មានតួនាទីទទួលខុសត្រូវរួមនៅក្នុងមន្ទីរហ្នឹង នៅកន្លែងអូរកន្សែងហ្នឹង ហើយគាត់មានទំនាក់ទំនងផ្ទាល់ជាមួយខាងលើ។

**ស៖** នៅពេលដែលយើងនិយាយអំពីថ្នាក់លើនេះ លោកសំដៅទៅលើ តាសារឿន ឬក៏លោកសំដៅទៅលើកងវរសេនាតូច ភស្តុភារ<៨០៦>? លោកអាចបញ្ជាក់អំពីទំនាក់ទំនង <ដែលគាត់មាន និងរបាយការណ៍ដែល គាត់ត្រូវធ្វើឲ្យថ្នាក់លើ>ហ្នឹងបានទេ? <>

**ឆ៖** អង្គភាពមន្ទីរឃុំឃាំងអូរកន្សែងនៅក្រោមការគ្រប់គ្រងរបស់វរសេនាតូចលេខ៨០៦។ នៅពេលដែល សែ គាត់ទៅរាយការណ៍ គឺគាត់ទៅចូលមេវរសេនាតូចលេខ៨០៦ មុនគេ។

*ប្រតិចារិកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារិកក្នុងភាសាទាំងបី។ ប្រតិចារិកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារិកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**ស៖** បាទ ទាក់ទងទៅនឹងបញ្ហាស្រួចស្រាល់ តើគាត់ធ្វើរបាយការណ៍ទៅ តាសារឿន ដោយផ្ទាល់ ឬក៏គាត់ទៅជួប តាសារឿន ផ្ទាល់តែម្តង?

[១១:០១:២៩]

**ឆ៖** ខ្ញុំអត់បានដឹងថា គាត់ទៅជួប តាសារឿន ផ្ទាល់ឬក៏ទៅជួបនរណា។ ខ្ញុំគ្រាន់តែដឹងថា គាត់ទៅសំដៅកន្លែងវរសេនាតូចលេខ៨០៦ ហ្នឹងហើយ។

**ប្រធានអង្គជំនុំ៖**

លោកៗសាក្សី សូមលោកបង្អង់បន្តិច ក្រោយពេលដែលលោកស្តាប់សំណួររួច ដោយសារមានការឆ្លងកាត់ការបកប្រែហើយ តាមរយៈប្រព័ន្ធសោតទស្សន៍ អ៊ីចឹងមានការយឺតបន្តិច។ អ៊ីចឹងលោកអង់បង្អង់បន្តិច ជៀសវាងនូវសំឡេងហ្នឹងជាន់គ្នារវាងការសួរហ្នឹង ដូចជាមិនចប់ ហើយលោកឆ្លើយតប។ លោកយល់ដែរទេ លោកសាក្សី? ព្រោះយើងធ្វើតាមប្រព័ន្ធសោតទស្សន៍ ហើយមានការបកប្រែជាពីរភាសាទៀត។ ភាសាផ្លូវការ គឺមានប្រើភាសានៅនេះបី ភាសាខ្មែរ ភាសាបារាំង និងភាសាអង់គ្លេសណា។

**2-TCW-900៖**

បាទ ខ្ញុំយល់ហើយ។ សូមបន្តយ។

**សួរដោយលោក វ៉ាំងសង់ វ៉ាយដ៍ ដេស្នាងឈល៖**

**ស៖** លោកសាក្សី តើ ឆោម សែ ធ្លាប់ចូលរួមសួរចម្លើយអ្នកទោស<>ដែលលោកទទួលបន្ទុកសួរចម្លើយនោះ<ទេ>?

[១១:០៣:០០]

**2-TCW-900៖**

**ឆ៖** បាទ រាល់ការសួរអ្នកទោសគ្រប់ទាំងអស់ គឺមានវត្តមានរបស់ សែ ហើយ សែ ជាអ្នកសួរផ្ទាល់។ ឯខ្ញុំគ្រាន់តែជាអ្នកកត់ត្រានូវចម្លើយដែលគេបាននិយាយ។

**ស៖** តើចំពោះគាត់ហ្នឹង មិនជាការលំបាកទេឬ<ដែល>ត្រូវមានវត្តមានសួរចម្លើយរហូត ហើយក្នុងពេលជាមួយគ្នានោះ គាត់ត្រូវមើលការខុសត្រូវនៅមន្ទីរសន្តិសុខហ្នឹងទាំងមូល ហើយគាត់ត្រូវទៅរាយការណ៍ទៅថ្នាក់លើផងដែរ? អ៊ីចឹងលោកច្បាស់ទេថា សែ ហ្នឹងគាត់មានវត្តមានរហូតជាអ្នកសួរចម្លើយរហូតនោះ លោកច្បាស់ទេ?

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**ឆ៖** បាទ ខ្ញុំច្បាស់ ពីព្រោះគាត់ឡើងទៅជួបខាងលើ មិនមែនទៅរាល់ថ្ងៃទេ។

**ស៖** បាទ សូមអរគុណ។ ទាក់ទងទៅនឹងអ្នកយាមកាម លោកនិយាយថា មានប្រាំបួននាក់។ ហើយលោកបានរៀបរាប់នៅក្នុងនេះ តែប្រាំមួយនាក់ទេ។ តើមានអ្នកយាមផ្សេងទៀតទេ គឺថាក្រៅពី ឡាយ, <ជួប>, <ចាង>, សេត, ញ៉ុក ហើយនិង អ៊ួយ <តើ>លោកចាំ<>ទេ? <> ឧទាហរណ៍ខ្ញុំសួរ ឈ្មោះ ទីន នេះ លោកចាំឈ្មោះ ទីន ហ្នឹងទេ?

**ឆ៖** ទីមៗ ហ្នឹងជាគណៈជាមួយខ្ញុំហ្នឹងហើយ ទីម។ បាទ ញាប់បន្តិច។

**ស៖** ខ្ញុំមិននិយាយពីសមាជិកទេ ខ្ញុំនិយាយឈ្មោះ ពីឈ្មោះ ទីន លោក។ គាត់ប្រហែលជាអ្នកយាម បើមិនអ៊ីចឹងទេជាអ្នកទោស ដែលគេឲ្យការងារគាត់ធ្វើទទួលខុសត្រូវមួយដែរ។ លោកចាំឈ្មោះ ទីន នេះទេ?

[១១:០៥:៤១]

**ឆ៖** បាទ ខ្ញុំចាំឈ្មោះ ទីន មិនមែន ទីម ទេ ទីន។ ទីន ហ្នឹងមកពីសហជីព។ ហើយខាងសហជីពហ្នឹងបញ្ជូនខ្លួនគាត់មកកន្លែងហ្នឹង ហើយឃើញសួរនាំគាត់ទៅដូចអត់ឃើញមានអី ក៏គាត់មករួមជួយការងារនៅក្នុងក្រុមសន្តិសុខហ្នឹង។

**ស៖** តើគាត់មានដូរមុខងារអីទេ? គាត់ជាអ្នកយាមរហូត ឬក៏គាត់ជាអ្នកទោសទេ? ហើយគេទុកចិត្តគាត់ គេឲ្យការងារគាត់ធ្វើ។ អ៊ីចឹងខ្ញុំចង់សួរលោកឲ្យច្បាស់ថា តើមុខតំណែងគាត់ហ្នឹងអ្វីដែរ?

**ឆ៖** នៅ -- ឈ្មោះ ទីន ហ្នឹងនៅក្រោយពេលដែលគាត់បានមកជួយការងារនៅក្នុងមន្ទីរហ្នឹង គឺឲ្យគាត់ជួយជាអ្នករកម្ហូប និងរកបន្លែសម្រាប់យកមកស្លឲ្យអ្នកដែលនៅកន្លែងហ្នឹង។

**ស៖** លោកនិយាយពីឈ្មោះ ឡាយ ដែរអម្បាញ់មិញនេះ។ អ៊ីចឹង ឡាយ ហ្នឹងជាអ្នកយាមដែលនៅក្នុងកងពល៨០១ ពីដើម ហើយក្រោយមកគេចាត់ឲ្យគាត់ទៅធ្វើជាអ្នកយាមនៅមន្ទីរសន្តិសុខហ្នឹង ឬក៏ពីដើមមកហ្នឹងឈ្មោះ ឡាយ ហ្នឹងជាអតីតអ្នកទោសទេ?

**ឆ៖** ឈ្មោះ ឡាយ ជាមនុស្សមកពីអង្គភាពពិការ ដែលមានទីតាំងនៅជាប់មាត់អូរ មាត់បឹងកន្សែងហ្នឹង ហើយគាត់មករួមធ្វើការងារនៅកន្លែងមន្ទីរហ្នឹង។

**ស៖** ដើម្បីបំភ្លឺ ខ្ញុំស្តាប់ការបកប្រែមិនបានទាំងអស់ទេអម្បាញ់មិញនេះ។ លោកនិយាយនៅក្នុងកំណត់ហេតុស្តាប់ចម្លើយរបស់លោក គឺឯកសារ E3/5512 ចម្លើយទី១២ របស់លោកទាក់ទងទៅនឹងអ្នកទោសវៀតណាម លោកបានឆ្លើយដូចតទៅនេះ៖ “យើងបានចេញបញ្ជាទៅអ្នកទោសម្នាក់ដែលជាប់

ឃុំឃាំងនៅមន្ទីរសន្តិសុខអូរកន្សែងឈ្មោះ <ឡៃ> ឲ្យគាត់ជាអ្នកសួរចម្លើយអ្នកទោសវៀតណាមដើម្បីយកចម្លើយ។" បញ្ចប់ការដកស្រង់។ អ៊ីចឹងខ្ញុំឆ្ងល់ ខ្ញុំចង់ដឹងថា តើ ឡាយ ហ្នឹងគាត់មានឋានៈអី? ចង់ដឹងថាគាត់ពីដើមមកគាត់ជាអ្នកទោសនៅអូរកន្សែងទេ ដូច ទីន អ៊ីចឹងដែរ ដល់ក្រោយមកក៏ក្លាយទៅជាអ្នកយាម ហើយមិនត្រឹមតែប៉ុណ្ណឹងទេ ក្លាយដល់ជាសួរចម្លើយអ្នកទោសវៀតណាមទៀតផង? អ៊ីចឹងខ្ញុំសូមឲ្យលោកបញ្ជាក់ពីមុខងាររបស់គាត់ហ្នឹង។

[១១:០៩:៣៣]

**ឆ៖** កន្លែងនេះ ខ្ញុំយល់ ពីដំបូងខ្ញុំអត់ទាន់យល់ ដល់ពីលោកប្រធានបានបញ្ជាក់ ខ្ញុំយល់។ មិនមែនឈ្មោះ ឡាយ ទេ ឈ្មោះ ឡៃ។ បាទ ឡៃ ហ្នឹងគាត់ចេះភាសាវៀតណាម ហើយ ឡៃ ហ្នឹងដើមឡើយគាត់នៅអង្គភាពកងពិសេស មិនដឹងថាគាត់មានបញ្ហាអីទេ គាត់ត្រូវគេបញ្ជូនមកកន្លែងមន្ទីរអូរកន្សែងហ្នឹងក្នុងឋានៈគាត់ជាអ្នកទោស។ ហើយការលំបាកយកព័ត៌មានពីជនជាតិវៀតណាម ពួកខ្ញុំអត់ចេះភាសាវៀតណាមទេ។ ហើយសម្លឹងឃើញថា ឡៃ ហ្នឹងគាត់ចេះវៀតណាម ភាសាវៀតណាមគ្រប់ អាចប្រើប្រាស់បាន។ នៅពេលដែលគាត់មកសួរបកប្រែជាភាសាវៀតណាមហ្នឹង គាត់មិនមែនជាអ្នកសន្តិសុខទេ គាត់នៅក្នុងឋានៈគាត់ជាអ្នកទោសដដែល ប៉ុន្តែប្រើគាត់ ដោយសារខាងខ្ញុំលំបាកពីរឿងការបកប្រែភាសា។

**សៈ** អ៊ីចឹងគឺថាមានពីរនាក់ឈ្មោះ ឡាយ មួយទៀតឈ្មោះ ឡៃ ដែលជាអ្នកទោស ហើយដែលគេប្រើគាត់ធ្វើជាអ្នកបកប្រែហ្នឹង។ អ៊ីចឹងខ្ញុំយល់អ៊ីចឹងត្រូវទេ ឡាយ ជាអ្នកយាម ហើយ ឡៃ ហ្នឹងជាអ្នកចេះវៀតណាម អ្នកបកប្រែ។ អ៊ីចឹងមែនទេ?

**ឆ៖** បាទ ត្រឹមត្រូវហើយ។ ឈ្មោះ ឡៃ ហ្នឹងជាអ្នកបកប្រែ ឈ្មោះ ឡាយ ហ្នឹងជាសន្តិសុខ។

[១១:១១:៥៧]

**សៈ** នៅក្នុងចំណោមអ្នកយាមនៅមន្ទីរអូរកន្សែងនោះ តើមានអ្នកដែលមិនមកពីកងពល៨០១ដែរឬទេ ក៏ប៉ុន្តែមកពីយោធាតំបន់នៅបានលុង ដែលគេចាត់តាំងឲ្យទៅអូរកន្សែង ដើម្បីបង្គ្រប់ចំនួនបុគ្គលិកធ្វើការនៅទីនោះ?

**ឆ៖** ក្រៅពីកម្លាំងក្នុងកងពលនៅក្នុងវរៈចំណុះឲ្យកងពល៨០១ គឺមានកម្លាំងសន្តិសុខមកពីតំបន់។ តំបន់នោះពីរនាក់។

**សៈ** ដើម្បីយល់លោកឲ្យច្បាស់ហ្នឹង គឺថា<>អ្នកយាមទាំងពីរនាក់ហ្នឹងត្រូវបានចាត់តាំងឲ្យមក

មន្ទីរសន្តិសុខអូរកន្សែងហ្នឹងជាប្រចាំការ ហើយ<ពួកគេនៅក្រោមបង្គាប់របស់>អ្នកដឹកនាំនៅមន្ទីរហ្នឹង ឬក៏យ៉ាងម៉េច?

**ឆ៖** អ្នកដែលមកពីតំបន់ ពីរនាក់មកនៅក្នុងការងារសន្តិសុខហ្នឹង គឺនៅក្នុងការគ្រប់គ្រង់របស់ ទីម ដែលទទួលខុសត្រូវផ្នែកសន្តិសុខ។

**ស៖** បាទសូមអរគុណ។ ខ្ញុំមានសំណួរមួយទៀតទាក់ទងទៅនឹងអ្នកទោស។ តើប្រធានមន្ទីរសន្តិសុខហ្នឹងគឺ តាសែ ហ្នឹងគាត់មានផ្តល់ការងារដល់អ្នកទោសដែរឬទេ? ឧទាហរណ៍ដូចជាឲ្យយាមកន្លែងណាមួយនៅក្នុងបរិវេណនៃមន្ទីរសន្តិសុខអូរកន្សែងហ្នឹង ឬក៏ឲ្យអ្នកទោសគ្នាឯងហ្នឹងយាមអ្នកទោសគ្នាឯងដែរ តើរឿងហេតុការណ៍ការងារបែបហ្នឹងមានធ្លាប់កើតឡើងទេ?

**ឆ៖** មានដូចជាឈ្មោះ ទីន១ ជាមកពីសហជីពហ្នឹង មុននឹងគាត់ចូលទៅកន្លែងដាំស្ល និងជួយរកបន្លែហ្នឹង គាត់បានជួយយាមកាមពេលដែលអ្នកទោសហ្នឹងធ្វើការនៅជុំវិញកន្លែងហ្នឹង។

[១១:១៥:១៧]

**ស៖** តើលោកមានឈ្មោះអ្នកទោសមួយដែលឈ្មោះ ផាន់ ចុល -- ផាន ចុល លោកស្គាល់ឈ្មោះហ្នឹងទេ អ្នកទោសហ្នឹង?

**ឆ៖** ខ្ញុំអត់ដែលឮឈ្មោះ ផាន់ ចុល ទេ អ្នកទោសនៅកន្លែងហ្នឹង។

**ស៖** ប្រហែលជាពេលនោះ គាត់មានរហស្សនាមគាត់ក៏មិនដឹង ប៉ុន្តែនៅសវនាការថ្ងៃទី០២ មីនា ឆ្នាំ២០១៦ នៅក្រោយម៉ោង១៥:២២:២៦<វិនាទី> កាលនោះលោកមេធាវី កូប៉េ សួរសំណួរទៅគាត់ ហើយគាត់ឆ្លើយ៖ "ក្រោយពីជម្រះស្មៅនៅកន្លែងហ្នឹង គេឲ្យខ្ញុំយាមនៅចម្ការខ្នុរ ហើយខ្ញុំត្រូវធ្វើយ៉ាងណាមិនឲ្យមានមនុស្សចូលមកលួចខ្នុរ។" សូមបញ្ចប់ការដកស្រង់។ តើគេឲ្យការងាររបៀបហ្នឹងទៅអ្នកទោស<ដែល>មិនមែនជាការប្រថុយប្រថាននឹង<>គ្រោះថ្នាក់ដែរឬទេ? ឬក៏ដោយសារអ្នកទោសនុំងគាត់<>មានកម្រិតទោសគាត់ស្រាល គាត់អាចធ្វើការបាននៅក្នុងមន្ទីរសន្តិសុខហ្នឹង?

**ឆ៖** នៅពេលធ្វើការ ភាគច្រើនទៅជម្រះចម្ការ១ដំឡូង ការងារកាប់ព្រៃធ្វើចម្ការ ហើយនិងដាំដំឡូង ចំពោះអ្នកទោសដែលអាចទៅធ្វើការបាន។

**ស៖** ដោយសារការងារមួយចំនួននោះលំបាក តើមានធ្លាប់សុំឲ្យអ្នកទោសនៅអូរកន្លែងហ្នឹងឲ្យជីករណ្តៅ ឬក៏លុបរណ្តៅនៅពេលដែលមានអ្នកទោសស្លាប់នោះ ដោយជំងឺ ឬក៏ដោយការសម្លាប់នោះ? តើ<>គេមានចាត់តាំងឲ្យអ្នកទោសហ្នឹងជីករណ្តៅ ឬក៏កប់រណ្តៅសពដែរឬទេ?

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**ឆ៖** ភាគីច្រើន គឺកងសន្តិសុខហ្នឹងហើយអ្នកទៅកាយទៅជីក។

[១១:១៨:៥៦]

**ស៖** ខ្ញុំឆ្ងល់ណាស់ ព្រោះថាមានអ្នកយាមសន្តិសុខហ្នឹងប្រាំបួននាក់ ហើយគាត់ត្រូវយាមអ្នកធ្វើការខាងក្រៅនៅពេលថ្ងៃ។ អ៊ីចឹងខ្ញុំសួរថា ក្នុងចំណោមពួកគាត់ហ្នឹង ទាំងប្រាំបួននាក់ហ្នឹង មានអ្នកដែលត្រូវបានចាត់តាំងឲ្យយាមអ្នកទោសដែលគេកំពុងសួរចម្លើយដែរឬទេ?

**ឆ៖** សូមម្តងទៀត ខ្ញុំស្តាប់អត់ទាន់។

**ស៖** បាទ ខ្ញុំឆ្ងល់ដែរ ព្រោះថាមានអ្នកយាមតែប្រាំបួននាក់ទេ លោកនិយាយថា ពួកគាត់ហ្នឹងត្រូវយាមបរិវេណមន្ទីរសន្តិសុខ ត្រូវយាមអ្នកទោសដែលថា ធ្វើការអីជាដើមហ្នឹង <ហើយ>ពួកគាត់ហ្នឹងត្រូវយាមកន្លែងសួរចម្លើយដែរឬទេ ពេលដែលគេសួរចម្លើយអ្នកទោសនោះ។ <>ការងារអស់ហ្នឹងជាការ<ងាររបស់>គាត់ <តើ>គាត់មានពេលជីករណ្តៅ <និង>កប់<រណ្តៅ>សាកសពដែរឬក៏យ៉ាងម៉េច?

**ឆ៖** អ្នកយាមនៅកន្លែងសួរចម្លើយមានតែម្នាក់។ ហើយអ្នកដែលនាំកម្លាំងទៅធ្វើការនៅជុំវិញកន្លែងហ្នឹង ជាប្រចាំគឺបីនាក់។ ហើយនៅពេលដែលមានជីករណ្តៅកប់សាកសពអី ខ្ញុំអត់ដឹងថា មានប៉ុន្មាននាក់ទេ ពីព្រោះភាគច្រើនគេធ្វើការពេលយប់។

**ស៖** បាទ សូមអរគុណ។ <តើ>ដោយសារ<តែវានៅក្រោមការទទួលខុសត្រូវ>របស់<ទឹម> <ក្នុងការ>ចាត់ចែងការងារផ្នែកក្រុមសន្តិសុខហ្នឹង<ឬ បានជា>លោកមិនដឹងពីរឿង<ទាំងអស់ទាក់ទងនឹងបញ្ហាសំខាន់នេះ>?

[១១:២១:៤៧]

**ឆ៖** ផ្នែកហ្នឹងជាការងារដែលរបស់ ទឹម គាត់ជាអ្នកទទួលខុសត្រូវ។

**ស៖** ខ្ញុំចោទសំណួរលោកទាក់ទងទៅនឹងតួនាទីជាក់លាក់របស់មន្ទីរសន្តិសុខហ្នឹង។ <ដូចលោកនិង ឆោម> សែ <បាន>និយាយ<ហើយ គឺវាសំដៅទៅលើ> មន្ទីរអប់រំកែប្រែ <ឬ>មន្ទីរសន្តិសុខ<ដោយសំអាងថាមាន>អ្នកទោស។ តើមានទម្រង់កែប្រែយ៉ាងម៉េចដែលគេប្រព្រឹត្តទៅលើអ្នកទោសនៅទីនោះ ក្រៅពីការ<លត់ដំ តាមរយៈការ>ឲ្យគាត់ធ្វើការងារនៅទីនោះ<ទេ>? <ខ្ញុំសួរជាពិសេសគឺ>វគ្គអប់រំ<កែប្រែ តើមានវគ្គអប់រំកែប្រែ>អីដែរឬទេ នៅក្នុងមន្ទីរហ្នឹង?

**ឆ៖** ក្រៅពីការងារពលកម្មដូចជាធ្វើស្រែ ធ្វើចម្ការ។ ហើយរៀងរាល់១០ថ្ងៃ មានការអប់រំអ្នក

ទាំងអស់គ្នាហ្នឹង ពន្យល់អំពី និយាយរួមតាមឯកសារដែលដូចជាទង់បដិវត្ត និងឯកសារយុវជន ទាក់ទងនឹងការធ្វើបដិវត្តន៍សង្គមនិយមហ្នឹង។

**ស៖** បើសិនជាខ្ញុំមិនច្រឡំទេ ទង់បដិវត្តហ្នឹងគឺ<ជាទស្សនាវដ្តី>គេទុកសម្រាប់តែកម្មាភិបាលបក្សទេ។ អ៊ីចឹងលោកចង់និយាយថា តាសែ <បាន>ប្រើទស្សនាវដ្តីហ្នឹង<ហើយ>គាត់យកខ្លឹមសារ<សម្ងាត់>ពីទង់បដិវត្តហ្នឹង ទៅនិយាយជាមួយអ្នកទោស<> ឬក៏គាត់ប្រើទង់បដិវត្តហ្នឹង និយាយតែជាមួយសមាជិកអ្នកដែលធ្វើការនៅក្នុង<មណ្ឌលអប់រំកែប្រែហ្នឹងទេ>?

**ឆ៖** ជារៀងរាល់ខែ មន្ទីរនោះទទួលឯកសារទង់បដិវត្តនិងទង់យុវជនហ្នឹង ឯកសារយុវជនហ្នឹងជារៀងរាល់ខែ។ នៅពេលដែលមានកិច្ចប្រជុំណែនាំដល់អ្នកដែលនៅក្នុងហ្នឹង គឺនិយាយអំពីការអភិវឌ្ឍសង្គមនិយម ហើយមួយទៀតគឺទាក់ទងដល់ការស្មោះត្រង់ជាមួយបក្ស។

[១១:២៥:៣០]

**ស៖** ខ្ញុំនៅសល់ពីរបីនាទីទៀត អ៊ីចឹងខ្ញុំចោទសំណួរលោកទាក់ទងទៅនឹងអគារនៃមន្ទីរសន្តិសុខហ្នឹង។ តើនៅក្នុងមន្ទីរសន្តិសុខហ្នឹងមានអគារដាក់អ្នកទោសប៉ុន្មាន<>ពេលដែលលោកទៅទីនោះដំបូង<>? ហើយពេលក្រោយមក គឺថាពេលចុងបញ្ចប់នោះ តើមានអគារប៉ុន្មានដែរ? <តើ>មានការសង់អគារបន្ថែមទៀតដើម្បីដាក់អ្នកទោស<ទេ>?

**ឆ៖** ក្រោយពីរើកន្លែងពីបានលុងទៅនៅជាប់មាត់អូរកន្សែងហ្នឹង មានអគារសម្រាប់ដាក់អ្នកទោសហ្នឹង ខាងលិចជាប់មាត់អូរហ្នឹងពីរ ហើយខាងកើតហ្នឹងមួយ អាហ្នឹងវែងជាងគេតិច ហើយក្រៅពីហ្នឹងចង្ក្រានបាយ ហើយនិងផ្ទះខ្ញុំ។ ទៅដល់ដំបូងមានអគារតែ សរុបមានតែប្រាំខ្នងទេ ធ្វើពីឫស្សី ហើយឈើមូល ហើយប្រក់ស្បូវ ជញ្ជាំងបន្ទាំ។

**ស៖** សំណួរខ្ញុំៗចង់ដឹងថា បន្ទាប់មកទៀតហ្នឹងគេសង់អគារថែម ឬក៏យ៉ាងម៉េច? គឺថាសង់ថែមហ្នឹងដើម្បីមានកន្លែងគ្រប់គ្រាន់ដាក់អ្នកទោស តើមានសង់អគារថែមទេ ក្រោយមក?

**ឆ៖** ក្រោយមកមានសង់ថែមនៅខាងកើត ហើយអគារសមរម្យ។ សមរម្យដោយយកកម្លាំងអ្នកដែលនៅក្នុងហ្នឹងចេះអារឈើអារអីទៅ សង់បានស្អាត ហើយជញ្ជាំងក៏ស្អាតដែរ ហើយកន្លែងស្នាក់នៅ ដេកពួនអីក៏សមរម្យដែរ។ ហើយសង់ថ្មីហ្នឹង អាខាងលិចឈប់ប្រើហើយ ហើយប្រើតែខាងកើតមានអគារវែងហ្នឹងមួយខ្នង ហើយបន្ទាប់មកមានអគារមួយសម្រាប់ស្រីៗ ហើយផ្ទះបាយ ហើយនិងផ្ទះពួកខ្ញុំសម្រាកហ្នឹង។

---

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឱ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

[១១:២៨:៥៦]

**ស៖** អ៊ីចឹងបើខ្ញុំមិនច្រឡំទេ គឺថាលោកនិយាយថា<>ពេលចុងក្រោយហ្នឹងគឺមានអគារចំនួនប្រាំ ដាក់អ្នកទោស គឺថា<អគារពីរ>នៅខាង<លិច>អូរ<> ហើយ<អគារពីរទៀតនៅខាងកើត ដែលមាន ទំហំធំជាង ហើយនិងអគារមួយទៀតសម្រាប់ដាក់អ្នកទោសស្ត្រី>។ <នេះគឺជាអ្វីដែល ឆោម សែ បាន និយាយនៅក្នុងកំណត់ហេតុស្តាប់ចម្លើយរបស់គាត់ គឺ>ឯកសារ E3/405 នៅចម្លើយទី១១<របស់ គាត់> ខ្ញុំដកស្រង់ចម្លើយ<>៖ "គឺថានៅក្នុងមន្ទីរនេះមានអគារអ្នកទោសបួន <អគារនីមួយៗមាន> ទទឹង៤ បណ្តោយ៦<ម៉ែត្រ>។ នៅក្នុងអគារមួយៗនោះគឺមានអ្នកទោស១២នាក់។ ហើយក្រោយមក ដោយសារចំនួនអ្នកទោសនុ៎ងកាន់តែកើតឡើង យើងសង់អគារបីទៀតបន្ថែមទៀត។ (ខ្ញុំដកចន្លោះបន្តិច ដកស្រង់)៖ បន្ថែមពីហ្នឹងទៀត គឺថាមានអគារពីរទៀត ដែលដាក់អ្នកទោសពិសេស ហើយដែលមាន ទោសធ្ងន់ជាងគេ ដែលតម្រូវឲ្យមានការយាមដ៏ប្រុងប្រយ័ត្ន។" សូមបញ្ចប់ការដកស្រង់។

អ៊ីចឹងខ្ញុំរាប់ទៅ ថាមេមន្ទីរសន្តិសុខហ្នឹងថាមានពីដើមមកមានអគារបួនដាក់អ្នកទោស ហើយខ្ទម បី -- ឃ្លាំងបី ហើយនិងមានអគារពីរទៀតសម្រាប់ដាក់អ្នកទោសពិសេស ទោសធ្ងន់។ អ៊ីចឹងខ្ញុំសួរ លោក ថាលោកយល់ឃើញយ៉ាងម៉េចដែរ ដូចលោកនិយាយអំពីអគារសម្រាប់ដាក់អ្នកទោសធ្ងន់អីជា ដើមនេះ លោកមានប្រតិកម្មយ៉ាងម៉េចដែរ?

**ប្រធានអង្គជំនុំ៖**

លោកសាក្សីឆ្លើយតប! លោកស្តាប់សំណួរបានទេ លោកសាក្សី?

[១១:៣១:៣០]

**2-TCW-900៖**

បាទ ខ្ញុំស្តាប់បាន លោកប្រធាន ថាចាំឲ្យវានេះបន្តិចបានខ្ញុំឆ្លើយ ព្រោះខ្ញុំសំឡឹងមើលឃើញរូបខ្ញុំ បានខ្ញុំឆ្លើយ។ ពីមុនខ្ញុំចេះឆ្លើយបន្ទាន់។ សូមអធ្យាស្រ័យ។

**ឆ៖** កន្លែងរោងសម្រាប់អ្នកដាក់អ្នកទោសធ្ងន់ហ្នឹង គឺមាន។ ហើយមានការយាមកាមទាំងយប់ ទាំងថ្ងៃហ្មត់ចត់ ពីព្រោះអ្នកទោសដែលធ្ងន់ហ្នឹងត្រូវដាក់ច្រវាក់។

**សួរដោយលោក វ៉ាំងសង់ វ៉ាយដ៍ ដេស្សាងឯល៖**

**ស៖** សូមអរគុណ។ ខ្ញុំសួរចំណុចចុងក្រោយមួយមុននឹងសម្រាក។ លោកទទួលបន្ទុកខាងសួរ ចម្លើយ តើលោកអាចពិពណ៌នាអំពីបន្ទប់ហ្នឹង ឬក៏ជម្រកហ្នឹង និយាយទៅកន្លែងសួរចម្លើយអ្នកទោស

លោកអាចជម្រាបជូនតុលាការបានទេ ថាតើកន្លែងសួរអ្នកទោសហ្នឹងនៅកន្លែងណា បើធៀបទៅនឹងអគារដាក់អ្នកទោសនោះ?

**ឆ៖** កន្លែងសួរចម្លើយអ្នកទោសនៅមិនឆ្ងាយពីផ្ទះខ្ញុំសម្រាកទេ។ តាមការប៉ាន់ប្រមាណប្រហែលជាមិនដល់១០០ម៉ែត្រទេ ហើយអគារហ្នឹងមិនមែនជាអគារអីធំជុំបាំងជញ្ជាំងជិត ធ្វើជារោងប្រក់ស្បូវ ហើយមានកន្លែងអង្គុយធ្វើពីឫស្សី ហើយអ្នកកន្លែងអង្គុយរបស់អ្នកទោសហ្នឹង ក៏ធ្វើពីឫស្សីហើយកន្លែងអ្នកសួរចម្លើយហ្នឹងក៏ធ្វើពីឫស្សីដែរ ហើយមិនមានអីគត់មត់ជញ្ជាំងព័ទ្ធជុំវិញទេ មានតែព្រៃសងខាង។

[១១:៣៣:៥៥]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ បាទ ឥឡូវនេះដល់ពេលសម្រាកថ្ងៃត្រង់ហើយ អង្គជំនុំជម្រះប្រកាសសម្រាកចាប់ពីពេលនេះតទៅរហូតដល់ម៉ោងមួយកន្លះរសៀលនេះ សូមអញ្ជើញវិញដើម្បីបន្តកិច្ចដំណើរការសវនាការ។ ហើយអរគុណលោកសាក្សី ហើយលោកមេធាវីប្រឹក្សាសាក្សី រួមទាំងលោក ញ៉ែម សំណាង បុគ្គលអង្គការធី.ភី.អូ ឥឡូវនេះដល់ពេលសម្រាកថ្ងៃត្រង់ហើយ ហើយអង្គជំនុំជម្រះប្រកាសសម្រាកចាប់ពីពេលនេះតទៅ រហូតដល់ម៉ោងមួយកន្លះណ៎ា សូមអញ្ជើញចូលវិញ។ ដូច្នេះលោកអាចសម្រាកបាន ហើយសុំលោកមកកាន់កន្លែងផ្តល់សក្ខីកម្មតាមរយៈប្រព័ន្ធសោតទស្សន៍នោះវិញនៅវេលាឲ្យបានមុនម៉ោងមួយកន្លះ ដើម្បីត្រៀមខ្លួន ហើយនិងឆ្លើយតបនឹងសំណួរបន្តទៀត លោកសាក្សី លោកយល់ទេ?

**2-TCW-900៖**

បាទ យល់លោកប្រធាន។

**ប្រធានអង្គជំនុំ៖**

អរគុណ លោកអាចសម្រាកបានហើយណ៎ា។

ហើយបង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនលោក ខៀវ សំផន ត្រឡប់ទៅកាន់បន្ទប់រង់ចាំខាងក្រោមសាលសវនាការនេះ ហើយនិងបង្គាប់ឲ្យនាំខ្លួនគាត់ត្រឡប់ចូលសវនាការនៅក្នុងបន្ទប់សវនាការនេះវិញនៅរសៀលនេះឲ្យបានមុនម៉ោងមួយកន្លះ។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១១:៣៥ នាទី ដល់ម៉ោង ១៣:៣៣ នាទី)*

[១៣:៣៣:០៨]

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ សួស្តីលោកសាក្សី តើលោកបានត្រៀមខ្លួនរួចហើយ ឬនៅ?

**2-TCW-900៖**

បាទ រួចហើយលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណណាស់លោកសាក្សី។ ហើយសូមលោកធ្វើការដូចព្រឹកមិញអ៊ីចឹង ហើយឱ្យមានការពន្យារពេលបន្តិចបន្ទាប់ពីស្ដាប់សំណួរហើយ ដើម្បីឱ្យការបកប្រែវាពេញលេញ។ ហើយព្រឹកមិញនេះ ខ្ញុំយូរពេក ខ្ញុំសួរបញ្ជាក់ហ្នឹងខ្ញុំបារម្ភក្រែងលោវាមានបញ្ហាប្រព័ន្ធសោតទស្សន៍ទេ។ អ៊ីចឹងទេណ៎ា មិនមានបញ្ហាអីទេ។ អ៊ីចឹងបើសិនជាលោកធ្វើអ៊ីចឹងបាន គឺជាការល្អ ដោយសារចុងក្រោយនៃសវនាការព្រឹកមិញយើងឃើញថា ប្រព្រឹត្តទៅបានល្អ ក្នុងការបកប្រែហ្នឹង គឺបានពេញលេញណ៎ា។

បាទជាបន្តទៅនេះ អង្គជំនុំជម្រះផ្ដល់វេទិកាជូនទៅសហព្រះរាជអាជ្ញារងអន្តរជាតិ ដើម្បីបន្តការតាំងសំណួរដេញដោលចំពោះសាក្សី។

[១៣:៣៤:៥១]

**លោក វ៉ាំងសង់ វ៉ាយឌ៍ ដេស្នាឯល៖**

សូមអរគុណលោកប្រធាន។ សូមគោរពលោកប្រធាន លោក លោកស្រីចៅក្រម។

**សួរដោយលោក វ៉ាំងសង់ វ៉ាយឌ៍ ដេស្នាឯល៖**

**ស៖** ដើម្បីបំភ្លឺបញ្ហាឱ្យបានច្បាស់ ខ្ញុំនឹងព្យាយាមបន្តសួរសំណួរទៅទៀត រហូតទៅដល់ម៉ោងបួន

ហើយស្អែក គឺសហមេធាវីនាំមុខនឹងសួរលោករហូតទៅដល់ម៉ោងប្រាំបួនសែសិបប្រាំ។ ខ្ញុំចង់សួរលោកពាក់ព័ន្ធទៅនឹងតួនាទីរបស់លោកនៅក្នុងមន្ទីរសន្តិសុខអូរកន្សែង។ ខ្ញុំបានរកឃើញសម្រង់ដែលខ្ញុំចង់សួររកមុននេះហើយ។ លោកបានឆ្លើយថា លោកជាសមាជិក ហើយ ទឹម ជាអនុរបស់ តាសែ។ នៅក្នុងកំណត់ហេតុ E3/5512 សំណួរ-ចម្លើយទី៤៖ “សូមលោករៀបរាប់ពីរចនាសម្ព័ន្ធមន្ទីរសន្តិសុខអូរ-កន្សែង?” ពេលនោះលោកឆ្លើយដូចតទៅ ខ្ញុំសូមដកស្រង់៖ កម្មាភិបាលគ្រប់គ្រងនៅមន្ទីរនេះ មានចំនួនបីនាក់ គឺមានឈ្មោះ សែ ជាប្រធានគ្រប់គ្រងរួម, មានខ្ញុំ <> ជាអនុប្រធានទទួលបន្ទុកសួរចម្លើយ និងរៀបចំឯកសារអ្នកទោស និងឈ្មោះ ទឹម ជាសមាជិក ជាអ្នកចាត់ចែងកងសន្តិសុខ និងយាមកាម (ស្លាប់ឆ្នាំ១៩៧៩)។” សូមបញ្ចប់ការដកស្រង់។ ដូច្នេះសូមឲ្យលោកបញ្ជាក់ជាថ្មីម្តងទៀត ពីព្រោះក្នុងនេះចម្លើយរបស់លោក គឺវាផ្ទុយគ្នាហើយ។ តើលោកជាអនុប្រធានមន្ទីរសន្តិសុខ ឬក៏ជាសមាជិកមន្ទីរអូរកន្សែងនេះ?

[១៣:៣៧:០៥]

**2-TCW-900៖**

**ឆ៖** តួនាទីខ្ញុំពិតនៅក្នុងមន្ទីរសន្តិសុខអូរកន្សែងនេះជាសមាជិក។ ឯ សែ ជាប្រធាន ហើយ ទឹម ជាអនុប្រធាន។

**ស៖** បាទ សូមអរគុណ។ នៅមន្ទីរសន្តិសុខអូរកន្សែងតើ សារឿន ជាប្រធានកងពល៨០១ មកទស្សនកិច្ចទេ? គាត់ធ្លាប់មកយ៉ាងហោចណាស់ក៏ម្តងទេ ឬក៏មិនដែលមកទាល់តែសោះ?

**ឆ៖** លោក តាសារឿន តាំងពីមានកើតមន្ទីរសន្តិសុខអូរកន្សែង គាត់មិនដែលមកកន្លែងហ្នឹងម្តងទេ។

**ស៖** តើមេដឹកនាំវរសេនាតូចភ័ស្តុភារ៨០៦ ដែលក្នុងនោះលោកថាមាន តាស្មៀន, <តាម៉ុន–អឹម-អូ-អិន> ជាដើមនោះ តើអ្នកទាំងអស់នុ៎ងធ្លាប់មកប្រជុំនៅមន្ទីរសន្តិសុខអូរកន្សែងហ្នឹងទេ?

**ឆ៖** អ្នកគ្រប់គ្រងនៅវរសេនាតូចលេខ៨០៦ ពីដើមមាន តាស្មៀន ចេញចូលមកប្រជុំនៅមន្ទីរសន្តិសុខអូរកន្សែង។

**ស៖** ពេលប្រជុំហ្នឹង <> គេប្រជុំជាមួយនឹងបុគ្គលិកមន្ទីរសន្តិសុខហ្នឹង គេប្រជុំពីរឿងអីដែរ?

**ឆ៖** ការប្រជុំហ្នឹងមានប្រជុំជីវភាពប្រចាំខែ ហើយនិងប្រជុំផ្ទៃក្នុង។ ភាគច្រើន គឺប្រជុំផ្ទៃក្នុង ហើយប្រជុំអំពីការងារនៅក្នុងសន្តិសុខ ច្រើនតែប្រជុំណែនាំថាធ្វើម៉េចកុំឲ្យមានអ្នកទោសរត់ចេញពី

កន្លែងឃុំឃាំង។

[១៣:៤០:០៧]

**ស៖** ក្នុងករណីមានអ្នកទោសរត់គេច ខ្ញុំមិនដឹងថា តើមានអ្នកណារត់រួចពីមន្ទីរហ្នឹង ឬក៏អត់ទេ ក៏ប៉ុន្តែគេមានប្រាប់លោកទេថា <លោកនឹងត្រូវ>ដាក់ទណ្ឌកម្មទេ ប្រសិនបើមានអ្នកទោសរត់រួចនោះ?

**ឆ៖** នៅមន្ទីរសន្តិសុខនេះ ខ្ញុំដឹងអ្នកទោសរត់ហ្នឹងមានឈ្មោះ ម៉ៅ ហើយរត់ទៅៗខាងលិចមន្ទីរហ្នឹងទៅភូមិមួយ គេហៅភូមិឈ្មួយ។ ហើយការចាប់មកវិញ គឺប្រជាជននៅភូមិហ្នឹង ចាប់មកប្រគល់នៅមន្ទីរហ្នឹងតែម្តង។

**ស៖** ពេលចាប់ ម៉ៅ បានវិញហ្នឹង គេយកទៅដាក់ក្នុងគុកអ្នកទោសធ្ងន់ ឬយ៉ាងម៉េច ដោយសារតែ ម៉ៅ ហ្នឹងបានរត់គេចនោះ?

**ឆ៖** ក្រោយពេលប្រជាជនចាប់ឈ្មោះ ម៉ៅ បានមកប្រគល់ឱ្យកងសន្តិសុខនោះ កងសន្តិសុខយកទៅដាក់នៅកន្លែងផ្ទះជាមួយអ្នកដែលមានដាក់កងជើង ដាក់ច្រវាក់អីហ្នឹង ដាក់ជាមួយគ្នាហ្នឹង។

**ស៖** ដើម្បីបញ្ចប់អំពីរឿងនេះ តើរហូត<>ទៅដល់ចុងឆ្នាំ ៧៨ នោះ តើ ម៉ៅ ហ្នឹងនៅរស់ទេ ឬក៏គាត់ស្លាប់?

**ឆ៖** ៧៨ ម៉ៅ ហ្នឹងអត់ទាន់ស្លាប់ទេ នៅរហូតដល់ ១កាន់អាវុធប្រយុទ្ធជាមួយកងទ័ពវៀតណាមទៀត។

[១៣:៤៣:០៣]

**ស៖** លោកបាននិយាយថា តាស្មៀន មកមន្ទីរសន្តិសុខអូរកន្សែងដើម្បីចូលរួមក្នុងការប្រជុំ ជាពិសេសប្រជុំ អំពីដំណើរការផ្ទៃក្នុង <អាចថាជាមួយថ្នាក់ក្រោមគាត់ដែរ>។ តើមេដឹកនាំ<អង្គភាព> ៨០៦ មានសិទ្ធិអំណាចក្នុងការកំណត់ថាតើអ្នកណាត្រូវសម្លាប់ចោលនៅមន្ទីរសន្តិសុខអូរកន្សែងដែរឬទេ ឬក៏ការសម្រេចបែបនេះត្រូវធ្វើឡើង ដោយ តាសារឿន តែប៉ុណ្ណោះ?

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយតប! មានការជំទាស់តវ៉ាពីខាងក្រុមសហមេធាវីការពារក្តី។

សូមអញ្ជើញលោកមេធាវីការពារក្តី លោក វ៉ិចទ័រ កូប៉េ!

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណលោកប្រធាន។ ខ្ញុំសូមជំទាស់នឹងសំណួរនេះ។ ទី១ គឺខ្ញុំយល់ឃើញថាគួរតែសួរ

សំណួរបើកសិន។ ខ្ញុំយល់ឃើញថា សាក្សីមិនទាន់ឆ្លើយថាតើការអនុវត្តការសម្លាប់នេះ គេធ្វើដោយរបៀបណា។ ហើយឥឡូវនេះសហព្រះរាជអាជ្ញារងអន្តរជាតិ បែរជាសួរអំពីការសម្លាប់នេះ ការអនុវត្តការសម្លាប់នេះទៅវិញ។ ដូច្នេះសុំធ្វើការជំទាស់ចំពោះការសួរបែបនេះ។

**លោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

លោកប្រធាន ខ្ញុំនឹងត្រឡប់មកនិយាយរឿងនេះនៅពេលក្រោយ។ ប៉ុន្តែឥឡូវខ្ញុំធ្វើតាមដំណាក់កាលម្តងមួយដំណាក់កាល។

[១៣:៤៤:៤៧]

**សួរដោយលោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

**ស៖** លោកសាក្សី តើលោកធ្លាប់ទៅផ្ទះ តាសារឿន ទេ ពេលដែលលោកត្រូវបានចាត់តាំងឲ្យទៅធ្វើការនៅមន្ទីរសន្តិសុខអូរកន្សែងនោះ? ហើយប្រសិនបើធ្លាប់ទៅ តើលោកទៅតែម្នាក់ឯង ឬក៏មានតាសែ ទៅជាមួយលោកដែរ?

**2-TCW-900៖**

**ឆ៖** ក្រោយពេលខ្ញុំមកធ្វើការនៅមន្ទីរសន្តិសុខអូរកន្តែង តាមខ្ញុំចាំ ខ្ញុំទៅផ្ទះ តាសារឿន ទៅលេងប្រពន្ធគាត់ទេ មិនដែលទៅជួប តាសារឿន និយាយពីកិច្ចការអីនៅកន្លែងអូរកន្សែងទេ។

**ស៖** ត្រង់ចំណុចនេះ ខ្ញុំសូមអានសម្រង់ពីរចេញពីកំណត់ហេតុស្តាប់ចម្លើយរបស់លោក។ ទី១ គឺ E3/5607 គឺចម្លើយទី៨។ ខ្ញុំសូមដកស្រង់ លោកបានឆ្លើយដូចតទៅ៖ "ថ្ងៃមួយពេលដែលខ្ញុំទៅលេងប្រពន្ធខ្ញុំនៅវ៉ុនសៃ, <>សារឿន បានប្រាប់ខ្ញុំដោយផ្ទាល់ថា មានមនុស្សម្នាក់មកពីភ្នំពេញ នឹងមកធ្វើការនៅក្នុងអង្គភាពខ្ញុំនៅអូរកន្សែង។ នៅពេលនោះ មន្ទីររបស់ខ្ញុំត្រូវបានផ្ទេរពីបានលុងទៅអូរកន្សែង។" សូមបញ្ចប់ការដកស្រង់។ ហើយខ្ញុំសូមអាននូវសម្រង់ទី២ គឺឯកសារ E3/5512 សំណួរចម្លើយ១១។ លោកបាននិយាយអំពី<ចំនួនជាក់លាក់>ជនជាតិភាគតិចចារ៉ាយដែលត្រូវបានចាប់<ខ្លួន និងឃុំឃាំងនៅ>មន្ទីរសន្តិសុខ<នោះ>។ ខ្ញុំសូមដកស្រង់--

**លោក វិចទ័រ កូប៉េ៖**

ខ្ញុំសូមជំទាស់ការអានសម្រង់ទី២ ក៏ដូចជាសម្រង់ទី១ដែរ ដោយសារកម្មវត្ថុដែលបានយកមកពិភាក្សាគឺថា សហព្រះរាជអាជ្ញារងសួរត្រង់ពាក់ព័ន្ធទៅនឹងជនជាតិចារ៉ាយ។ ទី១ គឺសួរសំណួរបើកពាក់ព័ន្ធទៅនឹងជនជាតិចារ៉ាយនេះសិន មិនត្រូវអានសម្រង់នេះ ហើយសួរចំចំណុចតែម្តងអ៊ីចឹងទេ។

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

[១៣:៤៧:៤៥]

**លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្សាឯល៖**

លោកប្រធាន ខ្ញុំបានសួរសំណួរបើករួចទៅហើយ ពាក់ព័ន្ធទៅនឹងកិច្ចប្រជុំ <ដែលសាក្សីអាចប្រជុំ>ជាមួយ សូ សារឿន។ <>គាត់ថាគាត់អត់ដែល<មាន>ប្រជុំ<>ទេ។ ហើយខ្ញុំអានសម្រង់ចម្លើយរបស់គាត់ ដែលថាគាត់ធ្លាប់ជួប សូ សារឿន។ ហើយខ្ញុំ<នឹង>មិន<>សួរអ៊ីស៊ីជម្រៅពាក់ព័ន្ធទៅនឹងជនជាតិចាវ៉ាយហ្នឹងទេ គ្រាន់តែដកស្រង់នូវចម្លើយរបស់គាត់ ដែលគាត់បាននិយាយថា គាត់បានប្រជុំជាមួយ តាសូ សារឿន នោះ។

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះបដិសេធនូវសេចក្ដីជំទាស់នេះ ព្រោះសេចក្ដីជំទាស់ដូចជាទំនងលឿនពេក ព្រោះមិនទាន់ស្ដាប់នូវការបំណងនៃការតាំងសំណួររបស់សហព្រះរាជអាជ្ញារងអន្តរជាតិផង។ លោកបន្តសំណួរ បើមិនចូលជ្រៅទៅដល់ជនជាតិចាវ៉ាយទេ កម្រិតត្រឹមតែលោកបានលើកអះអាងអម្បាញ់-មិញនេះគឺលោកអាចសួរបាន។ តាំងសំណួរសាជាថ្មីម្ដងទៀត។

**សួរដោយលោក វ៉ាំងសង់ វ៉ាយដ៍ ដេស្សាឯល៖**

**ស៖** សូមអរគុណលោកប្រធាន។ សម្រង់ដែលខ្ញុំនឹងអាននោះគឺចម្លើយលេខ១១ នៅឯកសារ E3/5512។ <ចម្លើយ៖> “ជនជាតិចាវ៉ាយនោះមានចំនួនជាង១០០នាក់”។

[១៣:៤៨:០៧]

**ប្រធានអង្គជំនុំ៖**

អំមិញក៏ ចុះអំមិញថា លោកថាមិនដល់ទៅលើកជនជាតិចាវ៉ាយទេ។ ឥឡូវម៉េចក៏ទៅអានជនជាតិចាវ៉ាយទៅវិញ? លោកសហព្រះរាជអាជ្ញារងអន្តរជាតិ ពេលគេជំទាស់គឺជំទាស់ផ្នែកខាងដែលមិនទាន់សួរបើកពាក់ព័ន្ធនឹងជាមួយនឹងជនជាតិចាវ៉ាយ។ លោកថា សួរហ្នឹងថាមានការប្រជុំជាមួយនឹងឈ្មោះ តាសារឿន ដែរឬទេ? សំណួរគ្រាន់តែដែលប្រជុំជាមួយ តាសារឿន ឬអត់ទេ? ហើយបើលោកអាននូវទៅជនជាតិចាវ៉ាយហ្នឹង គឺដូចជាអានអង្គហេតុប្រាប់ទៅអង្គហេតុហ្នឹងមុនសក្ខីកម្មហ្នឹងរួចទៅហើយ នាំមុខដល់សាក្សីរួចទៅហើយ។ លោករៀបចំសំណួរសាឡើងវិញ បើធ្វើដូច្នេះគឺមិនត្រូវទេ។ វាខុសអ្វីដែលលោកឆ្លើយតបទៅនឹងការជំទាស់របស់សហមេធាវីការពារក្ដី នួន ជា អម្បាញ់មិញនេះ។

**លោក វាំងសង់ វ៉ាយដ៍ ដេស្នាឯល៖**

បាទ លោកប្រធាន ខ្ញុំគ្រាន់តែចង់អានឃ្លាមួយតែប៉ុណ្ណោះ ដើម្បីបង្ហាញថាសាក្សីហ្នឹង គាត់បាននិយាយអំពីការប្រជុំមែន។

**សួរដោយលោក វាំងសង់ វ៉ាយដ៍ ដេស្នាឯល៖**

**ស៖** លោកសាក្សី លោកនិយាយថា៖ "ពេលនោះ តាសឿន បានហៅខ្ញុំ និង សែ ឲ្យទៅជួប" ខ្ញុំសូមបញ្ចប់ត្រង់ហ្នឹង ហើយខ្ញុំនឹងនិយាយអំពីជនជាតិចាវ៉ាយនៅពេលក្រោយ។ ខ្ញុំបានដកស្រង់នូវចម្លើយពីររបស់លោកនៅក្នុងកំណត់ហេតុរបស់លោក។ ទី១ លោកនិយាយថា សូ សារឿន ហ្នឹងបានប្រាប់លោកផ្ទាល់ថា មានមនុស្សមកពីភ្នំពេញម្នាក់នឹងមកធ្វើការនៅក្នុងអង្គភាពរបស់លោក។ ហើយមួយទៀតពាក់ព័ន្ធនឹងជាតិចាវ៉ាយនេះ តាសារឿន នេះបានហៅលោកហើយនិង សែ ហ្នឹងឲ្យទៅជួបគាត់។ ដូច្នេះលោកនឹកឃើញឡើងវិញទេ ថាលោកពិតជាធ្លាប់បានជួប តា<សូ> សារឿន មែននៅពេលនោះ?

[១៣:៥១:០៣]

2-TCW-900៖

**ឆ៖** កន្លែងនេះ ខ្ញុំសូមបញ្ជាក់អំពីការជួបជាមួយ តាសារឿន ហើយគាត់ប្រាប់ថាមានមនុស្សមកពីភ្នំពេញនៅពេលខ្ញុំចេញពីផ្ទះគាត់ ខ្ញុំទៅជួបប្រពន្ធគាត់ លេងជាមួយប្រពន្ធគាត់នោះហើយ និយាយស្ដីលេងជាមួយប្រពន្ធគាត់ហ្នឹងហើយ ខ្ញុំចេញមកជួបគាត់។ ជួបគាត់ គាត់ថាបន្តិចទៀតនឹងមានអ្នកមកពីភ្នំពេញមកជួយការងារនៅកន្លែងហ្នឹង។

**ស៖** បាទ សូមអរគុណ។ យោងតាមសម្រង់ដែលខ្ញុំបានអានជូនលោកស្ដាប់ហ្នឹង មានន័យថាលោកបានជួបគាត់ម្ដងទៀតនៅក្នុងមន្ទីរនៅវ៉ុនសៃហ្នឹង ជាមួយនឹង តាសៃ មែនទេ?

**ឆ៖** បាទ ត្រឹមត្រូវ។

**ស៖** លោកសាក្សី ក្រៅពីមន្ទីរសន្តិសុខអូរកន្សែងនៅក្នុងតំបន់របស់លោក ឬក៏នៅក្នុងភូមិភាគឦសានហ្នឹង តើមានមន្ទីរសន្តិសុខណាផ្សេងទៀតទេ? ទោះបីជាមន្ទីរសន្តិសុខរបស់យោធា ឬក៏មន្ទីសន្តិ-សុខស៊ីវិលក៏ដោយ នៅក្នុងតំបន់១០១, ១០២, <១០៤> ឬ១០៧ នេះ តើលោកដឹងថាមានមន្ទីរសន្តិសុខណាផ្សេងទៀត ឬក៏មន្ទីរអប់រំកែប្រែណាផ្សេងទៀត ក្រៅពីមន្ទីរអូរកន្សែងនេះទេ?

**ឆ៖** ខ្ញុំដឹងមួយកន្លែង ដែលមានគេកាន់នៅភ្នំកាច់ចង្កេះ។ នៅក្រោមការគ្រប់គ្រងរបស់កងពល៨០១ ហើយក្រៅពីហ្នឹង ខ្ញុំអត់ដឹង។

ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។

[១៣:៥២:២៩]

**ស៖** តើមន្ទីរហ្នឹង ដឹងនាំដោយ តាវណ្ណា មែនទេ?

**ឆ៖** បាទ កន្លែងហ្នឹងដឹកនាំដោយ តាវណ្ណា ហ្នឹង។

**ស៖** លោកដឹងទេថាហេតុអីបានជាគេបង្កើតមន្ទីរសន្តិសុខហ្នឹង? ហើយមន្ទីរសន្តិសុខហ្នឹងដាក់អ្នកទោសប្រភេទណា?

**ឆ៖** ខ្ញុំមិនដឹងថា មានមូលហេតុអីដែលនាំឲ្យបង្កើតកន្លែងហ្នឹង។ ខ្ញុំគ្រាន់តែដឹងថា គេបង្កើតកន្លែងមួយនៅមន្ទីរ នៅភ្នំកាច់ចង្កេះក្រោមការដឹកនាំរបស់ តាវណ្ណា ហ្នឹងគឺមានមនុស្ស ហើយមនុស្សហ្នឹងភាគច្រើនចុះទៅធ្វើការនៅការដ្ឋានស្រែ ហើយនិងរៀបចំកាប់ចម្ការ ដាំដំណាំ ពិសេសគឺដាំដំឡូង។

**ស៖** តើអ្នកទោសនៅមន្ទីរអូរកន្សែងដែលស្ថិតនៅក្រោមបញ្ជាកងពល៨០១នេះ មានត្រូវបានគេផ្ទេរទៅកាន់មន្ទីររបស់ តាវណ្ណា នៅជិតភ្នំកាច់ចង្កេះហ្នឹងទេ?

**ឆ៖** មិនមានការផ្ទេរចេញពីមនុស្សដែលនៅក្នុងមន្ទីរសន្តិសុខអូរកន្សែងទៅកាន់កន្លែង តាវណ្ណា ទេ។

**ស៖** ខ្ញុំ ឥឡូវនេះនិយាយអំពីប្រភេទអ្នកទោសនៅមន្ទីរអូរកន្សែង។ នៅអូរកន្សែងពេលដែលលោកធ្វើការនៅទីនោះ តើគេធ្លាប់ឃុំអតីតយោធាលន់ នល់ ឬសមាជិកគ្រួសាររបស់អតីតយោធា ឬក៏មន្ត្រីរដ្ឋការនៃរបបលន់ នល់ទេ?

**ឆ៖** អ្នកដែលមកដល់មន្ទីរឃុំឃាំងអូរកន្សែង មិនមានអតីតទាហានលន់ នល់ ឬក៏អ្នករដ្ឋការធ្វើការពីសម័យនោះទេ អត់ទេ មានតែកងទ័ព ហើយនិងប្រជាជននៅកម្មករសហជីព និងសហករណ៍។

[១៣:៥៦:៥៩]

**ស៖** ចុះទាហាននៃកងពល៨០១ ដែលគេឃុំនៅមន្ទីរអូរកន្សែងនោះ តើពួកគេមានឋានៈ ឋានន្តរសក្តិរហូតទៅដល់ថ្នាក់ណាដែរ ដល់ស័ក្តិប៉ុន្មានដែរ ដែលគេចាប់យកទៅឃុំនៅទីនោះ? ហើយបើសិនជាមានឋានៈខ្ពស់ណាទុំង គេមិនយកមកអូរកន្សែងទេ គេយកទៅមន្ទីរផ្សេង តើមានអីចឹងទេ?

**ឆ៖** អ្នកដែលមកដល់មន្ទីរឃុំឃាំងអូរកន្សែង ថ្នាក់ខ្ពស់បំផុតគឺត្រឹមអនុសេនាធំ ហើយនិងមានអនុសេនាតូច ក្រៅពីនេះជាយុទ្ធជន។

**ស៖** ហើយចុះអ្នកដែលមានឋានៈខ្ពស់ជាងនេះ ដែលគេចាប់ខ្លួនបាននោះ តើគេនាំយកទៅកន្លែងណា?

**ឆ៖** អ្នកមានឋានៈខ្ពស់ គេចាប់ ខ្ញុំអត់ដឹងថា គេនាំយកទៅណា។

**ស៖** តើទាហាននៃកងពល៨០១នោះ ត្រូវបានចាប់ខ្លួនដោយអ្នកណាដែរ មុនបញ្ជូនមកមន្ទីរអូរកន្សែងនោះ?

**ឆ៖** អ្នកដែលបញ្ជូនមកមន្ទីរសន្តិសុខអូរកន្សែង គឺជាការបញ្ជូនមកពីកងវរសេនាធំនីមួយៗ ដូចជាវរៈ៨២, វរសេនាធំ៨៣, វរសេនាធំ៨១។

**ស៖** លោកដឹងមូលហេតុទេ ថាហេតុអ្វីបានជាគេចាប់ខ្លួនទាហានទាំងអស់ហ្នឹង? គេចោទប្រកាន់ថាមានកំហុសអីខ្លះ? លោកអាចរៀបរាប់ឧទាហរណ៍ ឬក៏មានកំហុសអ្វីខ្លះដែលគេចាប់ខ្លួននោះ?

[១៤:០០:១១]

**ឆ៖** កាលខ្ញុំទៅនៅមន្ទីរសន្តិសុខអូរកន្សែងដំបូង ខ្ញុំជួបប្រទះតែអ្នកដែលគេបញ្ជូនមកពីអង្គភាពចំណុះឲ្យកងពល៨០១ហ្នឹង គឺភាគច្រើនជាយុទ្ធជន។ ហើយនៅពេលបញ្ជូនមក គេតែងតែមានលិខិតអមមួយ ថាអ្នកហ្នឹងសេរី លួចនេះ លួចនោះ ហើយខ្ជិលមិនសូវធ្វើការ។

**ស៖** តើមានអ្នកណាត្រូវបានគេចោទប្រកាន់ថា ជាប់ខ្សែក្បត់ទេ ឬក៏ចោទថាប្រឆាំងទៅនឹងមាគ៌ាបក្សទេ?

**ឆ៖** ក្រោយពីខ្ញុំទៅនៅទុំងបានបន្តិច ដែលកាលពីព្រឹកមិញមានសំណួរមួយថា មានអ្នកធ្វើការមកពីភ្នំពេញមកធ្វើការនៅកន្លែងនេះ ក្រោយពីអ្នកហ្នឹងមកបានមានបញ្ជូនអ្នកដែលមកនៅពីកងមក មកឋានៈជាអនុសេនាធំអី មកដោយគេប្រាប់ថា មានចម្លើយពីភ្នំពេញ។

**ស៖** ខ្ញុំដូចជាមិនយល់ចម្លើយរបស់លោក។ ក្នុងចំណោមទាហាននៅកងពល៨០១ តើមានអ្នកណាមួយចំនួនដែលមានត្រូវបានចាប់ខ្លួន ដោយសារតែគេចោទថា អ្នកទាំងអស់ហ្នឹងប្រឆាំងទៅនឹងមាគ៌ានយោបាយរបស់បក្ស ឬក៏អ្នកទាំងអស់ហ្នឹងបានរិះគន់ ទិតៀនបក្ស ឬក៏មិនស្តាប់តាមបញ្ជារបស់បក្សមានអីចឹងទេ?

**ឆ៖** មិននិយាយថា ជាទាហានចេញពីអង្គភាពគេបញ្ជូនមក ដោយការចោទប្រកាន់ថា ប្រឆាំងនឹងបក្ស ប្រឆាំងនឹងបទបញ្ជា ដូចជានៅប្រជាជនមកពីសហជីព គេថា មិនសូវគោរពមេដឹកនាំនៅក្នុងកន្លែងធ្វើការសហជីពហ្នឹង។ ឯទាហានគឺមានតែចម្លើយពាក់ព័ន្ធនឹងចម្លើយដែលមកពីភ្នំពេញ គេចាប់បញ្ជូនមកហ្នឹង។

[១៤:០៣:៤៩]

**ស៖** ដូច្នេះបើខ្ញុំយល់ច្រឡំទេ តាមរយៈចម្លើយរបស់លោក គឺថាមានការឆ្លើយដាក់នៅទីក្រុងភ្នំពេញ។ អ៊ីចឹងលោកចង់មានន័យថា អ្នកដែលគេចាប់ ហើយនិងឃុំខ្លួននៅភ្នំពេញហ្នឹង បានឆ្លើយដាក់ <ពួកអ្នកទាំង>ហ្នឹង នៅក្នុងចម្លើយសារភាពរបស់ពួកគេ អ៊ីចឹងមែនទេ?

**ឆ៖** បាទ ត្រឹមត្រូវហើយ។ ខ្ញុំលើកឧទាហរណ៍មួយ ដូចជាឈ្មោះ អ្នកទោសមួយនៅឋានៈគាត់ជាអនុសេនាធំ គាត់ឈ្មោះ ផេង ផយ។ គាត់នៅអតីតវរសេនាតូចលេខ វរសេនាតូចរបស់ ឡាយ សារឹម។ ហើយក្រោយពេល ឡាយ សារឹម ត្រូវគេចាប់ខ្លួន បានត្រូវគេចាប់ឈ្មោះ ផេង ផយ ហ្នឹង បញ្ជូនមកមន្ទីរសន្តិសុខអូរកន្សែង។

**ស៖** តើ ផេង ផយ ហ្នឹងជាខ្សែរបស់ <សាយ *(ស៊ីក)*> សារឹម ហ្នឹងឬ<>?

**ឆ៖** តាមការសាកសួរ ផេង ផយ បានផ្តល់ចម្លើយគឺ គាត់ថា គាត់ជាអ្នកនៅក្រោមការគ្រប់គ្រងរបស់ ឡាយ សារឹម។

**ស៖** ដើម្បីបំភ្លឺចំណុចនេះ ខ្ញុំសូមអានអំពីអ្វីដែលអតីតមេលោកបាននិយាយ គឺកំណត់ហេតុស្តាប់ចម្លើយរបស់ សែ គឺឯកសារ E3/405 ចម្លើយទី០៦ ដែលគាត់ឆ្លើយដូចតទៅនេះ ខ្ញុំសូមដកស្រង់៖ "មន្ទីរនេះបង្កើតឡើងដើម្បីដាក់អ្នកទោសដែលជាអតីតយោធានៅកងពល៨០១ ហើយពួកទាំងអស់នេះគេត្រូវចាត់ទុកថា ជាអ្នកមិនគោរពវិន័យ ហើយនិងត្រូវបានគេឆ្លើយដាក់នៅក្នុងចម្លើយសារភាពរបស់អ្នកទោសផ្សេងទៀត។" សូមបញ្ចប់ការដកស្រង់។ តើលោកយល់ស្របនឹងចម្លើយរបស់ សែ នេះដែរឬទេ គឺថាក្នុងចំណោមយោធាដែលគេចាប់នៅក្នុងកងពល៨០១ហ្នឹង គឺមានកងកម្លាំងមួយចំនួនហ្នឹងគាត់មិនគោរពវិន័យ អ៊ីចឹងហើយបានគេចាប់គាត់?

[១៤:០៧:០៣]

**ឆ៖** បាទ ត្រឹមត្រូវចម្លើយនេះ ខ្ញុំគាំទ្រ ពីព្រោះការចាប់មក មានអ្នកមិនគោរពវិន័យ ដូចខ្ញុំបានជម្រាបខាងដើមអ៊ីចឹង។

**ស៖** គាត់ក៏បាននិយាយផងដែរ ថាយោធាទាំងអស់ហ្នឹងត្រូវបានឆ្លើយដាក់ ដោយអ្នកផ្សេងទៀត។ អ៊ីចឹងលោកយល់ស្របជាមួយគាត់ទេ ឬក៏លោកមានមតិផ្ទុយពីហ្នឹង?

**ឆ៖** ខ្ញុំយល់ស្របតាមមតិរបស់គាត់ ថាមានការឆ្លើយដាក់ពីអ្នកផ្សេង។

**ស៖** អ្នកដែលគេចាប់ខ្លួនហ្នឹង ទោះបីជាយោធាក៏ដោយ ឬក៏ជាអ្នកស៊ីវិលក៏ដោយ <តើមានអ្នកដែលមិនមក>ពីកងពល៨០១<ទេ?> លោកថា មានកម្មករ <ឬសមាជិក>សហជីពចម្ការកៅស៊ូផង

ដែរ ឬក៏ជាសមាជិកសហករណ៍ផ្សេងៗនោះ តើក្នុងករណីទាំងអស់ហ្នឹង តើគេមាននីតិវិធីចុះឈ្មោះអ្នកទោសដែលទើបនឹងចូលមកដល់មន្ទីរសន្តិសុខ អូរកន្សែងហ្នឹងទេ? មានបញ្ជីទេ គេធ្វើបញ្ជីចុះឈ្មោះអ្នកទាំងអស់ហ្នឹងទេ ពេលមកដល់?

**ឆ៖** នៅពេលគេបញ្ជូនមកដល់មន្ទីរសន្តិសុខ មន្ទីរសន្តិសុខតែងតែធ្វើបញ្ជី ពិសេសអ្នកគ្រប់គ្រងការងារសន្តិសុខ តែងតែធ្វើបញ្ជីឈ្មោះ មកពីអង្គភាពណា មកពីកន្លែងណា។

**ស៖** អម្បាញ់មិញ លោកនិយាយអំពីសំបុត្រ<ដែលមកជាមួយអ្នកទោសនោះ> តើ<តែងតែ>មាន<សំបុត្រ ឬក៏ឯកសារ>ប្រវត្តិរូប<របស់អ្នកជាប់ឃុំហ្នឹង ត្រូវបានគេធ្វើឡើងទេ រួមបញ្ចូលទាំងកំហុសដែលពួកគេត្រូវបានចោទប្រកាន់ផង?>

**ឆ៖** អ្នកដែលទៅសាកសួរនាំ អ្នកដែលមកដល់ដំបូងហ្នឹងគឺ មិត្ត គាត់ទៅសួររកតែព័ត៌មានអំពីប្រវត្តិគាត់នៅក្នុងក្រុមណា អង្គភាពណា ជាអង្គភាពរបស់គាត់ហ្នឹង។ ហើយគេអាចសួរនាំខ្លះអំពីហេតុអីបានគេចាប់បញ្ជូនមក។

[១៤:១០:២៦]

**ស៖** តើក្រៅពីសំណួរទាំងអស់ហ្នឹង តើលោកមានផ្អែកលើឯកសារសរសេរណាមួយដែលពន្យល់អំពីមូលហេតុនៃការចាប់ខ្លួនអ្នកទោសទាំងអស់នោះដែរឬទេ?

**ឆ៖** ត្រង់ចំណុចនេះ ខ្ញុំអត់ដែលមានភស្តុតាងអីជាក់លាក់នៅពេលដែលគេបញ្ជូនមកដល់មន្ទីរនេះទេ។ ពេលខ្លះក៏ទទួលបញ្ជូនបញ្ជីឈ្មោះ ឧទាហរណ៍ខ្ញុំថាឈ្មោះ“ក” អ៊ីចឹងឋានៈជាយុទ្ធជន សកម្មភាពសេរី លួច ហើយខ្ជិល។ ហើយមួយទៀត ឧទាហរណ៍មួយទៀត ឧបមាឈ្មោះ “ខ” សកម្មភាពរបស់គាត់មិនគោរពការចាត់តាំង ពុតត្បុត ហ្នឹងមានកម្រិតប៉ុណ្ណឹង។

**ស៖** ប៉ុន្តែនៅក្នុងឯកសារទាំងអស់ហ្នឹង តើមានដែលគេនិយាយអំពីយោធា ជាពិសេសហ្នឹងដែលមកពីកងពល៨០១ គេចាប់ពួកគាត់ហ្នឹង ដោយសារពួកគាត់ខ្សែវៀតណាម ឬក៏គាំទ្រវៀតណាម ឬក៏ជាប់ពាក់ព័ន្ធជាមួយនឹង សេ.អ៊ី.អា ឬក៏ កា.ហ្សេ.បេ អីជាដើម មានករណីហ្នឹងទេ?

**ឆ៖** ខ្ញុំនៅទីនោះ ខ្ញុំអត់ដែលបានឃើញឯកសារដែលគេបង្ហាញជាក់លាក់ថា ឧទាហរណ៍ថាឈ្មោះ “ក” ជាភ្នាក់ងាររបស់វៀតណាម ឬក៏ជាភ្នាក់ងារ សេ.អ៊ី.អា ឬក៏ កា.ហ្សេ.បេ អត់ទេ។

**ស៖** នៅក្រោមរបបកម្ពុជាប្រជាធិបតេយ្យ តើអ្នកណាដែលគេចាត់ទុកថាជាខ្មាំងស៊ីរូងផ្ទៃក្នុង? តើគេដឹងថាអ្នកណាជាខ្មាំងស៊ីរូងផ្ទៃក្នុងហ្នឹងតាមវិធីណា? តើមានលក្ខណៈវិនិច្ឆ័យអីដែលអាចឲ្យយើង

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

ដឹងថា អ្នកណា បុគ្គលណាម្នាក់ជាខ្មាំងស៊ីរូងផ្ទៃក្នុងដែរឬទេ?

[១៤:១៣:៣០]

**ឆ៖** នៅមន្ទីរសន្តិសុខអូរកន្សែង មិនបានវិភាគជ្រៅជ្រះថា អ្នកនេះជាភ្នាក់ងារវៀតណាម អ្នកនេះជាភ្នាក់ងារ សេ.អ៊ី.អា អ្នកនេះជា កា.ហ្សេ.បេ។ ការសួរចម្លើយនៅពេលដែលអ្នកទោសសារភាពថា ខ្លួនជាភ្នាក់ងារ សេ.អ៊ី.អា ហើយចំពោះវៀតណាមមិនសូវមានលេចឮទេ ភាគច្រើនគឺ សេ.អ៊ី.អា។

**ស៖** សូមអរគុណ។ ទាក់ទងទៅនឹងទស្សនទានខ្មាំងនេះ តើលោកធ្លាប់ឮ ឬក៏ធ្លាប់<ឮ>តាសូ សារឿន<អាន>ដែរឬទេ ទាក់ទងទៅនឹងអ្វីដែលត្រូវធ្វើជាអាទិភាពទាក់ទងទៅនឹងខ្មាំងដែលយើងត្រូវកំណត់អត្តសញ្ញាណនៅក្នុងកងពល៨០១នេះ? តើលោកមាននៅចាំសេចក្ដីណែនាំជាក់លាក់ណាមួយដែលពាក់ព័ន្ធនឹងអ្វីដែលត្រូវធ្វើចំពោះខ្មាំង <>ដែល<ត្រូវបានកំណត់អត្តសញ្ញាណនៅក្នុង>កងពល៨០១<ដែរទេ>?

**ឆ៖** ភាសាថាខ្មាំងប្រឆាំងនឹងបដិវត្តន៍ ប្រឆាំងនឹងការងារសង្គមនិយម ខ្ញុំធ្លាប់ជួបប្រទះនៅពេលដែលគេបើកសិក្ខាសាលាចុងឆ្នាំ គឺថាអ្វីដែលមិនរីកចម្រើនដល់បក្ស ដល់ការធ្វើបដិវត្តន៍សង្គមនោះគឺជាសកម្មភាពរបស់ខ្មាំង។ ខ្ញុំលើកឧទាហរណ៍មួយអំពីការស្ទូងស្រូវ។ ស្ទូងស្រូវ វាស្ទូង២តឹក គម្លាតពីគុម្ពមួយទៅគុម្ព ២តឹក។ ហើយបើស្ទូង១ហត្ថ ថាលើសពី២តឹក មានន័យថាប្រឆាំងនឹងមាគ៌ាបដិវត្តន៍។ នេះហើយគេហៅថាខ្មាំងវាប្រឆាំងអ៊ីចឹង។ នេះជាសម្ដីដែលខ្ញុំឮ សូ សារឿន និយាយនៅក្នុងសិក្ខាសាលាចុងឆ្នាំ ឬក៏គេហៅថាបើកវគ្គរៀនសូត្រ។

[១៤:១៦:៥០]

**ស៖** តើលោកចូលរួមក្នុងវគ្គ<>ដែល<ដឹកនាំដោយ> សូ សារឿន<> នៅពេលណាដែរ<>?

**ឆ៖** ខ្ញុំមិនចាំថ្ងៃខែជាក់លាក់ទេ។ ខ្ញុំគ្រាន់តែចាំបានថា តាំងពីខ្ញុំមកនៅមន្ទីរសន្តិសុខអូរកន្សែង ខ្ញុំបានទៅចូលរួមវគ្គម្ដង។

**ស៖** ឥឡូវខ្ញុំសូមត្រឡប់មកនិយាយអំពីរយៈពេលដែលលោកទទួលបន្ទុកខាងវិទ្យុទាក់ទង នៅបញ្ជាការដ្ឋាននៃកងពល៨០១ ហើយនិងខ្ញុំសូមអានសម្រង់មួយផងដែរ ជូនលោកស្ដាប់គឺរបាយការណ៍ឯកសារ E3/1164 ចុះថ្ងៃទី២៥ ខែ<វិច្ឆិកា> ឆ្នាំ<១៩៧៦>។ របាយការណ៍នេះ រឿន នៃគណៈកងពល៨០១ ផ្ញើទៅអ៊ំ៨៩។ ខ្ញុំសូមអានសម្រង់ហ្នឹង ហើយខ្ញុំសូមឲ្យលោកឆ្លើយថាតើលោកស្គាល់ពាក្យដែល តាសារឿន បានប្រើដែរឬទេ ឬក៏សេចក្ដីណែនាំដែលគាត់ធ្លាប់ចេញ? នៅក្នុងឯកសារនេះមាន

ចំណងជើង<លេខ>៤ ដែលហៅ <>“ចំណាត់ការជាអាទិភាព<មួយចំនួន>”។ ហើយឃើញមានសរសេរថាមានចំណាត់ការ<>ចំនួនប្រាំ គឺទំព័រជាភាសាខ្មែរគឺ <00052327><>, ជាភាសាបារាំងគឺ 00532754, ជាភាសាអង់គ្លេសគឺ 00516711។ ខ្ញុំសូមអានវិធានការ ឬក៏ចំណាត់ការនៅក្នុងរបាយការណ៍ វឿន នេះដូចតទៅ សូមដកស្រង់៖ “អ្នកសង្ស័យថា ខ្មាំងត្រូវចាប់ដាច់ខាត។ ២) ចំពោះអ្នកដែលខ្មាំងឆ្លើយដាក់ ត្រូវពិនិត្យឯកសារ ហើយស្នើឲ្យចាប់ខ្លួនជាបណ្ដោះអាសន្ន។ ទី៣ អ្នកសេរីដើរហើរ ឬក៏ល្មើសវិន័យ អប់រំហើយមិនស្ដាប់ត្រូវមានវិធានការដកទុកម្ដុំតាមដាន។ ទី៤ កម្មាភិបាលអនុសេនាធំ និងអនុសេនាតូចមិនសកម្ម ពុតត្បុត ខ្ជិល ត្រូវដកចេញដាច់ខាត។ ទី៥ អ្នកមាននិន្នាការពាក់ព័ន្ធផ្នែកនយោបាយ គឺដកជាបណ្ដើរៗ។ ក្រោយមកទៀតអ្នកដែលល្អ ត្រូវទុកសិន។ អ្នកប្រឆាំង ឬក៏មិនសកម្ម ដកដាក់ម្ដុំ។”

[១៤:២០:៥០]

នៅចុងបញ្ចប់នៃរបាយការណ៍នេះ គឺមានសេចក្ដីបូកសរុប នៅទំព័រចុងក្រោយ ខ្ញុំសូមដកស្រង់៖ “នេះគឺជារបាយការណ៍កងពល៨០១ ចំពោះសកម្ម<ភាព>ខ្មាំង និងវិធានការដូចខាងលើ។ ស្នើសុំមានមតិ និងជួយយោបល់។ យើងខ្ញុំរង់ចាំមតិណែនាំរបស់បក្ស។” សូមបញ្ចប់ការដកស្រង់។

ទាក់ទងទៅនឹង<វិធានការអាទិភាព>ដែល<ស្នើដោយ> វឿន <>ទៅ សុន សេន <ដែលជាអ៊ំ ៨៩ ដើម្បីសុំមតិយោបល់> ហ្នឹង តើ<វិធានការទាំងអស់នេះពាក់ព័ន្ធទៅនឹងការចាប់ខ្លួនកម្មាភិបាល> កងពល៨០១ទាំងអស់ឬ<ទេ?> ហើយចំពោះរូបលោកផ្ទាល់នេះ លោកមាន<ដឹងពី>វិធានការទាំងប្រាំហ្នឹងទេ <ពាក់ព័ន្ធទៅនឹងលទ្ធភាពចាប់ខ្លួន ឬក៏>វិធានការប្រឆាំងនឹងខ្មាំង<>ទេ?

**ឆ៖** បាទ សំណួរនេះ ខ្ញុំសូមឆ្លើយ ក្រោយពេលខ្ញុំមកធ្វើការនៅមន្ទីរសន្តិសុខអូរកន្សែង កិច្ចការដែលមានការណែនាំប្រាំចំណុច ហើយរាយការណ៍ទៅភ្នំពេញ ខ្ញុំអត់ដែលបានដឹងទេ។ ព្រោះក្រោយពេលដែលខ្ញុំមកទទួលការងារនៅអូរកន្សែង កិច្ចការទូរលេខអី ខ្ញុំមិនបានដឹងទេ។

**ស៖** ក៏ប៉ុន្តែវិធានការទាំងប្រាំហ្នឹង ស៊ីគ្នានឹងអ្វីដែលលោកបានសង្កេតឃើញនៅមន្ទីរអូរកន្សែងហ្នឹងដែរឬក៏អត់ ទាក់ទងទៅនឹងអ្នកដែលគេសង្ស័យថា<ជាខ្មាំង ឬអ្នកដែលគេឆ្លើយដាក់> ឬក៏មិនគោរពតាមគោលនយោបាយបក្ស <ឬ>អ្នកដែល<>ត្រូវបានគេចាប់ខ្លួន<ទាំងអស់នោះ>នៅក្នុងកងពល៨០១<នោះ>?

**ឆ៖** អ្នកដែលគេបញ្ជូនមកមន្ទីរសន្តិសុខអូរកន្សែង មានអ្នកខ្លះក៏ស៊ីគ្នានូវចំណុចទាំងប្រាំ។

ចំណុចដែលស៊ីគ្នា ដូចជា អ្នកខ្ជិលច្រអូស មិនសូវគោរពវិន័យ ហើយនិងមានការឆ្លើយពីអ្នកផ្សេង ឆ្លើយដាក់គេអ្នកផ្សេង។ នេះគឺមានស៊ីគ្នាខ្លះ នៅក្នុងចំណុចទាំងប្រាំ។

[១៤:២៤:៤០]

**ស៖** ឥឡូវខ្ញុំចោទសំណួរជាក់លាក់មួយ ទាក់ទងទៅនឹងអ្នកធ្វើការនៅចម្ការកៅស៊ូ ដែលកាលនោះគេហៅថា ពួកសហជីព។ <ពួកសហជីពមួយចំនួនត្រូវបានចាប់ខ្លួន> ហេតុអ្វីបានជាអ្នកសហជីពទាំងអស់នោះ ត្រូវបានគេចាប់ខ្លួន តើមានមូលហេតុអ្វី? តើគេសង្ស័យថា ពួកគាត់ជាប់ពាក់ព័ន្ធនឹងបណ្តាញណាមួយ ជាប់ខ្សែរយៈនឹងបណ្តាញណាមួយ ឬក៏យ៉ាងម៉េច?

**ឆ៖** កម្មករសហជីពដែលត្រូវបានបញ្ជូនមកមន្ទីរសន្តិសុខអូរកន្សែងនេះ តាមប្រធានសហជីពឈ្មោះ ទុំ បានជួបខ្ញុំនៅ មិនមែនជាកន្លែងខ្ញុំ ឬក៏មិនមែនជាកន្លែងគាត់ទេ ពេលនុំងខ្ញុំដើរតាមផ្លូវទៅគាត់ត្រូវទៅបរកែវ ហើយជួប។ គាត់ថា ពួកហ្នឹងជាសមាសភាពដែលធ្លាប់ធ្វើកម្មករពីសម័យមុន ពីព្រោះពីមុនមានចម្ការកៅស៊ូគ្រប់គ្រងដោយ នាយទុនណាខ្ញុំអត់ដឹងទេ ប៉ុន្តែគាត់ប្រាប់ថា អ្នកដែលធ្លាប់ធ្វើកម្មករពីសង្គមចាស់ ពួកហ្នឹងមិនសូវជាគោរពតាមវិន័យរបស់អង្គការទេ។ វាឃ្លានថ្មើរណា វាចេញទៅរកនេះរកនោះ ស៊ីតាមអំពើចិត្តវា ហើយយើងអប់រំអត់ដែលធ្វើតាមយើងទេ។ ហើយសូមឲ្យខាងមិត្តហ្នឹង សួរនាំពួកគាត់ទៀតទៅ។

**ស៖** តើការចាប់អ្នកសហជីពនៅចម្ការកៅស៊ូហ្នឹងមិនប៉ះពាល់ដល់ផ្នែកសេដ្ឋកិច្ចទេឬ ជាក់ស្តែងគឺសមត្ថភាពនៃការបង្កបង្កើនផលនោះ បើចាប់គាត់អស់ទៅហើយ អត់មានប៉ះពាល់អីផ្នែកសេដ្ឋកិច្ចទេឬ?

[១៤:២៧:៣៤]

**ឆ៖** កន្លែងហ្នឹងខ្ញុំដូចអត់អាចបំភ្លឺបានថា វាប៉ះពាល់សេដ្ឋកិច្ចនៅក្នុងអង្គភាពសហជីពហ្នឹងយ៉ាងម៉េច ៗខ្ញុំអត់ដឹងដែរ។

**ស៖** តើមានភាពខុសគ្នាដែរឬទេ នៅពេលដែលយោធា ហើយនិងជនស៊ីវិលទៅដល់មន្ទីរអូរកន្សែង? តើអ្នកដែលទើបនឹងមកដល់<ថ្មី>ហ្នឹង <ត្រូវបានគេដាក់ខ្នោះជើង ខ្នោះដៃ ឬក៏>មានលក្ខណៈខុសគ្នា<>?

**ឆ៖** កាលដែលខ្ញុំឃើញគេបញ្ជូនមនុស្សមកពីមូលដ្ឋាន ដូចជាសហជីព គឺមកអត់មានចងអីមកដើរមក មានសាក់កាដូខ្មៅ ស្ពាយនៅខ្នងហ្នឹង ខ្លះបង្វេចទូលនៅនឹងក្បាលហ្នឹង ហើយបើជនជាតិ

ដើមភាគតិចគាត់ស្ពាយកាផា ស្ពាយអីមកជាមួយហ្នឹង។ ឯកងទ័ព អ្នកខ្លះមកជិះឡានមកអ៊ីចឹងមក ចុះពីលើឡានមិនមានចំណងមានអីទេ។ ខ្ញុំឃើញចងជាក់ស្តែងមានម្នាក់ពីរនាក់ ហើយខ្ញុំបានទៅស្រាយផ្ទាល់ដៃតែម្តង ឃើញហើម។ វាអាណិតគ្នាដោយសារខ្ញុំស្គាល់ គាត់ហ្នឹងឈ្មោះ ដំ ហើយជាពេទ្យ ហើយចរិតស្លូតបូត។ ហើយខ្ញុំឃើញនៅក្រោយឡានហ្នឹង ឃើញដៃគាត់ហើម ខ្ញុំហួសចិត្តថា ហេតុអីបានជាគេចងអ៊ីចឹង។

**ស៖** នៅពេលដែលពួកគេត្រូវបាននាំទៅអូរកន្សែង តើគេយកពួកគាត់ទាំងអស់ទៅដាក់ក្នុងបន្ទប់ ឬក៏គេយកទៅដាក់ខ្នោះ -- ដាក់ខ្នោះជើង<> ឬក៏មានរបៀបឃុំឃាំងបែបផ្សេងទៀត?

[១៤:៣០:៣៥]

**ឆ៖** នៅពេលអ្នកដែលគេបញ្ជូនមកដល់មន្ទីរឃុំឃាំងអូរកន្សែង ទៅដល់ភ្លាម អត់មានដាក់ខ្នោះ ឬដាក់ច្រវាក់អីទេ។ លើកលែងតែគេបញ្ជូនមកដោយមានការប្រុងប្រយ័ត្ន ដូចជានៅលើឡានមានគេបញ្ជូនមក មានកាំភ្លើងមានអី ម្នាក់ពីរនាក់នៅអមជាមួយ អាហ្នឹងចុះភ្លាមសន្តិសុខគេដាក់ច្រវាក់។ ជាក់ស្តែងដូចជាឈ្មោះ ផេង ផយ នៅពេលដែលគេបញ្ជូនមកហ្នឹងគឺមានយោធាម្នាក់ពីរនាក់ អមនៅលើឡានហ្នឹង ហើយចុះពីលើឡានហ្នឹងក៏គេចងដៃក្រពាត់ទៅក្រោយ ហើយចុះពីលើឡានហ្នឹងស្រាយចំណងស្រាយអីហើយបាន ចាប់ដាក់ច្រវាក់ ចង ដាក់ច្រវាក់ជើង។

**ស៖** ដើម្បីឱ្យច្បាស់ទាំងអស់គ្នា ខ្ញុំនិយាយអំពីពេលដែលគាត់ទើបតែទៅដល់អគារដែលគេទុកសម្រាប់ដាក់អ្នកទោសនៅមន្ទីរអូរកន្សែងហ្នឹង។ អ៊ីចឹងខ្ញុំសួរលោកថានៅយប់ទី១នោះ ឬក៏ថ្ងៃទី១ហ្នឹងគេមានចងពួកគាត់ដែរឬទេ ឬក៏គេដាក់ច្រវាក់គាត់ដែរឬទេ?

**ឆ៖** ដូចខ្ញុំបានជម្រាបអម្បាញ់ហ្នឹងថា យប់ទី១ហ្នឹង អត់មានដាក់ច្រវាក់អីទេ លើកលែងតែអ្នកទោសម្នាក់ដែលខ្ញុំបានជម្រាបពីខាងដើមហ្នឹង។ ដោយសារមានយោធាអី មើលទៅហាក់ដូចជាមានការប្រុងប្រយ័ត្នណាស់។ អ៊ីចឹងនៅពេលដែលមកដល់ គឺដាក់ច្រវាក់ គឺអ្នកទោសឈ្មោះ ផេង ផយ ហ្នឹង។

**ស៖** លោកសាក្សី ខ្ញុំស្តាប់ចម្លើយរបស់លោកឃ្លាចុងក្រោយអំមិញ ខ្ញុំស្តាប់អត់បាន។ សូមលោក ឆ្លើយម្តងទៀតលោកសាក្សី។

[១៤:៣៣:១៨]

**ឆ៖** ខ្ញុំសូមបញ្ជាក់ឱ្យច្បាស់ នៅពេលដែលគេបញ្ជូនមកពីសហជីព ឬក៏បញ្ជូនមកពីអង្គភាពកងទ័ព។ ទោះជាមកពីសហជីព អត់មានចំណងចងអីទេ គឺមកដើរ ហើយមានអ្នកនាំមក ម្នាក់មកប្រគល់

នៅមន្ទីរហ្នឹង។ ឯចំពោះកងទ័ព ៗច្រើនតែមកតាមឡាន។ តាមឡានមានមុខសញ្ញាពីរ មុខសញ្ញាមួយមកពីខាងផ្នែកបរកែរ ភាគច្រើនមកតាមឡានដឹកអ្នករបួស ឬអ្នកឈឺ មកចូលមកកន្លែងហ្នឹង ហើយជួនភាគច្រើនមិនមានចងអីទេ។ ហើយអ្នកដែលចង មកដល់មន្ទីរឃុំឃាំងហ្នឹងមានឈ្មោះ ផេង ផយ ឋាន: គាត់ជាអនុសេនាធំ។ ហើយយប់ទី១ គឺដាក់ច្រវាក់គាត់ ដោយសន្តិសុខគេឃើញថាមានការប្រុងប្រយ័ត្នពីកងឃោធា ដែលគេបញ្ជូនមកហ្នឹងមានកងឃោធាម្នាក់ពីរនាក់ឈរពីក្រោយឡានហ្នឹង។ ហើយចុះពីលើឡានទៅ ចូលទៅក្នុងបន្ទប់ឃុំឃាំងហ្នឹង គេដាក់ច្រវាក់។ នេះខ្ញុំសូមបញ្ជាក់ជូនប៉ុណ្ណឹង។

**ស៖** ខ្ញុំនឹងសួរខ្លីបន្តិច។ ឥឡូវខ្ញុំសូមអានសម្រង់មួយ។ នេះជាអតីតអ្នកទោសនៅមន្ទីរអូរកន្សែង។ គាត់ពីដើមមកធ្វើការនៅចម្ការកៅស៊ូដែលចាប់នៅឆ្នាំ១៩៧៨។ គាត់ឆ្លើយដូចតទៅនេះថា៖ “សូម្បីតែអ្នកធ្វើការពេលថ្ងៃនោះ ក៏<>ពេលយប់ឡើងគេដាក់ច្រវាក់ដែរ” គាត់ថាគាត់ជាប់ខ្នោះមួយរយៈដែរ ពេលទៅដល់នុ៎ង។

មានសាក្សីមួយទៀតឈ្មោះ សាក្សីឈ្មោះ <ខឹម> ពៅ។ ឯកសារ E3/7684 ជាភាសាបារាំងទំព័រទី៣ អង់គ្លេសភាសា ទំព័រទី៣ដែរ ភាសាខ្មែរ ERN គឺ<00221753> ។ គាត់ឆ្លើយពេលដែលគាត់ទៅដល់មន្ទីរអូរកន្សែងដូចតទៅនេះ គាត់ថា៖ “គេដាក់ខ្នោះជើងខ្ញុំ នៅក្នុងបន្ទប់មួយអស់រយៈពេលមួយខែ មុននឹងគេប្រលែងឲ្យខ្ញុំធ្វើការទៅបោចស្មៅ ឬក៏ដកដំឡូងអីជាដើមនោះ។ ទោះបីកាំបិត ក៏គេមិនឲ្យកាំបិតខ្ញុំដែរ សូម្បីធ្វើការងារហ្នឹង។ អ៊ីចឹងធ្វើការងារហ្នឹង មុតដៃ ហើយខ្ញុំមិនហ៊ានឆ្លើយប្រាប់គេថា មុតដៃទេ។ ពេលដែលខ្ញុំធ្វើការមានឃោធាពីរនាក់ដែលមានកាន់អាវុធច្រើន”។ ហើយនៅបន្ទាប់មកទៀតគាត់ថា៖ “ពេលយប់ឡើង ឃោធាទាំងអស់ហ្នឹងដាក់អ្នកទោសចូលទៅតាមបន្ទប់ ហើយដាក់ខ្នោះ។” សូមបញ្ចប់ការដកស្រង់។

អ៊ីចឹង<តើលោកមាន>ប្រតិកម្ម<យ៉ាងណាចំពោះសម្រង់នេះ?> គាត់ថា គាត់ទៅដល់ភ្លាមហ្នឹងគេដាក់ខ្នោះគាត់ទៅដល់មួយខែឯណោះ មុននឹងគេប្រលែងទៅឲ្យធ្វើការ។ ហើយគាត់ថា ពេលយប់ឡើងគេដាក់ខ្នោះអ្នកទោសទាំងអស់ បន្ទាប់ពីបានធ្វើការពេលពេញមួយថ្ងៃហើយហ្នឹង។ <>

[១៤:៣៧:៤២]

**ឆ៖** ចំពោះចម្លើយរបស់ តាពៅ ៗនេះខ្ញុំស្គាល់ ឮសួរឈ្មោះ ខ្ញុំចាំឈ្មោះគាត់។ ហើយគាត់ចេះជាង ធ្វើជាងអារឈើអារអីហ្នឹងគាត់។ ហើយខ្ញុំស្និទ្ធស្នាលមួយគាត់ណាស់ នៅពេលដែលគាត់ចេញពីកន្លែងដែលគេដាក់ច្រវាក់គាត់។ ខ្ញុំយល់ស្របតាមការធ្វើសក្ខីកម្មរបស់គាត់ថា មកដល់ដំបូងគេដាក់ខ្នោះ

ជើងគាត់មែន។ ប៉ុន្តែក្រោយមក សួរនាំគាត់ទៅ ដូចជាមិនមានអីដែលនាំឲ្យចាប់អារម្មណ៍ចំពោះអំពើប្រព្រឹត្តរបស់គាត់ ហើយក៏ឲ្យគាត់រស់នៅធម្មតា ធ្វើការធម្មតាដូចគេដូចឯង។

**ស៖** ខ្ញុំមានសំណួរខ្លីៗមួយចំនួនទៀតទាក់ទងទៅនឹងអនាម័យ ហើយនិងលក្ខខណ្ឌឃុំខ្លួន។ លោកនិយាយថា មានការសាងសង់អគារ ធ្វើរោង ធ្វើផ្ទះអីហ្នឹងជាអំពីឫស្សី ហើយប្រក់ស្លឹក។ តើបន្ទប់ទាំងអស់នុ៎ង ដំបូលជិតទេ ឬក៏នៅពេលភ្លៀងហ្នឹងលេច? តើនៅពេលនោះៗ ពេលភ្លៀងមានដែលលេចស្រក់លើអ្នកទោសទេ?

**ឆ៖** ដំបូលគត់មត់ ជញ្ជាំងៗឫស្សីបន្ទាំមិនជាគត់មត់ជិត ធ្វើឲ្យកម្តៅ ហើយនិងធាតុអាកាសត្រជាក់អីចូលមក ទប់ទល់បានទេ។ អ៊ីចឹងអ្នកទោសដែលនៅក្នុងរោងនីមួយៗតែងតែដុតភ្លើង ដុតភ្លើងនៅក្នុងរោងរបស់ខ្លួនហ្នឹង ពីព្រោះឲ្យគាត់ចេញទៅធ្វើការ ត្រឡប់មកវិញ គាត់លីឧស មួយចំនួនគាត់ដាក់នៅចង្ក្រានបាយ មួយចំនួនគាត់យកទៅដុត សម្រាប់កម្តៅខ្លួន នៅពេលដែលគាត់ត្រជាក់ពេលយប់ ពីព្រោះនៅតំបន់ហ្នឹង ជិតមាត់អូរ ត្រជាក់ខ្លាំងដែរ។

**ស៖** តើមានសត្វល្អិតដែរឬទេនៅក្នុងរោងហ្នឹង? សូមឲ្យលោកពិពណ៌នាអំពីលក្ខខណ្ឌអនាម័យនៅក្នុងរោងទាំងអស់ហ្នឹង?

**ឆ៖** នៅក្នុងរោងអ្នកទោសសម្រាក បើនិយាយពីសត្វល្អិតហ្នឹង មូសខ្លាំងណាស់ ហើយមិនមានមុងចងពេលយប់ទេ។

[១៤:៤១:២៥]

**ស៖** បាទ ទាក់ទងនឹងអនាម័យ តើលោកអាចជម្រាបជូនតុលាការបានដែរឬទេ ថាអ្នកទោសទាំងអស់ សុទ្ធតែគាត់អាចទទួលបានទឹកយកមកប្រើប្រាស់ គឺថាគាត់អាចងូតទឹកបាន គាត់អាចទៅបន្ទប់អីមានទឹកប្រើប្រាស់ត្រឹមត្រូវ ពេលថ្ងៃក៏ដូចពេលយប់?

**ឆ៖** ចំពោះការប្រើប្រាស់ទឹក នៅមន្ទីរអូរកន្សែងហ្នឹង មិនមានលក្ខខណ្ឌអីចំពោះអ្នកទាំងអស់គ្នាទេ។ ដូចជាយប់ ឲ្យគាត់នោមដាក់បំពង់ឫស្សី ម្នាក់មួយ។ ហើយនៅពេលគាត់ងូតទឹក ក្រោយពេលចេញពីចម្ការមកធ្វើការ គាត់ងូតទឹកនៅអូរ អូរក្រោយផ្ទះហ្នឹង។ ហើយគាត់ងូតដោយខ្លួនគាត់ ហើយទឹកគាត់ស្រេកយប់អី គាត់មានទឹកបំពង់ នៅតំបន់រតនគិរីសម្បូរឫស្សី ឫស្សីផ្តោបធំៗណាស់ មួយសាច់ហ្នឹង ប្រហែលជា៥លីត្រ ៦លីត្រ។ គាត់មានគ្រប់គ្នា។ ជួនកាលអ្នកខ្លះមិនយកទឹក ក៏គាត់ចែកហូប គាត់ចែកគ្នាប្រើប្រាស់នៅក្នុងកន្លែងហ្នឹង។

**ប្រធានអង្គជំនុំ៖**

បាទ ឥឡូវនេះដល់ពេលសម្រាកហើយ អង្គជំនុំជម្រះប្រកាសសម្រាកចាប់ពីពេលនេះតទៅ រហូតដល់ម៉ោងបី សូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការ។

អរគុណលោកសាក្សី ហើយនិងមេធាវីប្រឹក្សាសាក្សី ឥឡូវនេះដល់ពេលសម្រាកហើយ អង្គជំនុំជម្រះប្រកាសសម្រាកចាប់ពីពេលនេះតទៅ រហូតដល់ម៉ោងបី សូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការ។ ដូច្នេះលោកសូមមានវត្តមាននៅកន្លែងផ្តល់សក្ខីកម្ម នៅឲ្យបានមុនម៉ោងបីបន្តិច ដើម្បីត្រៀមខ្លួន។ លោកសាក្សីយល់ទេ?

**2-TCW-900៖**

បាទ យល់លោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ ឥឡូវនេះសម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១៤:៤៤ នាទី ដល់ម៉ោង ១៥:០០ នាទី)*

[១៥:០០:៥៧]

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ សួស្តីលោកសាក្សីតើលោកបានត្រៀមខ្លួនហើយឬនៅ?

**2-TCW-900៖**

**ឆ៖** បាទ លោកប្រធាន ខ្ញុំត្រៀមខ្លួនហើយអស់ហើយ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ហើយជាបន្តទៅនេះ អង្គជំនុំជម្រះផ្តល់វេទិការទៅក្រុមតំណាងសហព្រះរាជ

អាជ្ញា សហព្រះរាជអាជ្ញាអន្តរជាតិ សហព្រះរាជអាជ្ញារងអន្តរជាតិ ដើម្បីបន្តការតាំងសំណួរដេញដោលចំពោះសាក្សី។

**លោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

សូមអរគុណលោកប្រធាន។

**សួរដោយលោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

**ស៖** អម្បាញ់មិញនេះយើងនិយាយថាមានមូសច្រើន ហើយលក្ខខណ្ឌអនាម័យនៅក្នុងរោងដាក់អ្នកទោស<នៅកន្លែងឃុំឃាំងគុកអូរកន្សែង>។ អ៊ីចឹងខ្ញុំសួរលោក ថាតើអ្នកទោសហ្នឹងធ្លាក់ខ្លួនឈឺញ័រញាប់ដែរឬទេ? ហើយបើឈឺហ្នឹង ឈឺនឹងជំងឺអីដែរ?

[១៥:០២:៣៨]

**2-TCW-900៖**

**ឆ៖** អ្នកទោសដែលជួបប្រទះនូវជំងឺ ទី១គ្រុនចាញ់ ហើយទី២ជំងឺគ្រុនពោះវៀន រាករូស ដោយការប្រើប្រាស់ទឹកមិនស្អាត គាត់ហូបទឹកនៅ អត់ដាំ។

**ស៖** តើអ្នកទោសជាទូទៅគាត់ទទួលការព្យាបាលត្រឹមត្រូវពីបុគ្គលិកពេទ្យ ឬក៏អ្នកព្យាបាលហ្នឹងដែរឬទេ?

**ឆ៖** នៅពេលដែលអ្នកនៅក្នុងមន្ទីរឃុំឃាំងហ្នឹងឈឺ ហើយមានកន្លែងហ្នឹងមានពេទ្យម្នាក់មើលអ្នកជំងឺ។ ហើយថ្នាំសម្រាប់ព្យាបាល ច្រើនតែថ្នាំដែលផលិតដោយខ្លួនឯង ដូចជា ពីដើមគេហៅថ្នាំអាចម៍ទន្សាយៗហ្នឹង ផលិតស្លចម្រាញ់ពីឈើ ហើយលាយម្សៅធ្វើជាគ្រាប់ ដូចថ្នាំសម័យ។

**ស៖** តើវាជាការគ្រប់គ្រាន់ដែរឬទេ ក្នុងការធ្វើឲ្យអ្នកទោសទាំងអស់ហ្នឹងរួចផុតពីជំងឺ<ទាំងអស់នោះ> ហើយធ្វើឲ្យគាត់រួចផុតពីជំងឺខ្វះអាហារូបត្ថម្ភ?

**ឆ៖** ទាក់ទងនឹងជំងឺរបស់គាត់ ដោយការប្រើប្រាស់ថ្នាំ មិនមានប្រសិទ្ធភាព ហើយការហូបចុកមិនគ្រប់គ្រាន់ទាក់ទងដល់អាហារូបត្ថម្ភ។ ជំងឺគាត់ចេះតែដាបទៅ ដាបទៅរហូតដល់ស្លាប់។

**ស៖** តើចំពោះអ្នកទោសដែលជាប់ខ្នោះទាំងយប់ទាំងថ្ងៃនោះ អ្នកដែលគេស្ថិតនៅក្រោមការយាមដ៏រឹងមាំមែនទែននោះ តើចំពោះគាត់ហ្នឹង អ្នកដែលមានទោសធ្ងន់ទាំងអស់ហ្នឹងមិនកាន់តែធ្ងន់ធ្ងរទៀតទេឬ ការខ្វះថ្នាំអីសព្វបែបយ៉ាងហ្នឹង?

[១៥:០៦:០០]

**ឆ៖** ចំពោះអ្នកដែលដាក់ច្រវាក់ដែលជាលក្ខណៈធ្ងន់ធ្ងរ ដូចជាមិនសូវមានជួបប្រទះនូវជំងឺធ្ងន់ធ្ងរទេ។ គ្រាន់ថា អ្នកខ្លះថាគ្រុនផ្តាសាយអី ពេទ្យនៅនុំងឲ្យថ្នាំលេបធម្មតា។

**ស៖** លោកនិយាយគឺថា ពួកគាត់ហ្នឹងត្រូវទទួលការប្រព្រឹត្តប្រសើរជាង ល្អជាងអ្នកផ្សេងទៀត ឬក៏លោកចង់និយាយថា ដោយសារគេដាក់ច្រវាក់ជើង<ពេញមួយថ្ងៃ ហើយមិនអាចកម្រើកខ្លួនបាន>អីជាដើមហ្នឹង ធ្វើឲ្យគាត់មានជំងឺ<>ដូចជាហើម<ក>ជើង <ការឆ្លងមេរោគ> ហើម<ជើង>អីជាដើម បញ្ហាសន្លាក់អីជាដើម? តើលោកមានបានសង្កេតឃើញមានបញ្ហាហ្នឹងទេ?

**ប្រធានអង្គជំនុំ៖**

សាក្សីកុំទាន់អាលឆ្លើយតប!

សូមអញ្ជើញលោកស្រីមេធាវីការពារក្តីលោក ខៀវ សំផន!

**កញ្ញា អង់តា ហ្គីសសេ៖**

សូមអរគុណលោកប្រធាន។ អម្បាញ់មិញខ្ញុំឮថា សហព្រះរាជអាជ្ញា <និយាយថា នឹង>កែសំណួរឡើងវិញ។ <>ខ្ញុំ<នឹងជំទាស់>រហូត <បើ>គាត់នាំមុខសាក្សី។

**សួរដោយលោក វ៉ាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

**ស៖** អ៊ីចឹងខ្ញុំសួរម្តងទៀត។ តើអ្នកដែលគេដាក់ច្រវាក់ទាំងយប់ទាំងថ្ងៃ ដែលគាត់កម្រើកមិនបាន គាត់មានដំបៅជើង កជើងត្រង់កន្លែងដែលដាក់ច្រវាក់ហ្នឹង តើមានករណីហ្នឹងកើតឡើងទេ លោក?

[១៥:០៨:១១]

**2-TCW-900៖**

**ឆ៖** នៅកន្លែងដាក់ច្រវាក់ ខ្ញុំមិនដែលជួបប្រទះអ្នកទោសទាំងអស់ហ្នឹងកើតកំបៅ ដោយសារដាក់ច្រវាក់ ឬក៏ដាក់ខ្នោះជើងទេ។

**ស៖** ខ្ញុំសូមចោទសំណួរមួយទាក់ទងនឹងចំនួនអ្នកទោស ដែលជាប់ឃុំឃាំងនៅអូរកន្សែងពេលដែលលោកធ្វើការនៅទីនោះ។ តើលោកអាចប៉ាន់ប្រមាណចំនួនអ្នកទោសបានដែរឬទេ អ្នកទោសគ្រប់ប្រភេទដែលគេយកដាក់ឃុំឃាំងនៅអូរកន្សែងហ្នឹង? គឺខ្ញុំនិយាយតែរយៈពេលដែលលោកធ្វើការនៅទីហ្នឹង គឺថាចាប់ពីខែមេសា ឆ្នាំ<១៩៧៧> រហូតដល់ចប់របប<នោះ>។

**ឆ៖** ខ្ញុំមិនអាចរៀបរាប់ចេញពីឆ្នាំ៧៥មកទេ។ ខ្ញុំទៅគ្រប់គ្រងកន្លែងហ្នឹងក្នុងឆ្នាំ៧៧។ ពី៧៧ដល់មកដល់ចុង៧៨ គឺជារយៈពេលមួយមិនជាវែងប៉ុន្មានទេ។ ហើយចំពោះអ្នកជំងឺ -- អ្នកទោសនៅ

មន្ទីរសន្តិសុខអូរកន្សែងហ្នឹង មិនច្រើនលើសពី២០០ ច្រើនប៉ុន្មានទេ។ ហើយការចាំរបស់ខ្ញុំមិនចាំដល់មានតួលេខជាក់លាក់ទេ ប៉ុន្តែតាមការនឹកឃើញទៅក្រោយវិញនូវចំនួនមនុស្សដែលខ្ញុំឃើញជាប្រចាំរាល់ថ្ងៃមិនជាច្រើនទេ ប្រហែលជាមិនដល់ទៅ២០០ខ្ពស់ទេ។ នេះជាការនឹកឃើញទៅក្រោយវិញ។

**ស៖** បាទ សូមអរគុណ។ ទាក់ទងនឹងចំនួនមនុស្សស្លាប់នៅអូរកន្សែង លោកអាចប៉ាន់ប្រមាណចំនួនអ្នកទោសដែលស្លាប់នៅមន្ទីរអូរកន្សែងបានដែរឬទេ? គឺធៀបនឹងចំនួនអ្នកដែលចូលទៅហើយ និងអ្នកដែលនៅរស់ពេលដែលក្រោយរបបខ្មែរក្រហមបានចប់ទៅ តើលោកអាចផ្តល់តួលេខអ្នកដែលស្លាប់នៅក្នុងមន្ទីរអូរកន្សែងបានដែរឬទេ?

[១៥:១១:២៤]

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយតប!

អញ្ជើញលោកមេធាវី វ៉ិចទ័រ កូប៉េ!

**លោក វ៉ិចទ័រ កូប៉េ៖**

ខ្ញុំហាក់បីដូចជាមិនយល់នូវសំណួរនេះទេ។ <សំណួរនេះ គឺសន្មតថាមិនមានបញ្ជូនមនុស្សចេញ។ តើហេតុអ្វីបានជា មិនសន្មតថា មានការបញ្ជូនមនុស្សចេញខ្លះដែរ?> ពីព្រោះថាសក្ខីកម្មខ្លះបានបញ្ជាក់ថាមានគេបញ្ជូនមនុស្សចេញ។ ដូច្នេះ<ការ>ស្នើសុំ<សាក្សី>ឲ្យផ្តល់ភ័ស្តុតាងពីចំនួនអ្នកដែលគេឃុំខ្លួន ហើយនិង<ក្រោយមក នរណាដែលមិនមានជីវិតរស់>រហូតមកដល់ចុងបញ្ចប់នៃដំណាក់កាលនោះ <ដោយគ្មានការបញ្ជូនចេញ>។ <វាគឺជាសំណួរដែលស្មុគស្មាញសម្រាប់សាក្សីហើយខ្ញុំក៏យល់ឃើញថា មិនមានមូលដ្ឋានអ្វី <ក្នុងការនិយាយថា គ្មានការ>បញ្ជូនចេញនោះ<ទេ>។

**លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្សាងឈល៖**

ខ្ញុំគិតថាមេធាវីការពារក្តីមិនបានស្តាប់សាក្សីនេះទេ។ សាក្សីនេះបាននិយាយថា មិនមានបញ្ជូនអ្នកទោសណាចេញទៅកន្លែងផ្សេងទៀតទេ ទៅមន្ទីរឃុំឃាំងផ្សេងទៀតនោះ <ដូចជាអូរតាង ដែលគ្រប់គ្រប់ដោយ តាវ៉ាន នោះទេ>។

**សួរដោយលោក វ៉ាំងសង់ វ៉ាយដ៍ ដេស្សាងឈល៖**

**ស៖** ឥឡូវខ្ញុំសូមសួរសំណួរឲ្យស្រួលជាងនេះវិញបន្តិច។ អ៊ីចឹងលោកអាចជម្រាបជូនតុលាការបានដែរឬទេថា អ្នកទោសប៉ុន្មាននាក់បានស្លាប់នៅមន្ទីរអូរកន្សែងចន្លោះខែមេសា ឆ្នាំ១៩៧៧ ទៅដល់

ចុងឆ្នាំ១៩៧៨។ គឺសំដៅលើរយៈពេលដែលលោក<>នៅ<ទីនោះ>?

[១៥:១៣:០៤]

2-TCW-900៖

**ឆ៖** អ្នកដែលស្លាប់ដោយជំងឺនៅក្នុងមន្ទីរឃុំឃាំងអូរកន្សែងហ្នឹង ខ្ញុំចាំជាតួលេខមិនគ្រប់គ្រាន់ទេ។ ហើយតាមការឃើញ ដឹង ហើយនិងមើលទៅចាំខ្លះៗ គឺថាមិនមានច្រើនទេ គឺស្លាប់ដោយជំងឺគ្រុនចាញ់ អត់ មិនសូវហូបគ្រប់គ្រាន់ ហើយនិងរាក ភាគច្រើនរាករូសតែម្តង។ មិនលើស១០នាក់ ហើយក៏មិនក្រោមជាង១០នាក់ប៉ុន្មានដែរទេ នេះតាមការ ហើយខ្ញុំក៏គិតថា ខ្ញុំមិនចាំជាតួលេខជាក់លាក់ទេ។

**ស៖** ខ្ញុំសូមអានសម្រង់នូវកំណត់ហេតុស្តាប់ចម្លើយរបស់លោក គឺឯកសារ E3/406 លោកនិយាយច្បាស់ណាស់ចំណុចនេះ គឺជាចម្លើយទី៦ របស់លោក។ សូមដកស្រង់៖ “មានអ្នកទោសស្លាប់ច្រើន គាត់ស្លាប់ដោយសារឈឺ ហើយនិងអាហារហូបចុកមិនគ្រប់គ្រាន់។ ចំពោះអ្នកជាប់ទោសដែលជាប់ច្រវាក់នោះ ហូបមិនគ្រប់គ្រាន់ទេ ស្គមហើយឈឺស្លាប់។ ចំពោះអ្នកទោសដែលធ្វើការធម្មតា ហូបបាយលាយដំឡូងគ្រប់គ្រាន់ ជាពិសេសអ្នកទោសដែលនៅជាមួយខ្ញុំ។ ចំពោះអ្នកទោសដែលយើងកម្ទេចចោលតាមបញ្ជារបស់ថ្នាក់លើ ក្រៅពីវៀតណាម ក្រៅជាជនជាតិចារ៉ាយ មានប្រហែលជាជាង១០នាក់ប៉ុណ្ណោះ ហើយសុទ្ធតែជាយុទ្ធជន។ ដូច្នេះសរុបអ្នកទោសដែលស្លាប់នៅក្នុងមន្ទីរមានចំនួនខ្ទង់រយនាក់មិនដល់១.000នាក់ទេ។” សូមបញ្ចប់ការដកស្រង់។ តើខ្ញុំអានហើយនេះ ធ្វើឲ្យលោកនឹកឃើញអំពីចំនួនអ្នកទោសដែលស្លាប់នៅមន្ទីរអូរកន្សែងនេះដែរឬទេ ព្រោះថាពេលដែលគេសម្ភាសលោកនោះ លោកនិយាយថា មានមនុស្សស្លាប់ខ្ទង់រយនាក់ដែរ?

[១៥:១៥:៥១]

**ឆ៖** នៅពេលដែលមានក្រុមអ្នកមកសម្ភាសខ្ញុំដំបូង សួរពីរឿង សួរខ្ញុំចំតែម្តងថា មានការស្លាប់ដោយសម្លាប់ និងជំងឺរាប់ពាន់នាក់នៅក្នុងមន្ទីរសន្តិសុខអូរកន្សែង។ ខ្ញុំបានជម្រាបប្រាប់គាត់វិញថា ចំនួនពាន់នាក់ ខ្ញុំមិនទទួលទេ ការស្លាប់។ ហើយចំនួនរយនាក់ អាចនឹងមាន ពីព្រោះការចងចាំរបស់ខ្ញុំមិន វាច្រើនឆ្នាំដែរហើយ នៅពេលដែលគេសួរហ្នឹង អស់រយៈពេលច្រើនឆ្នាំហើយ ខ្ញុំក្រឡេកទៅក្រោយវិញ ក៏មានភ្លេចភ្លាំងដែរ។

**ស៖** នៅក្នុងចំណោមមនុស្សខ្ទង់រយនាក់ដែលស្លាប់ហ្នឹង តើជាភាគរយនោះមានប៉ុន្មាននាក់ដែលស្លាប់ដោយជំងឺ ឬក៏ខ្វះអាហារូបត្ថម្ភ ហើយប៉ុន្មានភាគរយដែលស្លាប់ ដោយសារមានគេសម្លាប់

<> គេកម្ទេច អានេះបើតាមខ្ញុំអានកំណត់ហេតុស្តាប់ចម្លើយរបស់លោកនោះ?

**លោក វ៉ិចទ័រ កូប៉េ៖**

*(គ្មានការបកប្រែ)*

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយតប!

សូមអញ្ជើញលោកមេធាវី វ៉ិចទ័រ កូប៉េ!

[១៥:១៧:៣៨]

**លោក វ៉ិចទ័រ កូប៉េ៖**

ខ្ញុំជំទាស់ទៅនឹងការតាំងសំណួរនេះ លោកប្រធាន។ សាក្សីទើបតែឆ្លើយថា តាមការចងចាំរបស់គាត់ ប្រហែលជាមានមនុស្ស១០នាក់ស្លាប់ដោយសារជំងឺ ដូចជា<ការទទួលទានអាហារមិនគ្រប់គ្រាន់> ឬក៏ជំងឺគ្រុនចាញ់។ ហើយក្រោយមក សហព្រះរាជអាជ្ញារងអានសម្រង់នេះឲ្យគាត់ស្តាប់ ប៉ុន្តែខ្ញុំមិនឮសួរសាក្សីឆ្លើយថា មានមនុស្សស្លាប់ដោយសារជំងឺដល់រាប់រយនាក់នោះទេ។ ដូច្នេះការសួរបែបនេះ គឺការសួរនាំមុខហើយ។ អ៊ីចឹងគាត់បានឆ្លើយរួចមកហើយ ថាតាមការចងចាំ គឺមានអ្នកទោសហ្នឹងស្លាប់ប្រហែលជា១០នាក់ ដោយសារជំងឺ។

**លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

លោកប្រធាន ខ្ញុំសូមឆ្លើយតបទៅគាត់។ ខ្ញុំអានសម្រង់គាត់ហើយ សាក្សីគាត់បានបញ្ជាក់ហើយថា មានមនុស្ស<បួនប្រាំ>រយនាក់ស្លាប់នៅអូរកន្សែង ហើយគាត់មិនបាននិយាយថា <>ទាំងអស់គ្នាស្លាប់ដោយសារឈឺ ឬក៏ខ្វះអាហារនោះទេ <ហើយក៏មានការនិយាយអំពីការកម្ទេចដែរ>។ ហើយអ៊ីចឹង ខ្ញុំសួរគាត់អម្បាញ់មិញ ខ្ញុំចង់ឲ្យគាត់ប៉ាន់ប្រមាណថា តើអ្នកដែលស្លាប់ដោយជំងឺហ្នឹង មានប៉ុន្មានភាគរយ ហើយអ្នកដែលស្លាប់ដោយសារគេកម្ទេចនោះ មានប៉ុន្មានភាគរយដែរ? ខ្ញុំគិតថា ខ្ញុំគួរតែត្រូវបានអនុញ្ញាតឲ្យសំណួរបែបនេះ លោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះបដិសេធនូវសេចក្តីជំទាស់របស់មេធាវីការពារក្តីលោក នួន ជា។ លោកមេធាវី វ៉ិចទ័រ កូប៉េ លើសំណួរនេះ។ សំណួរនេះ គឺមានមូលដ្ឋានសមស្រប ដែលអាចសួរបាន។ សាក្សីបើនៅចាំសំណួរ សូមលោកសាក្សីឆ្លើយតបទៅសំណួរដែលសួរ សំណួរចុងក្រោយចំពោះលោក ដោយ

សហព្រះរាជអាជ្ញារងអន្តរជាតិអម្បាញ់មិញនេះ។

[១៥:១៩:៤៣]

**2-TCW-900៖**

**ឆ៖** ខ្ញុំមិនអាចជម្រាបជាតួលេខតាមការប៉ាន់ប្រមាណជាភាគរយអីបានទេ ប៉ុន្តែកាលដែលខ្ញុំជម្រាបនៅក្នុងកំណត់ហេតុដើមថា រយនាក់ហ្នឹង ដោយសារខ្ញុំសរុបទាំងអ្នកដែលត្រូវគេកម្ទេច ទាំងអ្នកដែលមានជំងឺឈឺស្លាប់នៅក្នុងមន្ទីរឃុំឃាំង។ ហើយការសរុបជាភាគរយ ខ្ញុំសុំជម្រាបត្រឹមពាក្យថា អ្នកដែលស្លាប់ដោយជំងឺ គឺមានចំនួនតិចជាងអ្នកដែលត្រូវគេកម្ទេច។

**សួរដោយលោក វ៉ាំងសង់ វ៉ាយដ៍ ដេស្នាឯល៖**

**ស៖** បាទ សូមអរគុណលោកសាក្សី។ ឥឡូវខ្ញុំសូមចោទសំណួរមួយទាក់ទងទៅនឹងការសួរចម្លើយ។ តើលោកមានបានពិគ្រោះចម្លើយសារភាពដែលបញ្ជូនមកពីទីក្រុងភ្នំពេញដែរឬទេ? គឺថាជាចម្លើយរបស់អ្នកទោសដែលគេសួរចម្លើយនៅភ្នំពេញ ហើយលោកផ្អែកលើចម្លើយទាំងអស់ហ្នឹង មកសួរចម្លើយអ្នកទោសនៅអូរកន្សែង តើកាលណោះលោកមានឯកសារចម្លើយសារភាពដែលមកពីភ្នំពេញនៅក្នុងដៃដែរឬទេ ពេលសួរចម្លើយអ្នកទោសនៅមន្ទីរអូរកន្សែងនោះ?

**ឆ៖** ខ្ញុំមិនដែលមានឯកសារនៅក្នុងដៃទាក់ទងនឹងចម្លើយ ពីភ្នំពេញមកកាន់នឹងដៃទេ។ នៅពេលដែលសួរចម្លើយពីអ្នកទោស មានតែ ណូ ឈ្មោះ ណូ ទេ ដែលគេមានឯកសារដែលយកមកពីភ្នំពេញ។ ហើយក្នុងពេលហ្នឹង ណូ ជាអ្នកសួរផ្ទាល់តែម្តង។ ឯខ្ញុំអង្គុយនៅក្បែរគាត់ហ្នឹង កត់នូវចម្លើយដែលគេឆ្លើយមក ហើយក៏កត់អំពីសំណួរដែលគេសួរ ហើយនិងកត់ចម្លើយដែលគេឆ្លើយ។ ហើយចំពោះឯកសារខ្ញុំមិនមាននៅនឹងដៃទេ។

[១៥:២២:៣៧]

**ស៖** អម្បាញ់មិញយើងនិយាយអំពីបុគ្គលម្នាក់ដែលមកពីភ្នំពេញហ្នឹង លោកឲ្យឈ្មោះ គឺឈ្មោះ ណូ។ តើគាត់មកពីភ្នំពេញហ្នឹង ជាមួយចម្លើយសារភាពមកពីភ្នំពេញ ឬក៏យ៉ាងណា? ហើយបើគាត់មានចម្លើយសារភាពមកពីភ្នំពេញហ្នឹង តើជាចម្លើយសារភាពចេញពីមន្ទីរសន្តិសុខណាដែរ នៅទីក្រុងភ្នំពេញហ្នឹង?

**ឆ៖** ខ្ញុំអត់បានសួរនាំគាត់អំពីរឿងថា ចេញពីមន្ទីរសន្តិសុខណាទេ ពីព្រោះខ្ញុំប្រយ័ត្នប្រយែងខ្លួនខ្ញុំ។ ការជីកឫសជីកគល់ ចង់ដឹងរឿងគេច្រើន មិនមានសន្តិសុខសម្រាប់ខ្ញុំតែម្តង អ៊ីចឹងខ្ញុំអត់សួរហ៊ាន

សួរទេ។ ប៉ុន្តែស្អីដែលខ្ញុំឃើញគាត់កាន់ ស្អីដែលគាត់និយាយនៅពេលសួរចម្លើយ គឺគាត់ផ្អែកទៅលើឯកសារដែលគាត់កាន់នៅនឹងដៃ។

**ស៖** តើ តាសែ ហើយនិង តាសារឿន ហ្នឹងមានពិគ្រោះចម្លើយសារភាពដែលចេញមកពីទីក្រុងភ្នំពេញដែរឬទេ?

**ឆ៖** ខ្ញុំមិនដែលឃើញ សែ បានពិគ្រោះពិភាក្សាជាមួយ ឈូ និងជាមួយខ្ញុំទាក់ទងនឹងចម្លើយដែលមកពីភ្នំពេញទេ។

**ស៖** ទាក់ទងនឹង <តា>សារឿន ខ្ញុំសូមអានឯកសារ E3/5512 ចម្លើយទី១៣ របស់លោក លោកឆ្លើយដូចតទៅនេះ៖ "ចំពោះខ្ញុំវិញ ខ្ញុំបានទទួលកំណត់ហេតុស្តាប់ចម្លើយមួយដែល តា០៥ ឲ្យខ្ញុំ។ ហើយខ្ញុំប្រើវាដើម្បីសួរអ្នកទោសនៅអូរកន្សែង។" សូមបញ្ចប់ការដកស្រង់។ ហើយនៅក្នុងកំណត់ហេតុស្តាប់ចម្លើយរបស់លោកហ្នឹង លោកនិយាយថា តា០៥ ហ្នឹងគឺ តាសារឿន។ ខ្ញុំអានជូនលោកស្តាប់អ៊ីចឹង លោកនឹកឃើញទេ? នឹកឃើញដល់កំណត់ហេតុស្តាប់ចម្លើយមួយនោះ ដែល តាសារឿន ប្រគល់ជូនលោកទេ?

[១៥:២៥:៤៤]

**ឆ៖** ខ្ញុំរកនឹកអត់ឃើញ។

**ស៖** តើ តាសារឿន នៅពេលណាមួយនោះ គាត់មានបានផ្តល់សេចក្តីណែនាំទៅ តាសែ ហើយនិងចំពោះរូបលោកផ្ទាល់ ទាក់ទងទៅនឹងវិធីសាស្ត្រសួរចម្លើយអ្នកទោសដែលមិនព្រមឆ្លើយសំណួរដែលគេសួរទៅពួកគាត់ ហើយដែលមិនព្រមសារភាព? អ៊ីចឹងខ្ញុំសួរលោកថា លោកមានដែលធ្លាប់ទទួលសេចក្តីណែនាំអំពីវិធីសាស្ត្រនៃការសួរចម្លើយដែរឬទេ?

**ឆ៖** ខ្ញុំបានទទួលការណែនាំអំពីវិធីសួរចម្លើយគឺថា ក្នុងការណែនាំ គឺឲ្យអ្នកដែលអ្នកទោសហ្នឹងគឺសរសេរ ហើយយើងដាក់សំណួរទៅឲ្យគេសរសេរ។ ហ្នឹងមានមួយជំហានៗ។ ហើយនៅពេលដែលគាត់សរសេរហើយ យើងយកមកឃើញសំណេររបស់គាត់ហ្នឹង យើងសួរគាត់។

**ស៖** បាទ សូមអរគុណ។ នេះក្នុងករណីដែលអ្នកទោសហ្នឹងសហការជាមួយ គាត់ឆ្លើយ។ ក៏ប៉ុន្តែក្នុងករណីដែលអ្នកទោសមិនព្រមឆ្លើយការពិត តើមានការណែនាំឲ្យអ្នកយាមប្រើកម្លាំងបាយដោយវ៉ៃអ្នកទោស ឬក៏ដោយឆក់អ្នកទោសអីដែរឬទេ? តើ តាសារឿន គាត់មានផ្តល់ការណែនាំបែបហ្នឹងទេ?

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

[១៥:២៨:២២]

**ឆ៖** តាសារឿន អត់ដែលមានណែនាំពីវិធីក្នុងករណីដែលអ្នកទោសរឹងរូសមិនព្រមសារភាពកំហុសរបស់ខ្លួន ហើយមិនផ្ដល់ចម្លើយ។ ខ្ញុំព្ទចែ ណូ – ណូ បានណែនាំទៅកងសន្តិសុខថា ម្នាក់ហ្នឹងនៅពេលដែលឲ្យបាយហូប លាយអំបិលឲ្យប្រៃ។ កាលណាហូបអំបិលប្រៃ ស្រេកទឹកសុំទឹក សុំទឹកគឺសុំកងសន្តិសុខដែលយាមនៅខាងក្រៅហ្នឹងហើយ។ បើសិនណាជាអ្នកទោសហ្នឹងសុំទឹក ណែនាំឲ្យសន្តិ-សុខថា ឆ្លើយការពិតប្រាប់ទៅអង្គការទៅ ហើយគេឲ្យសៀវភៅ ហើយនិងប៊ិកទៅឲ្យអ្នកទោសហ្នឹង។

**ស៖** នៅក្នុងបន្ទប់សួរចម្លើយ តើមានឧបករណ៍ធ្វើទារុណកម្ម ដើម្បីបង្ខំឲ្យអ្នកទោសសារភាពដែរឬទេ?

**ឆ៖** ក្នុងពេលខ្ញុំបំពេញការងារនៅកន្លែងហ្នឹង នៅកន្លែងសួរចម្លើយគ្មានឧបករណ៍ ដូចជាដំបង ដូចជាព្រនង់ ឬក៏ប្រដាប់ឆក់ហ្នឹងអីអត់។

**ស៖** ឥឡូវខ្ញុំសូមអានអ្វីដែលលោកបានឆ្លើយនៅក្នុងកំណត់ហេតុស្ដាប់ចម្លើយ គឺឯកសារ E3/5512 ចម្លើយទី៨ គេសួរសំណួរលោកថា៖ "តើនៅក្នុងមន្ទីរសន្តិសុខអូរកន្សែងហ្នឹងមានឧបករណ៍ធ្វើទារុណកម្មដែរឬទេ?" លោកឆ្លើយពេលនោះថា៖ "មានដែរ ហើយមានឧបករណ៍សម្រាប់ឆក់ផងដែរ មានខ្សែភ្លើងឆក់។ ហើយខ្ញុំឃើញកងសន្តិសុខយកទៅអនុវត្តចំពោះអ្នកទោសដែលជាជនជាតិចារ៉ាយ ដែលពួកគាត់ហ្នឹងត្រូវគេចាប់បាននៅសមរភូមិ។ ហើយក៏មានព្រនង់ តែគេ<>មិនមាននៅកន្លែងហ្នឹងទេ ប៉ុន្តែពេលគេត្រូវការ គេទៅយកព្រនង់ហ្នឹងមកប្រើ។" លោកសាក្សី ខ្ញុំអានជូនលោកស្ដាប់នេះ លោកបានឆ្លើយយ៉ាងដូច្នេះទៅអ្នកស៊ើបអង្កេតនៃសហចៅក្រមស៊ើបអង្កេត។ ខ្ញុំអានអ៊ីចឹងលោកនឹកឃើញទេ?

[១៥:៣១:៤៥]

**ឆ៖** ខ្ញុំនឹកឃើញឧបករណ៍ដែលថា សម្រាប់យកមកឆក់ហ្នឹងគឺធ្វើនៅពេលដែលគេបញ្ជូនជនជាតិចារ៉ាយមក ហើយឃើញសន្តិសុខកាន់ទូរស័ព្ទជំនាន់សង្គ្រាម លន់ នល់ ហ្នឹង ទូរស័ព្ទហ្នឹងច្របាច់ទៅឆក់ ហើយខ្ញុំធ្លាប់ប្រើប្រាស់នៅមន្ទីរកងពលហ្នឹង គឺឆក់ដៃហ្នឹង។ ហើយខ្ញុំឃើញគេយកមក គេដាក់ឲ្យឆក់អាហ្នឹង ច្របាច់ទៅឆក់។

**ស៖** ខ្ញុំសូមអាននូវចម្លើយរបស់ តាឆោម សែ ដែលជាប្រធានមន្ទីរសន្តិសុខអូរកន្សែង គឺឯកសារ E3/405 ចម្លើយ១៤៖ "ពេលខ្លះមានការធ្វើទារុណកម្ម ប៉ុន្តែមិនមែនធ្វើជាលក្ខណៈប្រព័ន្ធទៅ

លើអ្នកទោសទាំងអស់ទេ។ ការធ្វើទារុណកម្មត្រូវបានធ្វើឡើងដើម្បីទទួលបានចម្លើយសារភាពពីអ្នកទោស។ គេធ្វើចំពោះអ្នកទោសណាដែលគេសង្ស័យថា មានលាក់លៀមព័ត៌មានមិនព្រមឆ្លើយការពិត។ ហើយក៏មានការវាយអ្នកទោស ដូចជាការវាយនឹងរំពាត់ ការប្រើចរន្តអគ្គិសនីដើម្បីឆក់ ជាដើម។” សូមបញ្ចប់ការដកស្រង់។ ដូច្នេះនៅទីនេះ ឆោម សែ គាត់មិនបានបែងចែកថា អ្នកទោសហ្នឹងជាជនជាតិចារ៉ាយ ឬក៏អត់ទេ។ អ៊ីចឹងលោកមានប្រតិកម្មយ៉ាងណាទៅនឹងចម្លើយរបស់ ឆោម សែ ពាក់ព័ន្ធទៅនឹងការធ្វើទារុណកម្មយកចម្លើយទៅលើអ្នកទោសដែលថាមិនមានលក្ខណៈជាប្រព័ន្ធនោះ?

**ឆ៖** ខ្ញុំស្ដាប់ការធ្វើសក្ខីកម្មរបស់លោក សែ ទាក់ទងនឹងការធ្វើទារុណកម្ម។ ខ្ញុំស្ដាប់ជាការបូកសរុបរបស់គាត់ ដែលបានធ្វើទារុណកម្មទៅលើអ្នកទោសក្នុងការសួរចម្លើយ។

[១៥:៣៤:៣៥]

**ស៖** ខ្ញុំឈប់សួរត្រង់បញ្ហានេះ ព្រោះថាខ្ញុំមានប្រធានបទផ្សេងទៀតដែលត្រូវសួរលោក។ លោកឆ្លើយថា ក្នុងចំណោមមនុស្សប៉ុន្មានរយនាក់ដែលស្លាប់នៅមន្ទីរអូរកន្សែង គឺភាគច្រើនត្រូវបានកម្ទេចស្លាប់ដោយសារការកម្ទេច។ អ៊ីចឹងខ្ញុំចង់ដឹងថា តើគេសម្លាប់អ្នកទោសទាំងអស់ នៅកន្លែងណា? មានរណ្ដៅដែលគេជីកហើយ<>ទុកសម្រាប់កប់សាកសពមនុស្សដែលគេសម្លាប់ទាំងអស់ហ្នឹង ឬក៏យ៉ាងម៉េច? លោកអាចរៀបរាប់លម្អិតបានទេ អំពីការសម្លាប់មនុស្ស និងទីតាំងកន្លែងដែលគេសម្លាប់នោះ?

**ឆ៖** ខ្ញុំចាំបាននៅពេលដែលគេយកអ្នកទោសទៅសម្លាប់ ភាគច្រើនគេយកពេលយប់។ ហើយអ្នកដែលចេញសកម្មភាពហ្នឹង គឺពីព្រោះខ្ញុំសម្រាកផ្ទះជាមួយគ្នា ដូចជា ទីម, សែ, ខ្ញុំ ហើយនិង ណូ គឺសម្រាកនៅក្នុងផ្ទះតែមួយ បន្ទប់ដោយឡែកៗពីគ្នា។ ប៉ុន្តែនៅពេលហ្នឹង ចាប់ពីម៉ោងប្រហែលជាប្រាំបីឬប្រាំពីរជាងអី ម៉ោងចន្លោះពេលហ្នឹង អត់ឃើញ ទីម ទេ។ នៅពេលដែលធម្មតា មិនមានករណីយកអ្នកទោសទៅសម្លាប់ចោលហ្នឹង ទីម នៅធម្មតា ប៉ុន្តែថ្ងៃដែលគេធ្វើការងារហ្នឹង អត់ឃើញ ទីម ទេ។ ហើយពេលយប់ ខ្ញុំអត់ដឹងថា គេយកទៅសម្លាប់នៅកន្លែងណា ឆ្ងាយ ឬជិត ក៏ខ្ញុំអត់បានសួរនាំគេដែរ។

**ស៖** ខ្ញុំចង់ឲ្យលោកបញ្ជាក់ឲ្យបានច្បាស់ នៅពេលដែលលោកនិយាយថា ទីម មិននៅ<ទីនោះទេ រាល់ពេលដែល>គេសម្លាប់អ្នកទោស លោកចង់មានន័យថាម៉េច? ខ្ញុំយល់ថា ទីម ហ្នឹងជាអ្នកទទួលខុសត្រូវខាងសន្តិសុខ ហើយគាត់<អាច>ជាអ្នកត្រួតពិនិត្យ <ឬក៏ទទួលខុសត្រូវ>ទៅលើការសម្លាប់មនុស្ស។ អ៊ីចឹងខ្ញុំស្ដាប់ត្រូវ ឬមិនត្រឹមត្រូវ សូមលោកបញ្ជាក់ឲ្យបានច្បាស់ត្រង់ចំណុចនេះ។

[១៥:៣៧:២៣]

**ឆ៖** ក្នុងការគ្រប់គ្រងផ្នែកសន្តិសុខ ក្នុងការយកអ្នកទោសទៅសម្លាប់ហ្នឹង ទីម ហ្នឹងហើយ ជាអ្នកទទួលខុសត្រូវ។ តែសំណួរមួយដែលខ្ញុំអត់ទាន់បានឆ្លើយ គឺថាមានរណ្ដៅអីហ្នឹង គឺមានតែរណ្ដៅដែលគេសម្លាប់ជនជាតិហូឡង់ អ្ហ្នា! ជនជាតិចារ៉ាយ ដែលនៅរណ្ដៅ បេ-៥២។ ខ្ញុំដឹងថា កន្លែងដែលគេកប់រណ្ដៅបេ-៥២ នៅពេលឱកាសមួយ ក្រោយពីការកម្ទេចជនជាតិចារ៉ាយអស់ពីកន្លែងទៅ ខ្ញុំពីរបីថ្ងៃក្រោយមក ខ្ញុំដើរទៅតំបន់ខាងលើនេះ ពីព្រោះកន្លែងហ្នឹងមានដើមខ្នុរ ដើមអីផ្លែ អីចឹងខ្ញុំទៅតំបន់នោះធុំក្លិនស្អុយ។ ដល់ធុំក្លិនស្អុយ ខ្ញុំប៉ាន់ប្រមាណថា គេកម្ទេចនៅកន្លែងហ្នឹង។

**ស៖** ខ្ញុំត្រឡប់មកនិយាយអំពីប្រធានបទចុងក្រោយនៃសំណួររបស់ខ្ញុំ គឺពាក់ព័ន្ធទៅនឹងអ្នកទោសជាជនជាតិភាគតិចចារ៉ាយ។ តើមានក្រុមជនជាតិចារ៉ាយតែមួយក្រុមទេ ឬក៏ច្រើនក្រុមដែលត្រូវបានគេនាំមកមន្ទីរសន្តិសុខអូរកន្សែងនៅឆ្នាំ១៩៧៧ ឬ១៩៧៨នោះ?

**ឆ៖** ជនជាតិចារ៉ាយដែលគេបញ្ជូនមកដល់មន្ទីរអូរកន្សែងហ្នឹង គឺមក ដឹកឡានមកជាម៉ុំមកតែម្ដង ឡានធំ ឡានហ្សេ.អឹម.សេ ហ្នឹង។ មិនដឹងជា តាមខ្ញុំចាំ ដូចជាពីរឡាន ចូលមកយប់ ហើយអ៊ូអែណាស់ ពេលដែលគេបញ្ជូនមកហ្នឹង មនុស្ស ពីព្រោះមនុស្សច្រើន។ ណែន ៗកន្លែងដេកតែម្ដង រកកន្លែងដេកអត់មាន ប៉ុន្តែចេះតែញុកចូលទៅ ដោយសំអាងថា មានទ្វារចាក់សោ។

**ស៖** ខ្ញុំសូមឱ្យលោកបំភ្លឺឱ្យបានច្បាស់ ខ្ញុំចង់ដឹងថាមានការដឹកជនជាតិចារ៉ាយតាមឡានហ្សេ.អឹម.សេ <ពីរគ្រឿង>ហ្នឹង មកតែមួយលើកទេ មួយជើងទេ ឬក៏មានការដឹកមកបន្តបន្ទាប់គ្នាមានច្រើនក្រុម គេចេះតែដឹកមកបន្តបន្ទាប់? តែមួយលើក ឬក៏ច្រើនលើកការបញ្ជូនជនជាតិចារ៉ាយមកមន្ទីរសន្តិសុខនេះ?

[១៥:៤០:៤២]

**ឆ៖** ខ្ញុំអាចភ្លេចភ្លាំងនៅពេលដែលគេបញ្ជូនមក ថាតើជាប៉ុន្មានជើង ឬក៏មកម្ដងទាំងអស់តែម្ដង ប៉ុន្តែគ្រាន់តែដឹងថាច្រើននាក់ដែលបញ្ជូនមកដល់កន្លែងហ្នឹង តាមឡាន ហើយមានកងឃោធា ក្នុងម្នាក់ៗហ្នឹង មួយឡានៗហ្នឹងមានម្នាក់ពីរនាក់មកជាមួយហ្នឹងដែរ។

**ស៖** លោកអាចប៉ាន់ប្រមាណចំនួនជនជាតិចារ៉ាយបានទេ? <លោកបានប្រាប់ខ្ញុំថា មានជនជាតិចារ៉ាយយ៉ាងច្រើន> ដែលគេនាំមកមន្ទីរសន្តិសុខអូរកន្សែងនេះ <តើនាំមកតែមួយលើក ឬក៏ច្រើនលើក>?

**ឆ៖** ខ្ញុំផ្ដល់ចម្លើយជាក់លាក់ជាចំនួនមិនបានទេ ដោយសារខ្ញុំភ្លេចដែរ។ ខ្ញុំគិតថាច្រើនក៏មិន

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឱ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

លើសរយ ហើយក៏មិនក្រោមរយដែរ ក្នុងចន្លោះហ្នឹង។ ហើយបើរយៗ ១១០នាក់ ឬក៏១០៥នាក់អី អាហ្នឹងមិនជាក់លាក់ទេ។

**ស៖** តើលោកចាំរដូវ ឬក៏ឆ្នាំណាដែលថាជនជាតិចាវ៉ាយដែលលោកថា<ជាង១០០>នាក់មកដល់អូរកន្សែងហ្នឹង នៅរដូវណា ឆ្នាំណាដែរ?

**ឆ៖** ខ្ញុំចាំដូចជារដូវវស្សា។

**ស៖** រដូវវស្សាហ្នឹង គឺពេលលោកចាប់ផ្តើមធ្វើការដំបូងនៅឆ្នាំ៧៧ ឬក៏នៅឆ្នាំ៧៨ ពេលដែលវៀតណាមជិតវាយចូលមកហើយ?

**ឆ៖** ចាប់ពីឆ្នាំ ចុង៧៧ មានការឈ្លោះគ្នានៅតាមព្រំប្រទល់ ស្ថិតនៅក្នុងតំបន់ផ្លូវលេខ១៩ ហើយមានការវាយគ្នាខ្លះៗ។ ហើយនៅពេល ក្នុងរយៈពេលហ្នឹងដែលគេបញ្ជូនជនជាតិចាវ៉ាយ មកមន្ទីរឃុំឃាំងអូរកន្សែង។ ហើយការផ្តល់ជាខែជាក់លាក់ ខ្ញុំចាំអត់បានដែរ។

[១៥:៤៤:០៩]

**ស៖** លោកចាំអំពីមូលហេតុ ហើយនិងកាលៈទេសៈនៃការចាប់ខ្លួនជនជាតិភាគតិចចាវ៉ាយនេះដែរឬទេ? លោកដឹងអ្វីខ្លះអំពីការចាប់ខ្លួនពួកគាត់? ហើយលោកដឹងថា តើពួកគាត់ត្រូវបានគេប្រមូលចាប់ប្រមូលផ្តុំដាក់នៅកន្លែងណាមួយសិនទេ មុននឹងបញ្ជូនមកអូរកន្សែងនោះ?

**ឆ៖** តាមការសាកសួរ ជនជាតិចាវ៉ាយទាំងអស់ហ្នឹង ជនជាតិចាវ៉ាយទាំងអស់ហ្នឹង មិនមែនជាជនជាតិចាវ៉ាយដែលរស់នៅក្នុងទឹកដីកម្ពុជាទេ។ ហើយជនជាតិចាវ៉ាយដែលកងយោធានៅខាងមុខហ្នឹងចាប់បញ្ជូនមកនេះ គឺជាជនជាតិចាវ៉ាយដែលរស់នៅក្នុងទឹកដីវៀតណាម។ ហើយចាប់ជនជាតិចាវ៉ាយហ្នឹង មិនមែនចាប់នៅក្នុងទឹកដីវៀតណាមទេ គឺចាប់នៅក្នុងដីកម្ពុជា។

**ស៖** ខ្ញុំចង់សួរលោកថា នៅពេលដែលគេចាប់ខ្លួនជនជាតិចាវ៉ាយហ្នឹង គេមានប្រាប់លោកថាជនជាតិចាវ៉ាយទាំងអស់ហ្នឹង មានកាន់កាំភ្លើង ឬមានអាវុធអីទេ?

**ឆ៖** នៅពេលដែលខ្ញុំទទួលអ្នក ទទួលគេបញ្ជូនជនជាតិចាវ៉ាយមកដល់កន្លែងខ្ញុំ ៗអត់បានទទួលព័ត៌មានថា ពួកទាំងអស់ហ្នឹងមានកាន់កាំភ្លើង កាន់អី អត់ទេ។ វាគ្រាន់តែមក មនុស្សមកហ្នឹង គេថា គេប្រគល់ឲ្យមកតែម្តង។ ហើយមានមនុស្សវ័យកម្រិតត្រឹម២៥ អាយុ២៥, ៣៥ជាង ឬក៏៤០ ហើយមានចាស់ ៗហ្នឹងចន្លោះមនុស្ស ៤០ ៗជាង ៤០ខ្ពស់ជិត៥០ដែរ ម្នាក់ពីរនាក់។

**ស៖** មានស្ត្រី ឬក៏មានយុវនារីទេនៅក្នុងចំណោមក្រុមជនជាតិចាវ៉ាយទាំងអស់នេះ?

**ឆ៖** មានស្ត្រីតិចតួច ហើយខ្ញុំមិនបានបញ្ជាក់អំពីតួលេខចំនួនថាប្រាំនាក់ ឬក៏១០អីទេ ប៉ុន្តែក្នុងចំណោមហ្នឹង គឺប្រុសភាគច្រើន ភាគច្រើនលើសលុបតែម្តង។ ហើយស្រីក៏ប្រហាក់ប្រហែលជាប្រាំទៅប្រាំមួយនាក់ ប៉ុណ្ណឹងទេ។

**ស៖** ខ្ញុំសូមអានទូរលេខមួយពាក់ព័ន្ធនឹងហេតុការណ៍មួយនេះ គឺឯកសារ E3/240 ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ១៩៧៧ ដែលផ្ញើដោយឈ្មោះ វី ទៅ "បងជាទីគោរព" ចម្លងជូន<>--

[១៥:៤៧:៥០]

**ប្រធានអង្គជំនុំ៖**

លោកកុំអាលទាន់! កុំអាល់ទាន់ មានបញ្ហា!

អញ្ជើញលោកមេធាវី វ៉ិចទ័រ កូប៉េ!

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណលោកប្រធាន។ ខ្ញុំសូមជំទាស់ពាក់ព័ន្ធជាមួយនឹងការតាំងសំណួរនេះ ពីព្រោះជាការពិត វាគឺជាសំណួរមួយដែលអង្គជំនុំជម្រះសាលាដំបូង<ត្រូវ>ឆ្លើយតប<នោះ ថាតើ>នៅក្នុងឯកសារ E3/240នោះ <មានអ្វីខ្លះដែលត្រូវធ្វើជាមួយ>នឹង<អ្វី>ដែលសាក្សី<នេះ កំពុង>ផ្តល់សក្ខីកម្ម<នោះ។ នេះគឺវាស្រពេចស្រពិល ហើយវាមិន>ច្បាស់<សោះ>។ ហើយខ្ញុំសូមរំឭក<ទៅអង្គជំនុំជម្រះ គឺ>ពាក់ព័ន្ធទៅនឹងសក្ខីកម្មរបស់អ្នក<ទោសម្នាក់> ដែលស្ថិតនៅក្នុងហេតុការណ៍ ដែលគាត់បានឃើញពាក់ព័ន្ធទៅនឹងជនរងគ្រោះដែលជាជនជាតិចាវ៉ាយ នៅក្នុងខែមីនា ឆ្នាំ៧៨ នោះ។ អ៊ីចឹងចំណុចពាក់ព័ន្ធនឹងទូរលេខនេះ <វាជាប់ពាក់ព័ន្ធទៅនឹងការ>សង្កេតមើល<របស់>សាក្សីហ្នឹង <គឺវាស្រពេចស្រពិល និងមិនច្បាស់> ហើយ គឺវាមិនមានការគាំទ្រភ័ស្តុតាងហ្នឹងច្បាស់លាស់នោះទេ។

**លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

លោកប្រធាន ខ្ញុំបានសួរសំណួរជាច្រើនរួចមកហើយ ពាក់ព័ន្ធទៅនឹងហេតុការណ៍នៃការនាំខ្លួនជនជាតិចាវ៉ាយមកដល់មន្ទីរសន្តិសុខនេះ។ <ខ្ញុំបានសួរអំពីសមាសភាពក្រុម សួរអំពី>រយៈ<ពេល និងសួរអំពីទីកន្លែង>ដែល<គេបញ្ជូនអ្នកទាំងនោះ>មក<ជាដើម>។ ដូច្នេះខ្ញុំគិតថា ឥឡូវនេះខ្ញុំមានសិទ្ធិក្នុងការសួរតទល់សាក្សី ជាមួយនឹងឯកសារមួយនៅក្នុងសំណុំរឿងដើម្បីឱ្យសាក្សីគាត់អាចឆ្លើយតប ថាតើជាហេតុការណ៍ហ្នឹងតែមួយដូចគ្នា ឬក៏ហេតុការណ៍ផ្សេង? ហើយចំពោះកាលបរិច្ឆេទវិញ គឺជាកាលបរិច្ឆេទរបស់ទូរលេខទេ មិនមែនជាកាលបរិច្ឆេទជនជាតិចាវ៉ាយចូលទៅមន្ទីរសន្តិសុខទេ។ អ៊ីចឹងក្នុង

នេះគេគ្រាន់តែនិយាយអំពីចាប់ជនជាតិចារ៉ាយតែប៉ុណ្ណោះ មិនមែននិយាយអំពីការប្រគល់ជនជាតិចារ៉ាយទៅមន្ទីរសន្តិសុខទេ។ ដូច្នេះខ្ញុំសូមការអនុញ្ញាតពីលោកប្រធាន ដើម្បីខ្ញុំអានទូរលេខមួយនេះ ហើយសួរសាក្សីអំពីខ្លឹមសារនៃទូរលេខនេះ ដើម្បីចង់ដឹងថា តើយើងកំពុងតែនិយាយគ្នាអំពីហេតុការណ៍នៃការចាប់ខ្លួនជនជាតិចារ៉ាយនេះតែមួយ ឬក៏យ៉ាងម៉េច?

[១៥:៥០:០៧]

**លោក វ៉ិចទ័រ កូប៉េ៖**

ខ្ញុំពិតជាជំទាស់ពាក់ព័ន្ធទៅនឹងការតាំងសំណួរនេះ ពីព្រោះថាគាត់មិនមែនជាអ្នកទទួលឯកសារ ឬក៏អ្នកសរសេរនោះទេ។ ហើយ<ក្រៅពីសាក្សីជាច្រើនផ្សេងទៀត ដែលបានប្រឈមនឹងការដេញដោល>ពាក់ព័ន្ធទៅនឹងឯកសារស-២១<គាត់គឺជាអ្នកដែលអាចនិយាយអំពីហេតុការណ៍ជនជាតិចារ៉ាយទាំងអស់នោះ>។ ហើយពាក់ព័ន្ធទៅនឹងចំណុចនេះគឺមានន័យថា គាត់សួរនេះនាំមុខសាក្សី ហើយធ្វើឲ្យទាក់ទងទៅនឹងភ័ស្តុតាង<របស់គាត់ ជាមួយនិង>ទូរលេខនេះ។ ហើយខ្ញុំពិតជាមិនអាចទទួលយកបានទេ ចំពោះការតាំងសំណួរបែបនេះនោះ។ គឺគាត់អាចបង្ហាញឯកសារយ៉ាងណាក្ដី គឺវាគួរតែបង្ហាញឲ្យបានលក្ខណៈអព្យាក្រឹត ហើយបង្ហាញធ្វើម៉េចឲ្យវាស៊ីទៅនឹងភ័ស្តុតាង។ យ៉ាងណាក្ដី គឺសហព្រះរាជអាជ្ញាគាត់ធ្វើការនាំមុខសាក្សីហើយ ៗយើងគួរតែរៀបចំឲ្យមានលក្ខណៈអព្យាក្រឹត ហើយគួរតែបង្ហាញឯកសារដែលគាត់ឃើញ។ ហើយខ្ញុំសូមធ្វើការជំទាស់យ៉ាងណាក្ដីនុ៎ង វាគួរតែបង្ហាញឯកសារហ្នឹងឲ្យបានមានលក្ខណៈអព្យាក្រឹត កុំឲ្យដឹកនាំសាក្សី នាំមុខសាក្សីដូច្នេះ។

*(ចៅក្រមពិភាក្សាគ្នា)*

[១៥:៥៣:០០]

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះសម្រេចថា បដិសេធនូវសេចក្ដីជំទាស់របស់មេធាវីការពារក្ដីលោក នួន ជា លោកមេធាវី វ៉ិចទ័រ កូប៉េ ចំពោះការតាំងសំណួរនេះ។ ហើយអង្គជំនុំជម្រះអនុញ្ញាតឲ្យមានការតាំងសំណួរនេះ និងសាក្សីគឺអាចធ្វើការកត់សម្គាល់ទៅនឹងអ្វីដែលបានលើកឡើងក្នុងការសួរចំពោះលោកពាក់ព័ន្ធនឹងសំណួរចុងក្រោយដែលនឹងសួរដោយសហព្រះរាជអាជ្ញារងអន្តរជាតិអម្បាញ់មិញនេះ។

សហព្រះរាជអាជ្ញារងអាចរៀបចំសំណួរចុងក្រោយរបស់លោកសាជាថ្មីម្ដងទៀត ទំនងជាមិនទាន់ពេញលេញទេអម្បាញ់មិញនេះ គឺមានការជំទាស់ជាមុន ហើយនិងសាក្សីក៏មិនទាន់បានស្ដាប់បាន

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

ពេញលេញនូវសំណួរដែលលោកមានបំណងក្នុងការសួរទៅគាត់ដែរ។ សូមអញ្ជើញ!

[១៥:៥៣:៥២]

**សួរដោយលោក វ៉ាំងសង់ វ៉ាយដ៍ ដេស្នាងលៈ**

**សៈ** បាទ លោកប្រធាន ខ្ញុំរៀបនឹងពន្យល់អំពីទូរលេខមួយនេះទៅហើយអម្បាញ់មិញនេះ។ ហើយខ្ញុំរៀបតែនឹងអានសម្រង់មុននឹងសួរសំណួរ។ ដូច្នេះខ្ញុំសូមបញ្ជាក់ម្តងទៀត ឯកសារនេះលេខ E3/240 ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ៧៧ ផ្ញើដោយឈ្មោះ វី "ជូនបងជាទីគោរព" ហើយចម្លងជូនអ៊ំ, អ៊ំនួន, បងវ៉ាន់, បងវន, បងខៀវ។ ជាភាសាបារាំង 00282550, ERN ជាភាសាខ្មែរគឺ 00001266, ជាភាសាអង់គ្លេស <00897665 *(ស៊ីក)*>។ ខ្ញុំសូមដកស្រង់នូវចំណុចទី១ គឺនៅដើមទូរលេខនេះតែម្តង៖ "នៅម៉ោងប្រាំបួនព្រឹក ថ្ងៃទី១៤ ខែមិថុនា (ក្នុងនេះអត់មានដាក់ឆ្នាំទេ ប៉ុន្តែយើងគិតថាឆ្នាំ៧៧) កងផលិត៨០១ ប្រចាំនៅ១០៧ ល្បាតចាប់បានកងទ័ពយួនចំនួន២០៩នាក់។ ក្នុងនោះមាននារីប្រាំបួននាក់ នៅម្តុំអូរល្អក់ខាងត្បូងផ្លូវលេខ៩ ចម្ងាយ៤គីឡូ សឹងទាំងអស់ជាជនជាតិចារ៉ាយ និយាយខ្មែរប៉ៃឡាំ។ បានបញ្ជូនមកទុកដាក់ហើយ។ <ពួកវាថា ពួកវាបានធ្វើ>ជាទាហាន២ទៅ១០ឆ្នាំ<មកហើយ> ហើយពួកវាមានជាប់នឹងខ្លួននោះ ដូចជាកាំភ្លើងអា.កាមួយដើម កាំភ្លើងអ៊ែរកែង<៣ដើម> កាំភ្លើងខ្លី<ពីរដើម> គ្រាប់បែកអាមេរិក<បីគ្រាប់>។ បើតាមយោបល់ខ្ញុំ គឺថាពួកនេះ គឺជាខ្មាំងខាងក្រៅ ដែលរត់មកចូលក្នុងដីយើង។"

ហើយចុះមកក្រោមបន្តិចមកទៀតមក គឺមានការរៀបរាប់អំពីសំណើសុំយោបល់បន្ថែមរបស់អង្គការ។ "អង្គភាពបង្កបង្កើនផល៨០១ហ្នឹង ស្នើឲ្យមានសេចក្តីសម្រេចភ្លាមៗ និងជាស្ថាពរ ហើយខ្ញុំសូមរង់ចាំនូវចម្លើយពីលោក។"

ដូច្នេះក្នុងនេះ គឺគេមានរៀបរាប់អំពីហេតុការណ៍មួយដែលទាហាន២០៩នាក់ ដែលជាទាហានវៀតណាមនោះ បានត្រូវបានចាប់ខ្លួននៅម្តុំអូរល្អក់។ ហើយពួកហ្នឹង គឺភាគច្រើនជាជនជាតិចារ៉ាយ ក្នុងនោះមាននារីហ្នឹងប្រាំបួននាក់។ តើព័ត៌មានមួយនេះ អាចឲ្យលោកជម្រាបយើងខ្ញុំបានទេ ថាអ្នកដែលលោកឃើញគេនាំមកអូរកន្សែងនុ៎ង ត្រូវគ្នាទៅនឹងចំនួនអ្នកដែលគេរៀបរាប់នៅក្នុងទូរលេខមួយនេះទេ?

[១៥:៥៧:២១]

**2-TCW-900៖**

**ឆៈ** ខ្ញុំគិតថា ការផ្តល់សក្ខីកម្មពីមុនថា ចាប់បានទាហានវៀតណាម២០៩នាក់ហ្នឹង ហើយនិង

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

ផ្ទុរផ្ទុងនឹងភាពជាក់ស្តែងដែលនៅកន្លែងខ្ញុំ ហើយខ្ញុំគិតថា វាជាការលើសចំនួន។ ហើយការដែលទទួល ខ្ញុំទទួលនូវកន្លែងខ្ញុំ មិនដល់២០០នាក់ទេ។ ស្ថានភាពជាក់ស្តែង មនុស្ស២០០នាក់ដាក់រោងមិនជាធំប៉ុន្មាន នោះ បណ្តោយប្រហែលជា១០ម៉ែត្រអីហ្នឹង ដាក់អត់អស់ទេ ២០០នាក់ហ្នឹង ហើយទទឹងផ្ទះ៦ម៉ែត្រ ហើយរួមនឹងអ្នកទោសជាទាហានជាអីជាមួយផង ដាក់អត់អស់ទេ។ អ៊ីចឹងចំនួននេះ ខ្ញុំមានប្រតិកម្មថា ជាចំនួនដែល ជាសាក្សីរបស់គេម្យ៉ាង ប៉ុន្តែចំពោះខ្ញុំ ខ្ញុំផ្តល់ថា ខ្ញុំមិនមានតួលេខចំនួននោះទេបាទ។

**ស៖** លោកសាក្សី ខ្ញុំនៅសល់តែពីរបីនាទីទៀតតែប៉ុណ្ណោះ ដើម្បីបំភ្លឺអំពីបញ្ហាមួយនេះ។ ក្រុមមនុស្សដែលលោកឃើញមកដល់អូរកន្សែង តើក្រុមហ្នឹង ត្រូវបានគេចោទប្រកាន់ថា ជាទាហានវៀត-ណាមទេ?

**ឆ៖** មិនមានការចោទប្រកាន់ជាទាហានវៀតណាមទេ។ ការវាយតម្លៃពីសមរភូមិមក គេវាយតម្លៃថា ជាកងទ័ពរបស់ ធីវ គី ក្នុងសម័យសង្គ្រាមមុនឆ្នាំ៧០។

**ស៖** មុននេះបន្តិចលោកនិយាយថា ពួកហ្នឹងមិននៅស្រុកខ្មែរទេ គឺរស់នៅវៀតណាម។ អ៊ីចឹងមានន័យថាអ្នកទាំងអស់ហ្នឹងមានសញ្ជាតិវៀតណាមមែនទេ ហើយត្រូវបានគេចាត់ទុកថាជាជនជាតិវៀតណាមដោយអាជ្ញាធរ កងពល ហើយនិងមជ្ឈិមបក្សមែនទេ?

[១៦:០០:២៧]

**ឆ៖** មើលភាសា សម្តីនិយាយគឺនិយាយជាភាសាចារ៉ាយ ហើយខ្ញុំអត់ចេះភាសាចារ៉ាយទេ។ ហើយការនិយាយគឺគេជាភាសាជនជាតិដើមភាគតិច គឺភាសាចារ៉ាយ និយាយ។ ហើយសាច់ឈាមសម្បុរសម្បកអី ខ្ញុំមើលដូចជាមិនមែនជនជាតិវៀតណាមសុទ្ធសាធទេ គឺជនជាតិរស់នៅតំបន់ភ្នំ ដូចជនជាតិដើមភាគតិចនៅក្នុងរតនគិរីអ៊ីចឹង។

**ស៖** លោកប្រធាន ខ្ញុំសុំពេល៥នាទីបន្ថែមទៀតលោកប្រធាន។ លោកសាក្សីដើម្បីឱ្យច្បាស់ទាំងអស់គ្នា គឺខ្ញុំមិនសំដៅទៅលើជនជាតិភាគតិចនៃក្រុមហ្នឹងទេ គឺខ្ញុំសំដៅទៅលើសញ្ជាតិរបស់ក្រុមនេះ។ លោកយល់ទេ ជនជាតិភាគតិច ហើយនិងសញ្ជាតិហ្នឹងវាខុសគ្នា។ ខ្ញុំចង់ដឹងថាអ្នកទាំងអស់ហ្នឹងជាអ្នកដែលរស់នៅប្រទេសវៀតណាមមែនទេ? ហើយជាអ្នកនិយាយចារ៉ាយ ជាជនជាតិភាគតិចចារ៉ាយខ្ញុំទទួលស្គាល់ ប៉ុន្តែពួកគាត់ហ្នឹងរស់នៅវៀតណាម មែនទេ? ពួកគាត់ជាពលរដ្ឋរបស់វៀតណាមមែនទេ?

**ឆ៖** បើសិនណាជាគាត់ បើពួកគាត់នៅក្នុងទឹកដីប្រទេសវៀតណាម គឺជាជនជាតិវៀតណាម

ហើយ។

**ស៖** មុននេះខ្ញុំបានលើកឡើងអំពីកិច្ចប្រជុំមួយ ដែលលោកបានចូលរួមជាមួយ តាសារឿន ហើយនិង សែ ពាក់ព័ន្ធទៅនឹងក្រុមជនជាតិភាគតិចចារ៉ាយនេះ។ តើ តាសារឿន និយាយអ្វីខ្លះប្រាប់លោក អំពីជនជាតិចារ៉ាយទាំងអស់ហ្នឹង? គាត់មានប្រាប់លោកថា ត្រូវធ្វើយ៉ាងម៉េចចំពោះអ្នកទាំងអស់ហ្នឹង ចាត់វិធានការយ៉ាងម៉េចខ្លះ? ហើយតើជាចុងក្រោយនុ៎ង ជោគវាសនារបស់ជនជាតិចារ៉ាយទាំងអស់ហ្នឹងទៅជាយ៉ាងណាដែរ?

[១៦:០២:៥៦]

**ឆ៖** នៅពេលដែលខ្ញុំបានទៅជួប តាសារឿន (០៥) ប្រធានកងពល៨០១ ជាមួយលោក សែ គាត់សួរនាំអំពីការគ្រប់គ្រង។ តើមន្ទីរសន្តិសុខអូរកន្សែងហ្នឹងគ្រប់គ្រងមនុស្ស ជនជាតិចារ៉ាយហ្នឹងបានទេ? ហើយពេលហ្នឹង សែ បានរាយការណ៍ថា ការគ្រប់គ្រងជនជាតិចារ៉ាយមានចំនួនច្រើនរបៀបនេះ ហើយតាមស្ថានភាពកងសន្តិសុខមានកម្រិតចំនួនមនុស្សតិច មិនអាចគ្រប់គ្រងបានទេ។ ហើយទី២ ការដោះស្រាយជម្រកសម្រាប់ឲ្យពួកហ្នឹងនៅ ក៏លំបាកដែរ។ នេះជាការរាយការណ៍របស់លោក សែ ប្រាប់ទៅ តាសារឿន នៅពេលអង្គប្រជុំ។

**ស៖** ខ្ញុំនៅសល់ពេលតិចណាស់ ដូច្នេះខ្ញុំសូមអានន្ទូវចម្លើយរបស់លោកដែលលោកបានឆ្លើយជូនសហចៅក្រមស៊ើបអង្កេត គឺឯកសារ E3/5512 គឺនៅចម្លើយទី១១ លោកនិយាយអំពីហេតុការណ៍នៃការចាប់ខ្លួនជនជាតិចារ៉ាយ។ លោកថា៖ "ជនជាតិចារ៉ាយហ្នឹង ពិតជាត្រូវបានចាប់ ហើយបញ្ជូនមកឃុំនៅមន្ទីរសន្តិសុខអូរកន្សែងមែន គឺពួកទាហាននៅសមរភូមិអូរយ៉ាដាវជាអ្នកចាប់បញ្ជូនតាមឡានមកមន្ទីរសន្តិសុខអូរកន្សែង ដោយចោទជនជាតិភាគតិចចារ៉ាយទាំងនោះថាជាទាហានធីវគី។ ជនជាតិចារ៉ាយនោះ មានចំនួនជាង១០០នាក់។ ក្នុងនោះមានស្ត្រីប្រហែលជាប្រាំទៅប្រាំមួយនាក់។ ពេលនោះ តាសារឿន ហៅ តា០៥ បានហៅខ្ញុំ និង សែ ឲ្យទៅជួប រួចប្រាប់ថា ឲ្យដោះស្រាយជនជាតិចារ៉ាយទាំងនោះទៅ។ ពេលខ្ញុំត្រឡប់មកមន្ទីរសន្តិសុខវិញ យើងក៏បានប្រាប់ទៅកងសន្តិសុខឲ្យដោះស្រាយអ្នកទោសជាជនជាតិចារ៉ាយទាំងនោះ។ ពាក្យថា "ដោះស្រាយ" នេះមានន័យថា "សម្លាប់ចោល"។" លោកសាក្សី តើលោកនឹកឃើញឡើងវិញទេអំពីអ្វីដែល តាសារឿន ប្រាប់លោក គឺថាត្រូវចាត់ការយ៉ាងម៉េចខ្លះចំពោះជនជាតិចារ៉ាយទាំងអស់នោះ គឺត្រូវតែសម្លាប់ចោល? លោកមាននឹកឃើញទេ?

**ឆ៖** ខ្ញុំនឹកឃើញការណែនាំរបស់ តាសារឿន (០៥) ហ្នឹងចំពោះជនជាតិចារ៉ាយ។ គាត់ ក្រោយ

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

ពី សែ បានរាយការណ៍ដូចខ្ញុំបានជម្រាបពីខាងដើម គាត់សរុបឃោបល់មកថា ដោះស្រាយ។ ហើយពាក្យថា "ដោះស្រាយៗ" គេប្រើអ៊ីចឹង។ ហើយជាការយល់របស់ពួកខ្ញុំ គឺនៅពេលថា "ដោះស្រាយ" គឺសម្លាប់ចោលហ្នឹងហើយ។ ហើយចម្លើយដែលខ្ញុំបានជម្រាបទៅក្រុមការងារដែលមកសួរខ្ញុំហ្នឹង គឺខ្ញុំយល់ស្រប គឺខ្ញុំបាននិយាយប្រាប់គាត់អ៊ីចឹងមែន។ ក្រោយពីមកពីជួប តាសារឿន វិញ សែ បានហៅសន្តិសុខ រួមទាំងខ្ញុំហ្នឹង អង្គុយប្រជុំជាមួយគ្នា ហើយឲ្យដោះស្រាយ។

[១៦:០៧:២២]

**លោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

សូមអរគុណលោកសាក្សី។ ពេលនេះគឺអស់ពេលទៅហើយ អ៊ីចឹងដល់ពេលដែលត្រូវផ្អាកសវនាការ។ សូមអរគុណលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ អរគុណលោកសាក្សី។ សវនាការនៅថ្ងៃនេះដល់ពេលសម្រាកហើយ អង្គជំនុំជម្រះប្រកាសផ្អាកកិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះត្រឹមនេះ។ ហើយសវនាការលើកទៅបន្តធ្វើនៅថ្ងៃស្អែក ថ្ងៃអង្គារ ទី២២ ខែមីនា ឆ្នាំ២០១៦ ចាប់ផ្ដើមពីម៉ោងប្រាំបួនព្រឹក។ ហើយសវនាការនៅថ្ងៃស្អែកនេះ អង្គជំនុំជម្រះនឹងធ្វើសវនាការបន្តស្ដាប់សក្ខីកម្មសាក្សីដែលមានរហស្សនាម 2-TCW-900 តាមប្រព័ន្ធសោតទស្សន៍ សូមភាគីជ្រាប និងអញ្ជើញចូលរួមតាមពេលវេលាបានកំណត់នេះ។

អង្គជំនុំជម្រះអរគុណលោកសាក្សី 2-TCW-900 ហើយដំណើរការសវនាការស្ដាប់សក្ខីកម្មរបស់លោកក្នុងឋានៈជាសាក្សីនៅមិនទាន់ចប់នៅឡើយទេ អង្គជំនុំជម្រះកោះអញ្ជើញលោកមកបន្តផ្ដល់សក្ខីកម្មនៅថ្ងៃស្អែកទៀត ដែលនឹងចាប់ផ្ដើមពីម៉ោងប្រាំបួនព្រឹក។ ហើយអង្គជំនុំជម្រះសូមអរគុណលោក ម៉ម រិទ្ធា មេធាវីប្រឹក្សាសាក្សី។ លោកអាចសម្រាកបានហើយ ៗអង្គជំនុំជម្រះក៏អញ្ជើញលោកមកបន្តអង្គុយក្បែរសាក្សីរូបនេះ ដើម្បីប្រឹក្សាសាក្សីនៅសវនាការនៅព្រឹកថ្ងៃស្អែកទៀត។ លោកសាក្សីលោកចាំដែរទេ? លោកយល់ដែរទេ គឺថាព្រឹកស្អែកទៀត គឺយើងចាប់ផ្ដើមនៅម៉ោងប្រាំបួនព្រឹក ដូចថ្ងៃនេះដែរណ៎ា?

**2-TCW-900៖**

ខ្ញុំយល់លោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ លោកអាចសម្រាកបានហើយណ៎ា។

ហើយតទៅនេះ បង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនជនជាប់ចោទទាំងពីររូប លោក នួន ជា និងលោកខៀវ សំផន ត្រឡប់ទៅកាន់មន្ទីរឃុំឃាំងនៃអ.វ.ត.ក វិញចុះ និងបង្គាប់ឲ្យនាំខ្លួនគាត់ទាំងពីររូបត្រឡប់ចូលរួមសវនាការនៅថ្ងៃស្អែកឲ្យបានមុនម៉ោងប្រាំបួនព្រឹក។

សម្រាកចុះ៕

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការផ្អាកនៅម៉ោង ១៦:០៩ នាទី)*